**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ........សហវ.......

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពី
## កិច្ចបញ្ជិកាគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែង

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៦៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃ១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករាឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ៍ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ: ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax : 855-23-427 798

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃ២៧ ខែមេសា ឆ្នាំ២០១៧ ស្ដីពីវិធាននិងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្ដីពីកិច្ចបញ្ជិកាគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែង សម្រាប់រដ្ឋបាលថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដូចមានភ្ជាប់ជាមួយប្រកាសនេះ។

**ប្រការ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះរដ្ឋបាលថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ លើកលែងសហគ្រាសសាធារណៈ។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ នាយកវិទ្យាស្ថាន និងគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤ តទៅ។

ថ្ងៃ ពុធ ៥ កើត ខែ ពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ២០២២

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល:-**

- រដ្ឋបាលថ្នាក់ជាតិ
- រដ្ឋបាលថ្នាក់ក្រោមជាតិ
- គ្រឹះស្ថានសាធារណៈរដ្ឋបាល
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ

# គោលការណ៍ណែនាំ
# ស្ដីពី
# កិច្ចបញ្ជិកាគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែង

## មាតិកា


| | ទំព័រ |
|---|---|
| **ជំពូកទី ១៖ បទប្បញ្ញត្តិទូទៅ** | **៤** |
| ១. គោលបំណង | ៤ |
| ២. វិសាលភាព | ៤ |
| ៣. និយមន័យ | ៤ |
| **ជំពូកទី ២៖ ការទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង** | **៩** |
| **ផ្នែកទី ១៖ ការធ្វើចំណាត់ថ្នាក់និងលេខអត្តសញ្ញាណនៃទ្រព្យសកម្មរយៈពេលវែង** | **៩** |
| ១. ចំណាត់ថ្នាក់នៃទ្រព្យសកម្មរយៈពេលវែង | ៩ |
| ២. លេខអត្តសញ្ញាណនៃទ្រព្យសកម្មរយៈពេលវែង | ១០ |
| ៣. ទ្រព្យសកម្មសម្រាប់លក់ | ១១ |
| ៤. ទ្រព្យសកម្មជាបណ្តាញ | ១១ |
| ៥. ផ្នែក ឬ គ្រឿងបន្លាស់សំខាន់ៗ | ១២ |
| **ផ្នែកទី ២៖ ការទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង** | **១២** |
| ១. ប្រភេទនៃការទទួលបានទ្រព្យសកម្មរយៈពេលវែង | ១២ |
| ២. ការទទួលស្គាល់ដំបូង | ១៣ |
| ២.១. ការកំណត់តម្លៃ (ថ្លៃដើម ឬ តម្លៃបច្ចុប្បន្ន) | ១៣ |
| ២.២. លក្ខខណ្ឌនៃការទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង | ១៣ |
| ២.៣. ការទទួលស្គាល់ទ្រព្យសកម្ម ក្នុងករណីទទួលបានទ្រព្យសកម្មដោយគ្មានការបង់ថ្លៃ ឬ ក្នុងតម្លៃទាបជាងខ្លាំងធៀបនឹងថ្លៃដើម | ១៣ |
| ២.៤. ការទទួលស្គាល់ទ្រព្យសកម្មពីការដោះដូរ ឬ ការរំលត់កិច្ចសន្យា ឬ កិច្ចព្រមព្រៀងរវាងរដ្ឋនិងឯកជន | ១៤ |
| ២.៥. ការទទួលស្គាល់ទ្រព្យសកម្មដែលមិនត្រូវបានទទួលស្គាល់ក្នុងការិយបរិច្ឆេទមុនៗ | ១៤ |
| ២.៦. សមាសធាតុនៃថ្លៃដើម | ១៦ |
| ២.៧. ការវាស់វែងបន្តបន្ទាប់ ក្រោយពីការទទួលស្គាល់លើកដំបូង | ១៧ |
| ៣. តម្លៃអប្បបរមានៃការទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង | ១៧ |
| ៤. ទ្រព្យសកម្មកំពុងដំណើរការ | ១៧ |
| ៥. លក្ខខណ្ឌនៃការទទួលស្គាល់បន្ទាប់ | ១៨ |
| ៦. គណនេយ្យកម្មលើការទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង | ១៩ |

៦.១. ការទិញ ឬ ការសាងសង់ទ្រព្យសកម្មរយៈពេលវែង ១៩
៦.២. ការសាងសង់ទ្រព្យសកម្មរយៈពេលវែងកំពុងដំណើរការ ២១
៦.៣. ការទិញ ឬ ការសាងសង់ក្នុងតម្លៃទាបជាងខ្លាំងធៀបនឹងថ្លៃដើម ២៤
៦.៤. ទ្រព្យសកម្មរយៈពេលវែងជាអំណោយ ២៥
៦.៥. ការដោះដូរទ្រព្យសកម្មរយៈពេលវែងជាមួយភាគីទីបី ២៦
៦.៦. ការទទួលស្គាល់ទ្រព្យសកម្មដែលមិនទាន់បានទទួលស្គាល់ក្នុងការិយបរិច្ឆេទមុនៗ ២៨
៦.៧. ចំណាយបន្តបន្ទាប់ ២៩

**ជំពូកទី ៣÷ រំលស់ ៣១**

១. គោលការណ៍រំលស់ ៣១
២. ការត្រួតពិនិត្យឡើងវិញលើចំណាយរំលស់ ៣២
៣. វិធីសាស្ត្ររំលស់ ៣២
៤. អាយុកាលប្រើប្រាស់ ៣២
៥. ប្រតិបត្តិការ តាមដីកាមិនមែនថវិកាសម្រាប់រំលស់ ៣៣
៦. គណនេយ្យកម្មសម្រាប់រំលស់ ៣៣

**ជំពូកទី ៤÷ ការលក់ ឬ លុបចេញពីបញ្ជីគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែង ៣៥**

១. ការឈប់ទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង ៣៥
២. គណនេយ្យកម្មសម្រាប់ការលក់ ឬ ការលុបចេញពីបញ្ជីគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែង ៣៥

**ជំពូកទី ៥÷ ការត្រួតពិនិត្យផ្ទៃក្នុងពាក់ព័ន្ធនឹងទ្រព្យសកម្មរយៈពេលវែង ៣៧**

១. ការត្រួតពិនិត្យផ្ទៃក្នុង ៣៧
២. ទំនាក់ទំនងជាមួយនឹងបញ្ជីទ្រព្យសកម្មរយៈពេលវែង ៣៨

**ឧបសម្ព័ន្ធ÷**

ឧបសម្ព័ន្ធ ១÷ តារាងចំណាត់ថ្នាក់ តម្លៃអប្បបរមានៃការទទួលស្គាល់ អាយុកាលប្រើប្រាស់និងវិធីសាស្ត្ររំលស់នៃទ្រព្យសកម្មរយៈពេលវែង ៣៩
ឧបសម្ព័ន្ធ ២÷ គំរូបញ្ជីទ្រព្យសកម្មរយៈពេលវែង ៥២
ឧបសម្ព័ន្ធ ៣÷ គំរូរបាយការណ៍ចំណាយរំលស់ទ្រព្យសកម្មរយៈពេលវែង ៥៣
ឧបសម្ព័ន្ធ ៤÷ គំរូសលាកបត្របង់ចំណូលថវិកា ៥៤
ឧបសម្ព័ន្ធ ៥÷ គំរូសលាកបត្រទទួលស្គាល់ចំណាយថវិកា ៥៥

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

### ១. គោលបំណង

គោលការណ៍ណែនាំនេះ មានគោលបំណងចូលរួមពង្រឹងការគ្រប់គ្រង និងកិច្ចបញ្ជិកាគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែង របស់ស្ថាប័នសាធារណៈ ឱ្យកាន់តែមានប្រសិទ្ធភាព ស័ក្តិសិទ្ធភាព គណនេយ្យភាព និងចូលរួមបង្ការបញ្ហាប្រឈមក្នុងការអនុវត្តថវិកា ដែលពាក់ព័ន្ធការចាត់ថ្នាក់រវាងចំណាយថែទាំនិងប្រតិបត្តិការ និងចំណាយមូលធន។

គោលការណ៍ណែនាំនេះ ជួយជំរុញដល់ការចុះកិច្ចបញ្ជិកាគណនេយ្យឱ្យបានត្រឹមត្រូវលើការចំណាយមូលធន ដោយកំណត់លក្ខខណ្ឌតម្រូវ និងតម្លៃអប្បបរមានៃការទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង ការគិតរំលស់ ការឈប់ទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង និងយន្តការក្នុងការគ្រប់គ្រងទ្រព្យសកម្មរយៈពេលវែង ក្នុងអំឡុងពេលអន្តរកាល ក្នុងការផ្លាស់ប្តូរពីប្រព័ន្ធគណនេយ្យសាធារណៈមូលដ្ឋានសាច់ប្រាក់ ទៅជាប្រព័ន្ធគណនេយ្យសាធារណៈមូលដ្ឋានបង្គរ ស្របតាមទិសដៅកំណែទម្រង់នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា។

### ២. វិសាលភាព

គោលការណ៍ណែនាំនេះ អនុវត្តចំពោះស្ថាប័នសាធារណៈ។ គោលការណ៍ណែនាំនេះ ត្រូវបានអនុវត្តចំពោះកិច្ចប្រតិបត្តិការអនុវត្តថវិការបស់ស្ថាប័នសាធារណៈដែលធនធានបានមកពីគ្រប់ប្រភព រួមមានថវិការដ្ឋ ថវិកាដៃគូអភិវឌ្ឍន៍ អំណោយ ឬថវិកាផ្សេងៗទៀត និងដែលពាក់ព័ន្ធនឹងការងារមួយចំនួនដូចខាងក្រោម÷

- ការទិញ ការសាងសង់ ឬ ការទទួលបានទ្រព្យសកម្មរយៈពេលវែង
- ការកែលម្អ ការផ្លាស់ប្តូរ ការលក់ ឬ ការលុបទ្រព្យសកម្មរយៈពេលវែង
- ការទទួលស្គាល់ ឬ ការឈប់ទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង
- ការគ្រប់គ្រងទ្រព្យសកម្មកំពុងដំណើរការ
- ការទទួលខុសត្រូវក្នុងការត្រួតពិនិត្យផ្ទៃក្នុងលើការគ្រប់គ្រងទ្រព្យសកម្មរយៈពេលវែង និង
- កិច្ចបញ្ជិកាគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែង។

### ៣. និយមន័យ

ពាក្យ ឬ វាក្យស័ព្ទដែលបានប្រើប្រាស់នៅក្នុងគោលការណ៍ណែនាំនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម÷

***ការគ្រប់គ្រង:*** គឺជាឥទ្ធិពលក្នុងការទទួលអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដែលហូរចូលស្ថាប័នសាធារណៈ និងដាក់កំហិតអ្នកដទៃលើអត្ថប្រយោជន៍ទាំងនោះ។ ក្នុងការកំណត់ពីការកើតមាននៃទ្រព្យសកម្ម ស្ថាប័នសាធារណៈត្រូវទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង ដែលតម្រូវតាមលក្ខខណ្ឌនៃការទទួលស្គាល់ ទោះបីជាពុំទាន់បានចុះបញ្ជីកម្មសិទ្ធិពេញលេញក៏ដោយ។ ស្ថាប័នសាធារណៈគ្រប់គ្រងទ្រព្យសកម្ម ក្នុងករណីដែលមានលទ្ធភាពគ្រប់គ្រងអត្ថប្រយោជន៍សេដ្ឋកិច្ចដែលនឹងហូរចូលពីទ្រព្យសកម្មទាំងនោះ។

***ការរុះរើនិងការបញ្ចប់:*** គឺជាការលុប ការកម្ទេចចោល ឬ ការដកសក្តានុពលចេញពីទ្រព្យសកម្ម ដែលកើតឡើងដោយសេចក្តីសម្រេចចិត្តជាក់លាក់របស់អ្នកគ្រប់គ្រង។

***គំរូនៃការប្រើប្រាស់:*** គឺជាគំរូ លំនាំ ឬ របៀបរបបនៃអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតរបស់ទ្រព្យសកម្មដែលត្រូវរំពឹងថាបានប្រើប្រាស់ដោយស្ថាប័នសាធារណៈ។ គំរូអាចស្ថិតនៅថេរ ឬ កើនឡើង ឬ ថយចុះ។ ក្នុងករណីគ្មានព័ត៌មានដែលប្រសើរជាងមុន គំរូនៃការប្រើប្រាស់របស់ទ្រព្យសកម្មត្រូវបានសន្មតថាប្រើប្រាស់តាមគំរូថេរ។

***តម្លៃកាកសំណល់:*** គឺជាចំនួនប៉ាន់ស្មានដែលស្ថាប័នសាធារណៈអាចទទួលបានពីការលក់ទ្រព្យសកម្ម បន្ទាប់ពីដកចំណាយប៉ាន់ស្មានលើការលក់ ប្រសិនបើទ្រព្យសកម្មអស់អាយុកាលប្រើប្រាស់ និងស្ថិតក្នុងលក្ខខណ្ឌដែលបានរំពឹងទុកនៅចុងអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្ម។ លើកលែងតែ ទ្រព្យសកម្មដែលអាចជួញដូរក្នុងទីផ្សារសកម្មតម្លៃកាកសំណល់ត្រូវបានសន្មតថាស្មើសូន្យ។

***តម្លៃផ្លាស់ប្តូរ:*** គឺជាតម្លៃសរុបនៃការផ្លាស់ប្តូរសក្តានុពលអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតនៃទ្រព្យសកម្មដែលមានស្រាប់ ដោយប្រើប្រាស់ការកសាងឡើងវិញ ឬ វិធីសាស្ត្រទំនើបប្រហាក់ប្រហែល បន្ទាប់ពីពិចារណាលើភាពខុសគ្នាក្នុងការប្រើប្រាស់ទ្រព្យសកម្មដែលមានស្រាប់ និងវិធីសាស្ត្រទំនើបប្រហាក់ប្រហែល។

***តម្លៃទីផ្សារ:*** គឺជាតម្លៃសមស្របនៃទ្រព្យសកម្មដែលត្រូវបានកំណត់តាមរយៈភ័ស្តុតាងក្នុងទីផ្សារដែលអាចអង្កេតបានពីប្រវត្តិលក់នៃទ្រព្យសកម្មដែលដូចគ្នា ឬ ស្រដៀងគ្នា បន្ទាប់ពីបានកែសម្រួលលើលក្ខខណ្ឌ និងការប្រៀបធៀបនៃទ្រព្យសកម្មទាំងនោះ។

***តម្លៃយោងគណនេយ្យ:*** គឺជាតម្លៃដែលទ្រព្យសកម្មត្រូវបានទទួលស្គាល់ បន្ទាប់ពីដករំលស់បូកបន្ត។ វាជាតម្លៃដែលត្រូវរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

***តម្លៃសមស្រប:*** គឺជាតម្លៃដែលទ្រព្យសកម្មអាចត្រូវបានដោះដូរ ឬ បំណុលត្រូវបានទូទាត់រវាងភាគីដែលទទួលបានព័ត៌មានពាក់ព័ន្ធ តាមរយៈប្រតិបត្តិការដោយបើកចំហ។

***តម្លៃអប្បបរមានៃការទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង:*** គឺជាតម្លៃអប្បបរមានៃទ្រព្យសកម្មរយៈពេលវែងដែលត្រូវទទួលស្គាល់។ ចំណាយដែលស្ថិតក្រោមតម្លៃអប្បបរមានៃការទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង គឺត្រូវកត់ត្រាជាចំណាយថែទាំនិងប្រតិបត្តិការ។

***តម្លៃអាចរំលស់បាន:*** គឺជាតម្លៃនៃទ្រព្យសកម្ម ឬ ជាតម្លៃផ្លាស់ប្តូរ បន្ទាប់ពីដកតម្លៃកាកសំណល់ចេញ។

***ថ្លៃដើម:*** គឺជាចំនួននៃសាច់ប្រាក់ ឬ សាច់ប្រាក់សមមូល ដែលត្រូវបានទូទាត់ ឬ តម្លៃសមស្របនៃតម្លៃតបស្នងដែលត្រូវផ្តល់ ដើម្បីទិញ ឬ ទទួលបានទ្រព្យសកម្ម នៅពេលសាងសង់ ឬ ទទួលបានទ្រព្យសកម្មទាំងនោះ។

***ទីផ្សារសកម្ម:*** គឺជាទីផ្សារដែលអាចគោរព ឬ បំពេញតាមគ្រប់លក្ខខណ្ឌដូចខាងក្រោម÷

(ក) ធាតុ ឬ ទំនិញដែលអាចទិញ ឬ លក់នៅក្នុងទីផ្សារគឺមានលក្ខណៈដូចគ្នា

(ខ) ជាទូទៅអ្នកដែលមានឆន្ទៈក្នុងការទិញ ឬ ការលក់អាចរកបានគ្រប់ពេលវេលា និង

(គ) តម្លៃអាចរកបានជាសាធារណៈ។

***ទ្រព្យសកម្មជាអំណោយៈ*** គឺជាទ្រព្យសកម្ម ដែលត្រូវបានផ្ទេរដោយមានតម្លៃទាប ឬ គ្មានការបង់ថ្លៃ ដែលជាទូទៅតាមរយៈកិច្ចសន្យាជាមួយដៃគូអភិវឌ្ឍ ឬ តាមរយៈកិច្ចព្រមព្រៀងរបស់រាជរដ្ឋាភិបាល ឬ ការបរិច្ចាគ។

***ទ្រព្យវិនិយោគៈ*** គឺជាទ្រព្យសកម្ម(ដី ឬអគារ ឬផ្នែកនៃដី ឬផ្នែកនៃអគារ) ដែលត្រូវបានរក្សាទុកដោយម្ចាស់ ឬដោយភតិកៈតាមរយៈភតិសន្យា ដើម្បីទទួលបានប្រាក់ឈ្នួល ឬ ការកើនឡើងនូវមូលធន ឬ ទទួលបានទាំងពីរ ជាជាងប្រើប្រាស់÷

(ក) សម្រាប់ការផលិត ឬ ការផ្គត់ផ្គង់ទំនិញ ឬ សេវាកម្ម ឬ សម្រាប់គោលបំណងរដ្ឋបាល ឬ

(ខ) សម្រាប់សកម្មភាពអាជីវកម្មទូទៅ។

***ទ្រព្យសកម្មៈ*** គឺជាធនធានដែលត្រូវបានគ្រប់គ្រង ដោយសារលទ្ធផលនៃព្រឹត្តិការណ៍ក្នុងអតីតកាល និងរំពឹងថានឹងផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដែលនឹងហូរចូលស្ថាប័នសាធារណៈ។

***ទ្រព្យសកម្មជាហេដ្ឋារចនាសម្ព័ន្ធៈ*** គឺជាទ្រព្យសកម្មដែលជាទូទៅមានវិសាលភាពធំ និងជាប់ពាក់ព័ន្ធជាបណ្តាញ ឬជាកម្មវិធីនៃទ្រព្យសកម្មរួម។ សមាសធាតុនៃទ្រព្យសកម្មទាំងនេះ អាចត្រូវបានថែទាំ កែលម្អ ឬ ដកចេញដាច់ដោយឡែកពីគ្នា។ ដូចនេះ កម្រិតនិងស្តង់ដាសេវាកម្មនៃបណ្តាញរបស់ទ្រព្យសកម្មរយៈពេលវែងគឺត្រូវធ្វើឱ្យមាននិរន្តរភាពជាបន្តបន្ទាប់។ ជាទូទៅ ទ្រព្យទាំងនេះ មានអាយុកាលវែង ប៉ុន្តែមិនមានតម្លៃទីផ្សារ និងមិនអាចចល័តបាន។

***ទ្រព្យសកម្មអរូបីៈ*** គឺជាទ្រព្យសកម្មមិនមែនជារូបិយវត្ថុដែលអាចកំណត់បាន និងគ្មានរូបវន្ត។ ឧទាហរណ៍ កម្មវិធីកុំព្យូទ័រ, ប្រកាសនីយបត្រ ឬ អាជ្ញាបណ្ណ។

***ទ្រព្យសកម្មជាបណ្តាញៈ*** គឺជាសំណុំនៃទ្រព្យសកម្មផ្សេងៗគ្នា ដែលត្រូវបានយកមកតភ្ជាប់គ្នា ដើម្បីបម្រើដល់សេវាកម្ម ឬបំពេញមុខងាររួមមួយ។ ទ្រព្យសកម្មនីមួយៗ អាចមានតម្លៃទាបជាងតម្លៃអប្បបរមានៃការទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង ប៉ុន្តែមានតម្លៃជាសារវ័ន្ត នៅពេលដែលវាស់វែងតម្លៃសរុបនៃទ្រព្យសកម្មជាបណ្តាញទាំងមូល។ ឧទាហរណ៍ប្រព័ន្ធបញ្ជូនភ្លើង ឬ ប្រព័ន្ធចែកចាយទឹក។

***ទ្រព្យសកម្មរយៈពេលវែងៈ*** គឺជាទ្រព្យសកម្មដែលត្រូវបានប្រើប្រាស់និងផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ចសម្រាប់រយៈពេលលើសពី ១២ ខែ។ ទ្រព្យសកម្មរយៈពេលវែង អាចត្រូវបានប្រើប្រាស់សម្រាប់ការផលិត ឬ ការផ្គត់ផ្គង់ទំនិញ ឬ សេវាកម្ម គោលបំណងរដ្ឋបាល ឬ អាជីវកម្មទូទៅ និងមិនមែនជាសន្និធិ ឬ ទ្រព្យវិនិយោគ ឬ ទ្រព្យសកម្មហិរញ្ញវត្ថុរយៈពេលវែង។

***ចំណាយក្នុងវដ្តនៃទ្រព្យសកម្មៈ*** គឺជាចំណាយទាំងអស់ដែលជាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសកម្ម។ ចំណាយទាំងនោះរាប់បញ្ចូលទាំងចំណាយក្នុងការទិញ ប្រតិបត្តិការ ថែទាំ កែលម្អ ធ្វើឱ្យប្រសើរឡើង និងការលក់ ឬ លុបចេញពីបញ្ជី។

***ចំណាយមូលធនៈ*** គឺជាចំណាយដែលអាចបង្កើនទ្រព្យ, សក្តានុពលសេវាកម្ម ឬ អាយុកាលប្រើប្រាស់នៃទ្រព្យ ឬ នាំឱ្យមានកំណើនសក្តានុពលសេវាកម្ម។

***ចំណាយថែទាំនិងប្រតិបត្តិការៈ*** គឺជាចំណាយដែលមិនធ្វើឱ្យមានការកើនឡើងនូវអាយុកាលប្រើប្រាស់ ឬ សក្តានុពលសេវាកម្ម ឬ មិនមានតម្លៃស្មើ ឬ លើសតម្លៃអប្បបរមានៃការទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង និងគ្រាន់តែធ្វើឱ្យទ្រព្យសកម្មដំណើរការនៅក្នុងវដ្តធម្មតានៃទ្រព្យសកម្ម។

***ចំណាយកែលម្អ:*** គឺជាចំណាយដែលបង្កើនអាយុកាលប្រើប្រាស់ ឬ បង្កើនសក្តានុពលសេវាកម្មនៃទ្រព្យសកម្មលើសពីលក្ខខណ្ឌបច្ចុប្បន្ន ប៉ុន្តែមិនលើសលក្ខខណ្ឌអតិបរមាបច្ចុប្បន្ននៃទ្រព្យសកម្ម។ ឧទាហរណ៍ ការអ៊ុតកៅស៊ូផ្លូវឡើងវិញ។

***ចំណាយធ្វើឱ្យប្រសើរឡើង:*** គឺជាចំណាយដែលបង្កើនអាយុកាលប្រើប្រាស់ ឬ បង្កើនសក្តានុពលសេវាកម្មនៃទ្រព្យសកម្មលើសពីកម្រិតអតិបរមានៃលក្ខខណ្ឌបច្ចុប្បន្ននៃទ្រព្យសកម្ម។ ឧទាហរណ៍ ការពង្រីកទ្រូងផ្លូវដើម្បីបន្ថែមគន្លងផ្លូវថ្មី ឬ បង្កើនសុវត្ថិភាពក្នុងការធ្វើដំណើរ។

***ចំណាយសិក្សាស្រាវជ្រាវ:*** គឺជាចំណាយលើការអង្កេតដែលបានរៀបចំជាមុននិងដំបូងបង្អស់ ដែលត្រូវបានធ្វើឡើងជាមួយនឹងការសង្ឃឹមទុកក្នុងការទទួលបាននូវចំណេះដឹង បច្ចេកទេស និងវិទ្យាសាស្ត្រ ព្រមទាំងចំណេះដឹងថ្មីៗ។ សកម្មភាពនៃការសិក្សាស្រាវជ្រាវរួមមាន÷

(ក) សកម្មភាពនានាដែលមានគោលដៅដើម្បីទទួលយកចំណេះដឹងថ្មីបន្ថែម

(ខ) ការស្រាវជ្រាវ ការវាយតម្លៃ និងការជ្រើសរើសចុងក្រោយនៃការអនុវត្តរបកគំហើញនៃការស្រាវជ្រាវ ឬ ចំណេះដឹងថ្មី

(គ) ការស្រាវជ្រាវរកជម្រើសនានាសម្រាប់វត្ថុធាតុដើម ឧបករណ៍ ផលិតផល ដំណើរការ ប្រព័ន្ធ ឬ សេវាកម្មនានា និង

(ឃ) ការរចនាប្លង់ ការបង្កើតឡើង ការវាយតម្លៃ និងការជ្រើសរើសចុងក្រោយនៃជម្រើសដែលអាចធ្វើទៅបានចំពោះវត្ថុធាតុដើមថ្មី ឬ ល្អប្រសើរជាងមុន ឧបករណ៍ ផលិតផល ដំណើរការ ប្រព័ន្ធ ឬ សេវាកម្មនានា។ ឧទាហរណ៍ ចំណាយលើការសិក្សាសមិទ្ធិលទ្ធភាព, ចំណាយសិក្សាពីតម្រូវការ, ការចំណាយលើការពិនិត្យលើលទ្ធភាពក្នុងការសាងសង់, ចំណាយលើការវាយតម្លៃការដ្ឋានមុនពេលសម្រេចចិត្តសាងសង់ ។ល។

***ចំណាយអភិវឌ្ឍ:*** គឺជាចំណាយលើការអនុវត្តនៃរបកគំហើញថ្មីៗនៃការស្រាវជ្រាវ ឬ ចំណេះដឹងផ្សេងៗទៀត ចំពោះផែនការ ឬ ការរចនាសម្រាប់ផលិតកម្មលើវត្ថុធាតុដើមថ្មី ឬ ល្អប្រសើរជាងមុន ឧបករណ៍ ផលិតផល ដំណើរការ ប្រព័ន្ធ ឬ សេវាកម្មនានា មុនពេលចាប់ផ្តើមផលិតកម្មក្នុងទម្រង់ពាណិជ្ជកម្ម ឬ ការប្រើប្រាស់។ សកម្មភាពនៃការអភិវឌ្ឍន៍រួមមាន÷

(ក) ការរចនា ការបង្កើត និងការសាកល្បងមុនពេលផលិតកម្ម ឬ ដាក់ឱ្យដំណើរការ ឬ ការបង្កើតគំរូនានា

(ខ) ការរចនាឧបករណ៍ ឬ សម្ភារនានាដោយប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ

(គ) ការរចនាប្លង់ ការសាងសង់ និងប្រតិបត្តិការលើរោងចក្រ ដែលមិនទាន់ត្រូវបានដាក់ឱ្យដំណើរការ ឬ ប្រើប្រាស់ក្នុងការផ្តល់សេវាកម្ម

(ឃ) ការរចនា ការបង្កើតឡើង និងការសាកល្បងវិធីសាស្ត្រថ្មីដែលបានជ្រើសរើសសម្រាប់វត្ថុធាតុដើមថ្មី ឬ ល្អប្រសើរជាងមុន ឧបករណ៍ ផលិតផល ដំណើរការ ប្រព័ន្ធ ឬ សេវាកម្មនានា និង

(ង) ចំណាយក្នុងការបង្កើតគេហទំព័រ និងការអភិវឌ្ឍកម្មវិធីកុំព្យូទ័រ ។ល។ ឧទាហរណ៍ ចំណាយក្នុងការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (Non-tax Revenue Management Information System), ចំណាយក្នុងការរៀបចំ និងអភិវឌ្ឍមុខងារលទ្ធកម្មក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS), ចំណាយក្នុងការរៀបចំនិងអភិវឌ្ឍមុខងារវិភាជន៍ថវិកានៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ។ល។

***ភាពជាសារវ័ន្ត:*** ព័ត៌មានត្រូវបានចាត់ទុកថាមានភាពជាសារវ័ន្ត នៅពេលដែលការលុបចោល កំហុសឆ្គង ឬ ការភាន់ច្រឡំលើការបង្ហាញព័ត៌មាននោះ អាចមានឥទ្ធិពល និង/ឬ ខូចខាតដល់គណនេយ្យភាពរបស់ស្ថាប័នសាធារណៈ ឬសេចក្តីសម្រេចចិត្តរបស់អ្នកគ្រប់គ្រង ដោយឈរលើមូលដ្ឋាននៃរបាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័នសាធារណៈ។ ភាពជាសារវ័ន្ត គឺអាស្រ័យលើចរិតលក្ខណៈ និងបរិមាណនៃធាតុដែលត្រូវបានយកមកពិចារណាទៅតាមកាលៈទេសៈជាក់លាក់របស់រដ្ឋបាល និងអង្គភាពនីមួយៗ។

***រំលស់:*** គឺជាការបែងចែក ឬ ការវិភាជដែលមានលក្ខណៈជាប្រព័ន្ធលើតម្លៃដែលអាចរំលស់បាននៃទ្រព្យសកម្ម តាមអាយុកាលប្រើប្រាស់នៃទ្រព្យនោះ ដែលឆ្លុះបញ្ចាំងពីគំរូនៃអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត ដែលត្រូវបានប្រើប្រាស់ដោយស្ថាប័នសាធារណៈ។

***វិធីសាស្ត្ររំលស់ថេរ:*** គឺជាវិធីសាស្ត្ររំលស់ដែលត្រូវបានប្រើប្រាស់ ដើម្បីកំណត់ពីគំរូនៃការប្រើប្រាស់ ដែលត្រូវបានកំណត់ថាមិនប្រែប្រួលលើរយៈពេលកំណត់។

***វដ្តនៃទ្រព្យសកម្ម:*** គឺជារយៈពេលសរុបដែលទ្រព្យសកម្ម ត្រូវបានបង្កើតឡើងរហូតដល់ពេលលក់ ឬ លុបចេញពីបញ្ជី។ វដ្តនៃទ្រព្យសកម្មរាប់បញ្ចូលនូវសកម្មភាពដូចជា ការទិញ ការថែទាំ ការកែលម្អ និងការលក់ ឬ ការលុបចេញពីបញ្ជី។

***ស្ថាប័នសាធារណៈ:*** ដែលប្រើប្រាស់ក្នុងគោលការណ៍ណែនាំនេះ សំដៅដល់រដ្ឋបាលថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល លើកលែងតែសហគ្រាសសាធារណៈ។

***សន្និធិ:*** គឺជាទ្រព្យសកម្មរយៈពេលខ្លី ដែល÷

(ក) ត្រូវបានរក្សាទុកសម្រាប់លក់នៅក្នុងអាជីវកម្មធម្មតា

(ខ) ស្ថិតក្នុងដំណើរការនៃការផលិតសម្រាប់ការលក់ ឬ

(គ) ជាវត្ថុធាតុដើម ឬ ការផ្គត់ផ្គង់ ដែលត្រូវបានប្រើប្រាស់ក្នុងការផលិត ឬ ការផ្តល់សេវាកម្ម។

***សមាសធាតុ:*** គឺជាផ្នែកសំខាន់មួយនៃទ្រព្យសកម្មជាហេដ្ឋារចនាសម្ព័ន្ធដែលមានអាយុកាលប្រើប្រាស់ និងគំរូនៃការប្រើប្រាស់ខុសគ្នាពីផ្នែកសំខាន់ផ្សេងៗទៀត។ ផ្នែកទាំងនោះ អាចត្រូវបានបែកចែកជាផ្នែកដែលមានអាយុកាលខ្លី និងផ្នែកដែលមានអាយុកាលវែង។

***អាយុកាលប្រើប្រាស់:*** គឺជារយៈពេលដែលទ្រព្យសកម្មត្រូវបានរំពឹងថាអាចប្រើប្រាស់បាន ដោយស្ថាប័នសាធារណៈ ឬចំនួននៃការផលិត ឬ ឯកតានៃការផលិតដែលរំពឹងថានឹងទទួលបានពីទ្រព្យសកម្មរបស់ស្ថាប័នសាធារណៈ។

***អាយុកាលសេដ្ឋកិច្ច:*** គឺជាអាយុកាលសក្តានុពលសរុបនៃទ្រព្យសកម្ម ដោយរាប់បញ្ចូលអាយុកាលបន្ទាប់ពីទ្រព្យសកម្មនោះ ត្រូវបានរំលស់អស់និងមានតម្លៃយោងគណនេយ្យស្មើសូន្យ។

***អត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត:*** គឺជាសក្តានុពលក្នុងការរួមចំណែកដោយផ្ទាល់ ឬ ដោយប្រយោលក្នុងការផ្តល់ជូននូវទំនិញ ឬ សេវាកម្មទៅតាមគោលបំណងរបស់ស្ថាប័នសាធារណៈ។ អត្ថប្រយោជន៍សេដ្ឋកិច្ច គឺរាប់បញ្ចូលទាំងអត្ថប្រយោជន៍សង្គម បរិស្ថាន ហិរញ្ញវត្ថុ និងអភិបាលកិច្ច។

## ជំពូកទី ២

## ការទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង

### ផ្នែកទី ១÷ ការធ្វើចំណាត់ថ្នាក់និងលេខអត្តសញ្ញាណនៃទ្រព្យសកម្មរយៈពេលវែង

### ១. ចំណាត់ថ្នាក់នៃទ្រព្យសកម្មរយៈពេលវែង

ចំណាត់ថ្នាក់នៃទ្រព្យសកម្មរយៈពេលវែង គឺជាការចងក្រងជាក្រុមនៃទ្រព្យសកម្មរយៈពេលវែង ដែលមានចរិតលក្ខណៈ និងមុខងារស្រដៀងគ្នា ទៅតាមចំណាត់ថ្នាក់នៃទ្រព្យសកម្មរយៈពេលវែងនីមួយៗ ដើម្បីងាយស្រួលក្នុងការរាយការណ៍ហិរញ្ញវត្ថុ។ ចំណេាត់ថ្នាក់នៃទ្រព្យសកម្មរយៈពេលវែង ត្រូវបានប្រើប្រាស់ក្នុងការផ្តល់លេខសម្គាល់ដល់ទ្រព្យសកម្មនីមួយៗ ដើម្បីផ្តល់ភាពងាយស្រួលក្នុងការតាមដាន គ្រប់គ្រង និងរាយការណ៍ ដល់អ្នកគ្រប់គ្រងទ្រព្យសកម្មទាំងនោះ។

ចំណាត់ថ្នាក់នៃទ្រព្យសកម្មរយៈពេលវែង ត្រូវបានរៀបចំឡើងតាមលំដាប់លំដោយ និងបែងចែកលម្អិតទៅតាមផ្នែក មាន១ខ្ទង់, ក្រុម មាន២ខ្ទង់, ថ្នាក់ មាន២ខ្ទង់, ប្រភេទ មាន២ខ្ទង់, ធាតុ មាន៤ខ្ទង់។ លេខសម្គាល់ចំណាត់ថ្នាក់នៃទ្រព្យសកម្មរយៈពេលវែង នឹងមានទម្រង់ជា ផ្នែក-ក្រុម-ថ្នាក់-ប្រភេទ-ធាតុ (x-xx-xx-xx-xxxx)។ លេខសម្គាល់នេះអាចត្រូវបានភ្ជាប់បន្ថែមជាមួយនឹងចំណាត់ថ្នាក់ថវិកា (ឧទាហរណ៍ ចំណាត់ថ្នាក់សេដ្ឋកិច្ច) លេខកូដសម្គាល់ទ្រព្យ និងលេខរៀងទ្រព្យ ដើម្បីកំណត់អត្តសញ្ញាណនៃទ្រព្យសកម្មរយៈពេលវែងនីមួយៗ។ លេខអត្តសញ្ញាណនៃទ្រព្យសកម្មរយៈពេលវែងត្រូវបានកំណត់ដោយស្ថាប័នសាធារណៈ និងត្រូវទទួលស្គាល់ដោយអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ទ្រព្យសកម្មរយៈពេលវែងត្រូវបានបែងចែក ជា២ ផ្នែក គឺ ផ្នែកទី១ ទ្រព្យសកម្មអរូបី និងផ្នែកទី២ ទ្រព្យសកម្មរូបី។

ផ្នែកនីមួយៗត្រូវបានបែងចែកជាក្រុម-ថ្នាក់-ប្រភេទ-និងធាតុ ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ ១ នៃគោលការណ៍ណែនាំនេះ។

ការប្រើប្រាស់ចំណាត់ថ្នាក់នៃទ្រព្យសកម្មរយៈពេលវែងក្នុងគោលការណ៍ណែនាំនេះ គឺមានតែត្រឹមកម្រិតប្រភេទសិន ដូចមានកំណត់ក្នុងតារាងឧបសម្ព័ន្ធ ១។ មូលហេតុ គឺដោយសារតែការកំណត់និងបែងចែកទ្រព្យសកម្មរយៈពេលវែងជាធាតុ ដែលមានអាយុកាលខ្លី ឬ វែង មានភាពស្មុគស្មាញ, ការលំបាកខ្លាំង និងតម្រូវឱ្យមានចំណាយខ្ពស់ និងពេលវេលាច្រើន ដែលមិនឆ្លុះបញ្ចាំងពីបរិការណ៍សេដ្ឋកិច្ច និងស្ថានភាពនៃការគ្រប់គ្រងទ្រព្យសកម្មរយៈពេលវែងរបស់រាជរដ្ឋាភិបាលកម្ពុជានាពេលបច្ចុប្បន្ន។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចចេញគោលការណ៍ណែនាំបន្ថែមសម្រាប់កំណត់ចំណាត់ថ្នាក់ទ្រព្យសកម្មរយៈពេលវែងដល់កម្រិតធាតុ ទៅតាមតម្រូវការចាំបាច់។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចចេញគោលការណ៍ដាច់ដោយឡែកចំពោះទ្រព្យសកម្មរយៈពេលវែងដែលមានលក្ខណៈស្មុគស្មាញ ដូចជាទ្រព្យសកម្មភតិសន្យា ទ្រព្យសកម្មកសិកម្ម ទ្រព្យសកម្មដែលផ្តល់ហិរញ្ញប្បទានសេវាដល់ក្រុមហ៊ុនឯកជន និងទ្រព្យសកម្មរយៈពេលវែងផ្សេងទៀត ទៅតាមកាលៈទេសៈ, ពេលវេលាសមស្រប និងការកំណត់ដោយស្តង់ដាគណនេយ្យសាធារណៈកម្ពុជា។

**២. លេខអត្តសញ្ញាណនៃទ្រព្យសកម្មរយៈពេលវែង**

ទ្រព្យសកម្មរយៈពេលវែងទាំងអស់ ត្រូវតែកត់ត្រានៅក្នុងបញ្ជីទ្រព្យសកម្មរយៈពេលវែង លើកលែងតែមានគោលការណ៍អនុញ្ញាតដាច់ដោយឡែករបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ទ្រព្យសកម្មរយៈពេលវែងទាំងនោះ ត្រូវមានលេខអត្តសញ្ញាណដើម្បីសម្គាល់ទ្រព្យនីមួយៗ។ លេខអត្តសញ្ញាណនៃទ្រព្យសកម្មរយៈពេលវែង មិនអនុញ្ញាតឱ្យប្រើប្រាស់លេខស្ទួនឡើយ លើកលែងតែសំណុំនៃទ្រព្យសកម្មជាបណ្តាញតែមួយ។

ទម្រង់នៃលេខអត្តសញ្ញណនៃទ្រព្យសកម្មរយៈពេលវែង ត្រូវរៀបចំទៅតាមទម្រង់ដូចខាងក្រោម៖

លេខកូដរដ្ឋបាល - លេខកូដភូមិសាស្ត្រ - លេខសម្គាល់ចំណាត់ថ្នាក់ទ្រព្យសកម្មរយៈពេលវែង - មាតិកាគណនី - លេខកូដសម្គាល់ទ្រព្យ - លេខរៀងទ្រព្យ (AAAA-BBBB-CCCC-DDDD-EEEE-FFFF)។

AAAA ជាលេខកូដរដ្ឋបាលរបស់ស្ថាប័នសាធារណៈ

BBBB ជាលេខកូដភូមិសាស្ត្ររបស់ស្ថាប័នសាធារណៈ

CCCC ជាលេខសម្គាល់ចំណាត់ថ្នាក់ទ្រព្យសកម្មរយៈពេលវែង

DDDD មាតិកាគណនី

EEEE លេខកូដសម្គាល់ទ្រព្យ ដូចជា ស្លាកលេខរថយន្ត លេខបណ្ណសំគាល់អចលនវត្ថុ លេខកូដសំគាល់ពេលផលិត។ល។

ក្នុងករណីដែលមានលេខកូដសម្គាល់ទ្រព្យ

FFFF តំណាងឱ្យលេខរៀងទ្រព្យ ដូចជា លេខ ០០០១ តំណាងឱ្យរថយន្តទី១ ០០០២ តំណាងឱ្យរថយន្តទី២ ។ល។

**ចំណាំ៖** អក្សរតាង AAAA ដល់ EEEE មិនសំដៅដល់ចំនួនខ្ទង់ ឬ ចំនួនអក្សរឡើយ គឺប្រែប្រួលទៅតាមព័ត៌មាននៃអក្សរតាងទាំងនោះ លើកលែងតែអក្សរតាង FFFF តំណាងឱ្យលេខចំនួន ៤ ខ្ទង់។

លេខកូដរដ្ឋបាល និងលេខកូដភូមិសាស្ត្រ ត្រូវបានកំណត់យកតាមការកំណត់របស់ប្រកាសលេខ **៧៧២** សហវ -ប្រក ចុះថ្ងៃទី០៣ ខែសីហា **ឆ្នាំ២០១៧** ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់រដ្ឋបាលនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រកាសលេខ ២៤២ សហវ-ប្រក ចុះថ្ងៃទី**២៧** ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់ភូមិសាស្ត្រនៃមាតិកាថវិកា។

មាតិកាគណនី ត្រូវបានកំណត់យកតាមការកំណត់របស់ប្រកាសលេខ ៥២៣ សហវ-ប្រក ចុះថ្ងៃទី០៩ ខែឧសភាឆ្នាំ **២០១៧** ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។

លេខសម្គាល់ទ្រព្យ ត្រូវបានកំណត់យកតាមការណែនាំក្នុងចំណុច១ខាងលើ នៃផ្នែកទី១ នៃជំពូកទី២ នេះ។

លេខរៀងទ្រព្យ ត្រូវបានកំណត់តាមលំដាប់លំដោយ ដោយស្ថាប័នសាធារណៈនីមួយៗ។

ឧទាហរណ៍៖ អគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានទិញរថយន្តថ្មីមួយគ្រឿង និងបានកត់ត្រានៅក្នុងបញ្ជីទ្រព្យសកម្មរយៈពេលវែង ព្រមជាមួយនឹងលេខសម្គាល់ ១០០៩-១២០២១១-២០៦០១០១-២១០៨១-រដ្ឋ-០០១១-០០១១។

១០០៩ សំដៅដល់អគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

១២០២១១ សំដៅដល់សង្កាត់វត្តភ្នំក្នុងខណ្ឌដូនពេញ រាជធានីភ្នំពេញ

២០៦០១០១ សំដៅដល់លេខ២÷ ផ្នែកទី២ ទ្រព្យសកម្មរូបី, លេខ ០៦÷ក្រុមទី០៦ ជាសម្ភារ ឧបករណ៍ដឹកជញ្ជូន, លេខ ០១÷ ថ្នាក់ទី១ សម្ភារ ឧបករណ៍ដឹកជញ្ជូនផ្លូវគោក និងលេខ ០១÷ ប្រភេទទី១ រថយន្ត

២១០៨១ សំដៅដល់ សម្ភារ ឧបករណ៍ដឹកជញ្ជូន

អក្សរនិងលេខ រដ្ឋ-០០១១ សំដៅដល់ស្លាកលេខសម្គាល់រថយន្ត

០០១១ សំដៅដល់រថយន្តទី១១ដែលត្រូវភ្ជាប់លេខសម្គាល់ ០០១១។

## ៣. ទ្រព្យសកម្មសម្រាប់លក់

ទ្រព្យសកម្មរយៈពេលវែង ត្រូវបានចាត់ទុកថាជាទ្រព្យសកម្មសម្រាប់លក់ នៅពេលដែលទ្រព្យសកម្មនោះត្រូវបានសម្រេចថា នឹងលក់ ក្នុងអំឡុងពេល១២ខែ។ ការកំណត់ថាជាទ្រព្យសកម្មសម្រាប់លក់ត្រូវគោរពតាមគោលការណ៍ណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានការទទួលស្គាល់ដោយអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ។

ជាទូទៅ ទ្រព្យសកម្មសម្រាប់លក់កំណត់ត្រឹមតែការលក់ដី ឬ អគារបន្ទាន់ និងឥតព្រាងទុក។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងកាលៈទេសៈមួយចំនួន ទ្រព្យសកម្មសម្រាប់លក់អាចរាប់បញ្ចូលទាំងស្ថាប័នទាំងមូល ឬ ឧបករណ៍ជាក់លាក់ណាមួយ។

តម្លៃនៃទ្រព្យសកម្មសម្រាប់លក់ គឺជាតម្លៃយោងគណនេយ្យនៅក្នុងបញ្ជីទ្រព្យសកម្មរយៈពេលវែងនៅថ្ងៃដែលសម្រេចថាជាទ្រព្យសកម្មសម្រាប់លក់។ ចំណាយបន្ថែមដែលកើតឡើងក្នុងការអភិវឌ្ឍទ្រព្យសកម្មសម្រាប់លក់ នឹងត្រូវបានបញ្ចូលជាតម្លៃនៃទ្រព្យសកម្មសម្រាប់លក់។

ទ្រព្យដែលត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្មសម្រាប់លក់ គឺត្រូវវាយតម្លៃរាល់ឆ្នាំនៅចុងការិយបរិច្ឆេទរាយការណ៍។ ប្រសិនបើមានកាលៈទេសៈផ្លាស់ប្ដូរ ហើយទ្រព្យសកម្មសម្រាប់លក់ត្រូវបានពិចារណាថា នឹងមិនត្រូវបានលក់វិញ ក្នុងរយៈពេល ១២ ខែ នោះទ្រព្យសកម្មសម្រាប់លក់នោះ នឹងត្រូវចាត់ថ្នាក់ជាទ្រព្យសកម្មរយៈពេលវែង ទៅតាមវិធីសាស្ត្រវាយតម្លៃ (ថ្លៃដើម ឬ តម្លៃសមស្រប)។

នៅពេលដែលទ្រព្យសកម្មត្រូវបានចាត់ទុកជាទ្រព្យសកម្មសម្រាប់លក់ ការគិតរំលស់លើទ្រព្យសកម្មនោះ គឺត្រូវបញ្ឈប់ផងដែរ។

## ៤. ទ្រព្យសកម្មជាបណ្ដាញ

ទ្រព្យសកម្មជាបណ្ដាញ គឺជាសំណុំនៃទ្រព្យសកម្មផ្សេងៗគ្នា ដែលត្រូវបានយកមកតភ្ជាប់គ្នា ដើម្បីបម្រើដល់សេវាកម្ម ឬ បំពេញមុខងាររួមមួយ។

ទ្រព្យសកម្មនីមួយៗ អាចមានតម្លៃទាបជាងតម្លៃអប្បបរមានៃការទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង ប៉ុន្តែមានតម្លៃជាសារវ័ន្ត នៅពេលដែលវាស់វែងតម្លៃសរុបនៃទ្រព្យសកម្មជាបណ្ដាញទាំងមូល។

ឧទាហរណ៍ទី១÷ ប្រព័ន្ធបណ្ដាញចែកចាយទឹក សំដៅដល់សមាសធាតុនៃបណ្ដាញចែកចាយទឹកដោយរាប់បញ្ចូលទាំងអាងស្ដុកទឹក រោងចក្រកែច្នៃទឹក ប្រព័ន្ធទុយោធំៗ និងប្រព័ន្ធចែកចាយទឹក ។ល។

ឧទាហរណ៍ទី២÷ ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ សំដៅដល់សមាសធាតុដែលរាប់បញ្ចូលការរៀបចំឈូសឆាយផ្លូវ ការរៀបចំទ្រូងផ្លូវ ការចាក់បំពេញដីនិងក្រួសលើផ្លូវ ការអ៊ុតកៅស៊ូផ្លូវ ការរៀបចំបណ្តាញលូបង្ហូរទឹក ការដាក់ស្លាកសញ្ញាចរាចរណ៍ ។ល។

**៥. ផ្នែក ឬ គ្រឿងបន្លាស់សំខាន់ៗ**

ចំណាយលើផ្នែក ឬ គ្រឿងបន្លាស់នៃទ្រព្យសកម្មរយៈពេលវែងអាចមានចំនួនតិចតួច ឬ ធំៗជាសារវ័ន្ត។ ចំណាយតិចតួចលើផ្នែក ឬ គ្រឿងបន្លាស់ ត្រូវបានកត់ត្រាជាចំណាយចរន្ត។ ប៉ុន្តែចំណាយធំៗជាសារវ័ន្តលើផ្នែក ឬ គ្រឿងបន្លាស់សំខាន់ៗនៃទ្រព្យសកម្មរយៈពេលវែងត្រូវកត់ត្រាជាចំណាយមូលធន។ ផ្នែក ឬ គ្រឿងបន្លាស់សំខាន់ៗមួយចំនួនតម្រូវឱ្យមានការផ្លាស់ប្តូរនៅក្នុងចន្លោះពេលថេរ ឬ ក្រោយពេលការទទួលស្គាល់ដំបូង។ ឧទាហរណ៍ ផ្លូវថ្នល់ តម្រូវឱ្យមានការអ៊ុតកៅស៊ូឡើងវិញរៀងរាល់ ៥ ឆ្នាំ ឬ គ្រឿងខាងក្នុងយន្តហោះដូចជា កៅអី បន្ទប់ធ្វើម្ហូប ធ្នើរដាក់សម្ភាររបស់អ្នកដំណើរ អាចតម្រូវឱ្យមានការផ្លាស់ប្តូរ ឬ ជំនួសច្រើនដងក្នុងអំឡុងអាយុកាលនៃយន្តហោះ។ ចំណាយជាសារវ័ន្តលើផ្នែក ឬ គ្រឿងបន្លាស់សំខាន់ៗទាំងនោះ ត្រូវកត់ត្រាជាចំណាយមូលធននៅក្នុងតារាងតុល្យការទៅតាមចំណាត់ថ្នាក់នៃទ្រព្យសកម្មទាំងនោះ។

ចំណាយលើផ្នែក ឬ គ្រឿងបន្លាស់សំខាន់ៗនៃទ្រព្យសកម្មរយៈពេលវែង ត្រូវបានទទួលស្គាល់ជាទ្រព្យសកម្មរយៈពេលវែងនៅក្នុងតារាងតុល្យការទៅតាមចំណាត់ថ្នាក់នៃទ្រព្យសកម្មរយៈពេលវែង ប្រសិនបើបំពេញគ្រប់លក្ខខណ្ឌដូចខាងក្រោម÷

- ចំណាយស្មើ ឬ លើសពីតម្លៃអប្បបរមានៃការទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង និង
- ផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ចលើសពី ១២ ខែ។

ផ្នែក ឬ គ្រឿងបន្លាស់សំខាន់ៗ ដែលត្រូវបានប្រើប្រាស់ភ្ជាប់ជាមួយទ្រព្យសកម្មជាក់លាក់ណាមួយនោះ ត្រូវកត់ត្រាទៅតាមចំណាត់ថ្នាក់នៃទ្រព្យសកម្មរយៈពេលវែងនោះ។

ក្នុងករណីដែលផ្នែក ឬ គ្រឿងបន្លាស់សំខាន់ៗត្រូវបានទទួលស្គាល់ជាទ្រព្យសកម្មរយៈពេលវែង ផ្នែក ឬ គ្រឿងបន្លាស់ចាស់ដែលត្រូវបានផ្លាស់ប្តូរទាំងនោះអាចលុបចេញពីបញ្ជីទ្រព្យសកម្មរយៈពេលវែង នៅក្នុងករណីដែលផ្នែក ឬ គ្រឿងបន្លាស់ចាស់ទាំងនោះនៅមានតម្លៃយោងគណនេយ្យ និងអាចវាស់វែងបាន ស្របទៅតាមលក្ខខណ្ឌដែលមានចែងនៅចំណុច១នៃជំពូកទី៤ អំពីការឈប់ទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង។

**ផ្នែកទី ២÷ ការទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង**

**១. ប្រភេទនៃការទទួលបានទ្រព្យសកម្មរយៈពេលវែង**

ស្ថាប័នសាធារណៈ អាចទទួលបានទ្រព្យសកម្មរយៈពេលវែង តាមរយៈ÷

១. ការទិញ ឬ ការសាងសង់ ឬ ការអភិវឌ្ឍន៍ដោយខ្លួនឯង នូវទ្រព្យសកម្មទាំងនោះ ដោយត្រូវបង់ជាតម្លៃតបស្នង

២. អំណោយ ឬ វិភាគទាន ដោយគ្មានការបង់ថ្លៃទិញ ឬ ក្នុងតម្លៃមួយដែលទាបជាងខ្លាំងធៀបនឹងថ្លៃដើម

៣. ការដោះដូរទ្រព្យសកម្ម ឬ ការរំលត់កិច្ចសន្យា ឬ កិច្ចព្រមព្រៀងរវាងរដ្ឋនិងឯកជន

៤. ការទទួលស្គាល់ទ្រព្យសកម្មដែលមិនទាន់បានទទួលស្គាល់ក្នុងការិយបរិច្ឆេទមុនៗ ប៉ុន្តែត្រូវបានកំណត់ក្នុងពេលបន្តបន្ទាប់តាមរយៈការរាប់ទ្រព្យសកម្មរយៈពេលវែង ឬ នៅក្នុងដំណើរការផ្សេងៗ។

## ២. ការទទួលស្គាល់ដំបូង

### ២.១. ការកំណត់តម្លៃ (ថ្លៃដើម ឬ តម្លៃបច្ចុប្បន្ន)

តម្លៃរបស់ទ្រព្យសកម្មរយៈពេលវែងត្រូវបានកំណត់តាមរយៈវិធីសាស្ត្រថ្លៃដើម ឬ វិធីសាស្ត្រតម្លៃបច្ចុប្បន្ន។

វិធីសាស្ត្រថ្លៃដើម ត្រូវបានប្រើប្រាស់លើទ្រព្យសកម្មរយៈពេលវែង ដែលស្ថាប័នសាធារណៈ បានទិញ សាងសង់ ឬ អភិវឌ្ឍន៍ដោយខ្លួនឯង។

រីឯ វិធីសាស្ត្រតម្លៃបច្ចុប្បន្ន ឬ តម្លៃសមស្រប ត្រូវបានប្រើប្រាស់ ចំពោះទ្រព្យសកម្មដែលទទួលបានពីអំណោយ ឬ ការចូលរួមវិភាគទាន, ការដោះដូរ ឬ ការរំលត់កិច្ចសន្យា ឬ កិច្ចព្រមព្រៀងរវាងរដ្ឋនិងឯកជន និងទ្រព្យសកម្មដែលមិនទាន់បានទទួលស្គាល់ក្នុងការិយបរិច្ឆេទមុនៗ។ វិធីសាស្ត្រតម្លៃបច្ចុប្បន្ន ត្រូវបានវាស់វែងតាមតម្លៃទីផ្សារ ប្រសិនបើមានទីផ្សារសកម្មដែលអាចរកបាន ឬ តម្លៃផ្លាស់ប្តូរក្រោយកាត់រំលស់ ប្រសិនបើពុំមានទីផ្សារសកម្មដែលអាចរកបាន។

### ២.២. លក្ខខណ្ឌនៃការទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង

ស្ថាប័នសាធារណៈ ត្រូវទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង ក្នុងករណីទ្រព្យសកម្មនោះបំពេញគ្រប់លក្ខខណ្ឌដូចខាងក្រោម÷

- ទ្រព្យសកម្មនោះ មានរូបរាងជារូបវ័ន្ត (លើកលែងតែទ្រព្យសកម្មរយៈពេលវែងអរូបី)
- ស្ថាប័នសាធារណៈមានសិទ្ធិទទួលបានអត្ថប្រយោជន៍ ឬ មានសិទ្ធិដាក់កំហិតអ្នកដទៃពីការប្រើប្រាស់ទ្រព្យសកម្មនោះ
- អាចទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត ឬ សក្តានុពលសេវាកម្មដែលពាក់ព័ន្ធនឹងទ្រព្យសកម្មនោះ
- ទ្រព្យសកម្មនោះមិនត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្មរយៈពេលវែងសម្រាប់លក់ ហើយទ្រព្យសកម្មនោះត្រូវបានរំពឹងថានឹងប្រើប្រាស់លើសពី ១២ ខែ
- ថ្លៃដើមនៃទ្រព្យសកម្មនោះអាចត្រូវបានវាស់វែងជាក់លាក់ និង
- តម្លៃនៃទ្រព្យសកម្មនោះស្មើ ឬ លើសតម្លៃអប្បបរមានៃការទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង។

**<u>ចំណាំ</u>**÷ ស្ថាប័នសាធារណៈ ត្រូវកត់ត្រាតាមទម្រង់ដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធ ២ នៃគោលការណ៍ណែនាំនៅរាល់ពេលទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង។ ទន្ទឹមនឹងនេះ ស្ថាប័នសាធារណៈ ត្រូវបន្តកត់ត្រាតាមដានបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ស្របតាមលិខិតបទដ្ឋានគតិយុត្តិជាធរមាន។

### ២.៣. ការទទួលស្គាល់ទ្រព្យសកម្មក្នុងករណីទទួលបានទ្រព្យសកម្មដោយគ្មានការបង់ថ្លៃ ឬ ក្នុងតម្លៃទាបខ្លាំងធៀបនឹងថ្លៃដើម

ទ្រព្យសកម្មទាំងអស់ដែលបំពេញលក្ខខណ្ឌនៃការទទួលស្គាល់ក្នុងចំណុច ២.២ ត្រូវបានវាស់វែងតាមវិធីសាស្ត្រថ្លៃដើម។ តម្លៃនៃទ្រព្យសកម្មដែលទទួលបានដោយគ្មានការបង់ថ្លៃ ឬ ក្នុងតម្លៃទាបខ្លាំងធៀបនឹងថ្លៃដើម (សម្រាប់ទ្រព្យដែលទទួលបានពីអំណោយ ឬ វិភាគទាន) គឺត្រូវវាស់វែងតាមវិធីសាស្ត្រតម្លៃសមស្របនៅថ្ងៃដែលទទួលបានទ្រព្យសកម្មនោះ។ ក្នុងករណីមិនមានទីផ្សារសកម្ម ទ្រព្យសកម្មដែលត្រូវបានទទួលនោះត្រូវវាស់វែងតាមវិធីសាស្ត្រតម្លៃផ្លាស់ប្តូរក្រោយកាត់រំលស់។

ឧទាហរណ៍÷ ក្រសួងសាធារណការនិងដឹកជញ្ជូន បានទិញរថយន្តដឹកជញ្ជូនថ្មីមួយគ្រឿង ដែលមានតម្លៃទីផ្សារ ១០០ ០០០ ០០០ រៀល។ ក្រសួងសាធារណការនិងដឹកជញ្ជូន តម្រូវឱ្យបង់ទឹកប្រាក់ត្រឹមតែ ៥០%នៃតម្លៃទីផ្សារ ដែលមានទឹកប្រាក់ស្មើនឹង ៥០ ០០០ ០០០ រៀល រីឯទឹកប្រាក់៥០% ទៀតស្មើ ៥០ ០០០ ០០០ រៀល ត្រូវបានទូទាត់ដោយដៃគូអភិវឌ្ឍ។

ក្នុងករណីនេះ ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវទទួលស្គាល់រថយន្តជាទ្រព្យសកម្មរយៈពេលវែងតាមតម្លៃទីផ្សារដែលស្មើនឹង ១០០ ០០០ ០០០ រៀល ដោយសារតែមានតម្លៃទីផ្សារដែលអាចអង្កេតបាន ទោះបីជាក្រសួងបានចំណាយទឹកប្រាក់ត្រឹមតែ ៥០ ០០០ ០០០ រៀលក៏ដោយ។

### ២.៤. ការទទួលស្គាល់ទ្រព្យសកម្មពីការដោះដូរ ឬ ការរំលត់កិច្ចសន្យា ឬ កិច្ចព្រមព្រៀងរវាងរដ្ឋនិងឯកជន

ទ្រព្យសកម្មទាំងអស់ដែលបំពេញលក្ខខណ្ឌនៃការទទួលស្គាល់ក្នុងចំណុច ២.២ ត្រូវបានវាស់វែងតាមវិធីសាស្ត្រថ្លៃដើម។ ទ្រព្យសកម្មដែលទទួលបានពីការដោះដូរ ឬ ការរំលស់កិច្ចសន្យា ឬ កិច្ចព្រមព្រៀងរវាងរដ្ឋ និងឯកជន ត្រូវបានវាស់វែងតាមវិធីសាស្ត្រតម្លៃបច្ចុប្បន្ននៅថ្ងៃដែលត្រូវទទួលស្គាល់ទ្រព្យទាំងនោះ។ តម្លៃនៃទ្រព្យសកម្មនោះត្រូវបានវាស់វែងដូចខាងក្រោម÷

- តម្លៃទីផ្សារ ប្រសិនបើមានទីផ្សារសកម្មដែលអាចរកបាន ឬ
- តម្លៃផ្លាស់ប្តូរក្រោយកាត់រំលស់ ប្រសិនបើមិនមានទីផ្សារសកម្មដែលអាចរកបាន។

### ២.៥. ការទទួលស្គាល់ទ្រព្យសកម្មដែលមិនទាន់បានទទួលស្គាល់ក្នុងការិយបរិច្ឆេទមុនៗ

ទ្រព្យសកម្មទាំងអស់ដែលបំពេញលក្ខខណ្ឌនៃការទទួលស្គាល់ក្នុងចំណុច ២.២ ត្រូវបានវាស់វែងតាមវិធីសាស្ត្រថ្លៃដើម។ នៅពេលដែលទ្រព្យសកម្មមិនត្រូវបានទទួលស្គាល់ក្នុងការិយបរិច្ឆេទមុនៗ និងត្រូវបានកំណត់ក្នុងពេលបន្តបន្ទាប់តាមរយៈការរាប់ទ្រព្យសកម្មរយៈពេលវែង ឬ ដំណើរការផ្សេងៗ ទ្រព្យសកម្មនោះត្រូវបានវាស់វែងតាមវិធីសាស្ត្រតម្លៃបច្ចុប្បន្ននៅថ្ងៃដែលត្រូវទទួលស្គាល់។ តម្លៃនៃទ្រព្យសកម្មនោះត្រូវបានវាស់វែងដូចខាងក្រោម÷

- តម្លៃទីផ្សារ ប្រសិនបើមានទីផ្សារសកម្មដែលអាចរកបាន ឬ
- តម្លៃផ្លាស់ប្តូរក្រោយកាត់រំលស់ ប្រសិនបើមិនមានទីផ្សារសកម្មដែលអាចរកបាន។

ឧទាហរណ៍ទី១÷ រដ្ឋាភិបាលជប៉ុនបានផ្តល់អំណោយជាអគារសាលារៀនមួយខ្នងមាន៥បន្ទប់ ដល់សាលារៀនក.ខ. នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០X១។ សាលារៀន ក.ខ. មិនបានទទួលស្គាល់សាលារៀនជាទ្រព្យសកម្មរយៈពេលវែងនោះទេ រហូតដល់ ថ្ងៃទី០១ ខែមករា ឆ្នាំ២០X៥។ សាលារៀន ក.ខ. បានវាស់វែងតម្លៃសរុបនៃសាលារៀននេះដោយប្រើប្រាស់វិធីសាស្ត្រតម្លៃផ្លាស់ប្តូរក្រោយកាត់រំលស់ ដោយសារតែមិនអាចរកតម្លៃទីផ្សារបាន។ តាមរយៈការវាយតម្លៃនេះ សាលារៀនប្រើប្រាស់វិធីសាស្ត្រប្រហាក់ប្រហែលក្នុងការសាងសង់សាលារៀននៅក្នុងតំបន់នៃសាលារៀន ក.ខ. ហើយត្រូវបានវាស់វែងក្នុងតម្លៃសរុប ២០០ ០០០ ០០០ រៀល។ សាលារៀនបានប្រើប្រាស់វិធីសាស្ត្រកែសម្រួលតម្លៃវាស់វែង (Adjustment Factors) ស្មើនឹង -៥% នៃតម្លៃសរុប ដើម្បីកែសម្រួលលើកំហុសបច្ចេកទេសក្នុងការវាយតម្លៃ ព្រមទាំងគិតថា ទ្រព្យសកម្មនោះ មានគុណភាពនៅសល់ត្រឹមតែ ៨៥% នៃគុណភាពសំណង់អគារសាលារៀន។ តារាងវាយតម្លៃត្រូវបានលម្អិតដូចខាងក្រោម÷

| បរិយាយ | តម្លៃជារៀល |
|---|---|
| តម្លៃសរុបនៃសាលារៀន ក.ខ. | ២០០ ០០០ ០០០ |
| វិធីសាស្ត្រកែសម្រួលតម្លៃស្មើ -៥% នៃតម្លៃសរុប | (១០ ០០០ ០០០) |
| តម្លៃក្រោយពេលកាត់កងវិធីសាស្ត្រកែសម្រួលតម្លៃ | ១៩០ ០០០ ០០០ |
| តម្លៃដែលនៅសល់នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០X៥ ត្រឹមកម្រិតគុណភាព (៨៥%) | ១៦១ ៥០០ ០០០ |

តាមរយៈការវាស់វែងដូចលម្អិតខាងលើ សាលារៀន ក.ខ. ត្រូវទទួលស្គាល់អគារសាលារៀន ជាទ្រព្យសកម្មរយៈពេលវែងក្នុងតម្លៃ ១៦១ ៥០០ ០០០ រៀល ទោះបីជាសាលារៀន មិនបានចំណាយក្នុងការកសាងអគារក៏ដោយ។

ឧទាហរណ៍ទី២÷ រដ្ឋាភិបាលជប៉ុន បានផ្តល់ជំនួយឥតសំណងក្នុងការកសាងរោងចក្រកែច្នៃទឹកកខ្វក់ក្នុងខណ្ឌដង្កោ រាជធានី ភ្នំពេញ ដែលចំណាយរយៈពេលសាងសង់អស់ ២ ឆ្នាំ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០X០ រហូតដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០X១ ដោយចំណាយអស់ទឹកប្រាក់សរុប ៤ ០០០ ០០០ ០០០ រៀល។ រោងចក្រកែច្នៃទឹកកខ្វក់ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០X២ និងតាមរយៈកិច្ចសន្យាផ្តល់ជំនួយឥតសំណង រដ្ឋាភិបាលជប៉ុននៅបន្តគ្រប់គ្រងនិងផ្តល់ជំនួយបច្ចេកទេសក្នុងការប្រើប្រាស់និងថែទាំរោងចក្រកែច្នៃទឹកកខ្វក់នោះ រហូតដល់ថ្ងៃទី០១ ខែមករា ឆ្នាំ ២០X៣ ទើបប្រគល់រោងចក្រកែច្នៃទឹកកខ្វក់ជូនរាជរដ្ឋាភិបាលកម្ពុជា។ ដោយសារតម្លៃបច្ចុប្បន្នរបស់រោងចក្រកែច្នៃទឹកកខ្វក់ ពុំអាចកំណត់បានតាមរយៈទីផ្សារសកម្ម រាជរដ្ឋាភិបាលកម្ពុជា បានប្រើប្រាស់វិធីសាស្ត្រតម្លៃផ្លាស់ប្តូរក្រោយកាត់រំលស់ ដើម្បីវាស់វែងតម្លៃបច្ចុប្បន្នរបស់រោងចក្រកែច្នៃទឹកកខ្វក់ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០X៣ ដែលជាថ្ងៃដែលត្រូវទទួលស្គាល់រោងចក្រកែច្នៃទឹកកខ្វក់នោះ។ រាជរដ្ឋាភិបាលកម្ពុជា ក៏បានប្រើប្រាស់វិធីសាស្ត្រកែសម្រួលតម្លៃវាស់វែង (Adjustment Factors) ស្មើនឹង -១០% នៃតម្លៃសរុប និងបានកំណត់អាយុកាលប្រើប្រាស់របស់រោងចក្រកែច្នៃទឹកកខ្វក់ត្រឹមរយៈពេល ១០ឆ្នាំ ដោយសន្មតតម្លៃកាកសំណល់ស្មើសូន្យ។ តារាងវាយតម្លៃលម្អិតគឺមានដូចខាងក្រោម÷

| បរិយាយ | តម្លៃជារៀល |
|---|---|
| តម្លៃសរុបនៃរោងចក្រកែច្នៃទឹកកខ្វក់ | ៤ ០០០ ០០០ ០០០ |
| វិធីសាស្ត្រកែសម្រួលតម្លៃស្មើ -១០% នៃតម្លៃសរុប | (៤០០ ០០០ ០០០) |
| តម្លៃក្រោយពេលកាត់កងវិធីសាស្ត្រកែសម្រួលតម្លៃ | ៣ ៦០០ ០០០ ០០០ |
| ចំណាយរំលស់រយៈពេល ១ឆ្នាំ ៣៦ ០០០ ០០០ (៣៦០ ០០០ ០០០-០)/១០ | (៣៦០ ០០០ ០០០) |
| តម្លៃដែលនៅសល់នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០X៣ ក្រោយកាត់រំលស់ | ៣ ២៤០ ០០០ ០០០ |

តាមរយៈការវាស់វែងដូចមានលម្អិតខាងលើ រាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលស្គាល់រោងចក្រកែច្នៃទឹកកខ្វក់ជាទ្រព្យសកម្មរយៈពេលវែងក្នុងតម្លៃ ៣ ២៤០ ០០០ ០០០ រៀល ទោះបីជារាជរដ្ឋាភិបាលកម្ពុជា មិនបានចំណាយក្នុងការកសាងរោងចក្រកែច្នៃទឹកកខ្វក់ក៏ដោយ។

## ២.៦. សមាសធាតុនៃថ្លៃដើម

សមាសធាតុដែលត្រូវពិចារណាក្នុងការកំណត់ថ្លៃដើម ឬ តម្លៃដំបូងនៃទ្រព្យសកម្ម រួមមាន÷

- ថ្លៃទិញ រាប់បញ្ចូលទាំងពន្ធ និងអាករពិសេស បន្ទាប់ពីដកអប្បហា ការសងត្រឡប់មកវិញ ឬ ពន្ធដែលអាចប្រមូលមកវិញ
- ចំណាយផ្សេងៗ ដែលទាក់ទងដោយផ្ទាល់ទៅនឹងការនាំយកទ្រព្យសកម្មទាំងនោះមកដាក់នៅទីតាំង និងលក្ខខណ្ឌដែលចង់បាន។

ចំណាយដែលទាក់ទងដោយផ្ទាល់ទៅនឹងថ្លៃដើមនៃទ្រព្យសកម្ម ហើយត្រូវទទួលស្គាល់ក្នុងតារាងតុល្យការនោះ រាប់បញ្ចូលដូចខាងក្រោម÷

- ចំណាយក្នុងកិច្ចសន្យាសម្រាប់ការសាងសង់
- ចំណាយអត្ថប្រយោជន៍បុគ្គលិកសម្រាប់បុគ្គលិកដែលជាប់ទាក់ទងដោយផ្ទាល់ក្នុងការសាងសង់ ឬ ការទទួលបានទ្រព្យសកម្មនោះ
- ចំណាយក្នុងការរៀបចំការដ្ឋាន
- ចំណាយលើគម្រោងប្លង់លម្អិត រាប់បញ្ចូលទាំងចំណាយដែលពាក់ព័ន្ធ
- ចំណាយក្នុងការដឹកជញ្ជូន ឬ ការលើកដាក់
- ចំណាយក្នុងការតម្លើង ផ្គុំ ឬ បញ្ចូលកម្មវិធី
- ចំណាយក្នុងការរុះរើនិងចំណាយក្នុងការបញ្ចប់
- ចំណាយលើកម្រៃសេវាកម្មវិជ្ជាជីវៈ
- ចំណាយបោសសំអាតមីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងចំណាយដែលពាក់ព័ន្ធការដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ និង
- ចំណាយផ្សេងទៀត ដែលជាប់ទាក់ទងដោយផ្ទាល់នឹងទ្រព្យសកម្ម។

**<u>បញ្ជាក់</u>÷** ក្នុងបរិការណ៍សេដ្ឋកិច្ចនិងស្ថានភាពបច្ចុប្បន្ន ការប្រាក់លើប្រាក់កម្ចីសម្រាប់ផ្តល់ហិរញ្ញប្បទានលើគម្រោងនានាដែលកើតឡើងក្នុងអំឡុងពេលនៃការសាងសង់ (បើទោះជាចំណាយនោះមានភាពជាសារវន្តចំពោះចំណាយទូទៅនៃគម្រោងក៏ដោយ) មិនត្រូវបានទទួលស្គាល់ជាផ្នែកនៃថ្លៃដើមនៃទ្រព្យសកម្មនោះទេ។

ថ្លៃដើម ដែលមិនទាក់ទងដោយផ្ទាល់ទៅនឹងថ្លៃដើមនៃទ្រព្យសកម្ម មិនត្រូវបានទទួលស្គាល់ទៅក្នុងតារាងតុល្យការ រាប់បញ្ចូលនូវថ្លៃនានាដូចខាងក្រោម÷

- ចំណាយក្នុងការបើកការសម្របសម្រួលថ្មី (រាប់បញ្ចូលនូវចំណាយក្នុងការបណ្តុះបណ្តាលបុគ្គលិក ចំណាយក្នុងការប្រារព្ធពិធីសម្ពោធ ឬ ចំណាយក្នុងការចរចារ)
- ចំណាយក្នុងការណែនាំផលិតផល ឬ សេវាថ្មី (រាប់បញ្ចូលទាំងចំណាយផ្សាយពាណិជ្ជកម្ម)
- ចំណាយក្នុងការថែទាំកម្មវិធីជាសាមាយិក និងបន្ទុកនានាលើកិច្ចព្រមព្រៀងនៃអាជ្ញាបណ្ណ

- ចំណាយរដ្ឋបាលទូទៅ និងចំណាយលើសង្វាក់ផលិតកម្ម
- ចំណាយនានាពាក់ព័ន្ធនឹងការសិក្សាសមិទ្ធិលទ្ធភាព ឬ ការសិក្សាលើលទ្ធភាពដែលអាចធ្វើបាន ចំណាយសិក្សាស្រាវជ្រាវ ផែនការមេ ផែនការគោលគំនិត និងចំណាយលើការស៊ើបអង្កេត នៅត្រឹមចំណុចដែលត្រូវសម្រេចចិត្តលើការអនុវត្តគម្រោង ឬ មុនពេលបំពេញនិយមន័យនៃចំណាយអភិវឌ្ឍ
- ចំណាយក្នុងការត្រួតពិនិត្យ ឬ អធិការកិច្ច ប៉ុន្តែពុំមានការធ្វើឱ្យប្រសើរឡើងជារូបវ័ន្ត ការកែលម្អ ឬ ការផ្លាស់ប្តូរទ្រព្យសកម្ម។

នៅក្នុងកាលៈទេសៈមួយចំនួន តម្លៃទ្រព្យសកម្ម ដែលត្រូវបានទទួលស្គាល់ រាប់បញ្ចូលទាំងតម្លៃប៉ាន់ប្រមាណពីដំបូងក្នុងការរុះរើ ឬ ដកទ្រព្យសកម្មនោះចេញ ឬ ត្រូវស្តារទីតាំងការដ្ឋាននោះឡើងវិញ។ ចំណាយទាំងនោះអាចត្រូវបានទទួលស្គាល់ នៅពេលដែល÷

- ចំណាយទាំងនោះត្រូវបានវាស់វែងដោយជាក់លាក់
- ចំណាយទាំងនោះមានភាពជាសារវ័ន្ត ទាំងចំនួន ឬ ចរិតលក្ខណៈ និង
- នៅពេលដែលកើតមានកាតព្វកិច្ចជាក់លាក់ដែលគ្របដណ្តប់ដោយបទប្បញ្ញត្តិ ឬ កាតព្វកិច្ចបរិស្ថាន នៅពេលដែលទ្រព្យសកម្មទាំងនោះត្រូវបានដាក់ឱ្យប្រើប្រាស់ជាលើកដំបូង។

### ២.៧. ការវាស់វែងបន្តបន្ទាប់ ក្រោយពីការទទួលស្គាល់លើកដំបូង

ក្រោយពីការទទួលស្គាល់ទ្រព្យសកម្មលើកដំបូង ទ្រព្យសកម្មត្រូវបានវាស់វែងជាបន្តបន្ទាប់ ដោយយកតាមតម្លៃយោងគណនេយ្យ (ថ្លៃដើមដករំលស់បូកបន្ត)។

## ៣. តម្លៃអប្បបរមានៃការទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង

ចំណាយត្រូវបានទទួលស្គាល់តាមមូលដ្ឋាននៃភាពជាសារវ័ន្ត។ តម្លៃអប្បបរមានៃការទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែងត្រូវបានកំណត់ទៅតាមប្រភេទនៃទ្រព្យសកម្មរយៈពេលវែង ដែលមានលម្អិតក្នុងឧបសម្ព័ន្ធ ១ នៃគោលការណ៍ណែនាំនេះ។

## ៤. ទ្រព្យសកម្មកំពុងដំណើរការ

ទ្រព្យសកម្មអាចត្រូវការរយៈពេលសាងសង់យូរ ឬ ច្រើនជាងមួយការិយបរិច្ឆេទ ដែលទាមទារឱ្យមានការចំណាយច្រើនដងទៅតាមដំណាក់កាល ឬ ផ្នែក។ ចំណាយទៅលើទ្រព្យសកម្មកំពុងដំណើរការទាំងនោះត្រូវបានគ្រោងនិងកត់ត្រាក្នុងគណនីនៃទ្រព្យសកម្មកំពុងដំណើរការ។ ទ្រព្យសកម្មកំពុងដំណើរការត្រូវទទួលស្គាល់ជាទ្រព្យសកម្មរយៈពេលវែងទៅតាមប្រភេទនៃទ្រព្យសកម្មរយៈពេលវែងដោយគណនេយ្យករសាធារណៈ ដោយផ្អែកលើអាណត្តិបើកប្រាក់ទូទាត់ចំណាយស្របតាមប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រកាសលេខ ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ។

ស្ថាប័នសាធារណៈត្រូវពិនិត្យសមតុល្យគណនីនៃទ្រព្យសកម្មកំពុងដំណើរការ ជារៀងរាល់ខែ និងត្រូវធានាថាទ្រព្យសកម្មកំពុងដំណើរការដែលបានទទួលស្គាល់ជាទ្រព្យសកម្មរយៈពេលវែងដោយគណនេយ្យករសាធារណៈ ត្រូវបានផ្ទេរចេញពីបញ្ជីទ្រព្យសកម្មកំពុងដំណើរការទៅក្នុងបញ្ជីទ្រព្យសកម្មរយៈពេលវែង។

## ៥. លក្ខខណ្ឌនៃការទទួលស្គាល់បន្ទាប់

ចំណាយដែលកើតឡើងក្រោយការទទួលស្គាល់ដំបូង អាចត្រូវបានកត់ត្រាជាចំណាយចរន្តនៅក្នុងរបាយការណ៍ចំណូលចំណាយ ឬ ត្រូវបានកត់ត្រាជាចំណាយមូលធននៃទ្រព្យសកម្មរយៈពេលវែងនៅក្នុងតារាងតុល្យការ។

នៅពេលដែលធ្វើការប្រៀបធៀបទៅនឹងទ្រព្យសកម្មដែលមានស្រាប់ ចំណាយដែលកើតឡើងក្រោយការទទួលស្គាល់ដំបូង ត្រូវទទួលស្គាល់ជាចំណាយមូលធន ប្រសិនបើចំណាយទាំងនោះ ត្រូវបំពេញគ្រប់លក្ខខណ្ឌដូចខាងក្រោម÷

- មានតម្លៃស្មើ ឬ លើសតម្លៃអប្បបរមានៃការទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង និង
- បង្កើនអាយុកាលប្រើប្រាស់នៃទ្រព្យសកម្ម ឬ ផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវាកម្មបន្ថែមលើសពីរយៈពេល ១២ ខែ។

ការកំណត់ជាចំណាយថែទាំនិងប្រតិបត្តិការ ឬ ចំណាយមូលធន នឹងតម្រូវឱ្យមានការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈ ប៉ុន្តែត្រូវបំពេញតាមនិយមន័យនិងលក្ខខណ្ឌនៃការទទួលស្គាល់នៃចំណាយទាំងនោះ។ ឧទាហរណ៍ខាងក្រោម ផ្តល់ជាការណែនាំខ្លះៗលើចំណាយជាទូទៅ និងការធ្វើគណនេយ្យកម្មលើចំណាយទាំងនោះ÷

| ចំណាត់ថ្នាក់ | ចំណាយ | ទាបជាងតម្លៃអប្បបរមានៃការទទួលស្គាល់ | ស្មើ ឬលើសតម្លៃអប្បបរមា និងបំពេញលក្ខខណ្ឌនៃការទទួលស្គាល់បន្ទាប់ |
|---|---|---|---|
| | | ចំណាយថែទាំ និងប្រតិបត្តិការ | ចំណាយមូលធន |
| អគារ | ប្តូរបង្អួច | ✓ | |
| | ប្តូរទ្វារ | | ✓ |
| | លាបពណ៌ខាងក្នុងអគារ | ✓ | ✓ |
| | ជួសជុលម៉ាស៊ីនត្រជាក់ | ✓ | |
| | ជួសជុលដំបូលដែលជ្រាបទឹក | ✓ | |
| | ប្រកដំបូលឡើងវិញទាំងអស់ | | ✓ |
| | ប្តូរទុយោទឹក | ✓ | |
| | ប្តូរទុយោទឹក និងម៉ាស៊ីនបូមទឹក | ✓ | ✓ |
| ផ្លូវថ្នល់ | ជួសជុលជង្ហុកធំៗ | ✓ | ✓ |
| | ក្រាលកៅស៊ូឡើងវិញ | | ✓ |
| | ឈូសឆាយពង្រាបផ្លូវដើរ | | ✓ |
| | ក្រាលក្រួសក្រហមលើផ្លូវ | ✓ | |
| | ក្រាលក្រួសក្រហមលើផ្លូវទាំងមូល | | ✓ |



ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ៦. គណនេយ្យកម្មលើការទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង

### ៦.១. ការទិញ ឬ ការសាងសង់ទ្រព្យសកម្មរយៈពេលវែង

**ឧទាហរណ៍ទី១÷ការទិញរថយន្ត÷**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទិញរថយន្តមួយគ្រឿងដែលមានចំណាយដូចរៀបរាប់ខាងក្រោម÷

| ល.រ | បរិយាយ | ចំនួន (រៀល) |
|---|---|---|
| ១ | ថ្លៃដើមនៃការទិញ | ៨០ 000 000 |
| ២ | ថ្លៃដឹកជញ្ជូន | ១ 000 000 |
| | **ចំណាយសរុប** | **៨១ 000 000** |

**កិច្ចបញ្ជិកាគណនេយ្យ÷**

ឥណពន្ធ គណនី សម្ភារ ឧបករណ៍ដឹកជញ្ជូនផ្លូវគោក (លេខ ២១០៨១) ៨១ 000 000 រៀល

ឥណទាន គណនី អ្នកផ្គត់ផ្គង់ (៤០០១) ៨១ 000 000 រៀល។

នៅពេលទូទាត់÷

ឥណពន្ធ គណនី អ្នកផ្គត់ផ្គង់ (លេខ ៤០០១) ៨១ 000 000 រៀល

ឥណទាន គណនី ធនាគារ (លេខ ១១..) ៨១ 000 000 រៀល។

**ឧទាហរណ៍ទី២÷ការសាងសង់អគារ**

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សាងសង់អគារថ្មីដែលមានចំណាយ ដូចរៀបរាប់ខាងក្រោម÷

| ល.រ | បរិយាយ | ចំនួន (រៀល) |
|---|---|---|
| ១ | ចំណាយលើការពិនិត្យលទ្ធភាពក្នុងការសាងសង់ | ១០ 000 000 |
| ២ | ចំណាយលើការវាយតម្លៃការដ្ឋានមុនសាងសង់ | ៥ 000 000 |
| ៣ | សម្ភារសំណង់ | ៥០០ 000 000 |
| ៤ | ថ្លៃពលកម្មលើការសាងសង់ | ២០០ 000 000 |
| | **ចំណាយសរុប** | **៧១៥ 000 000** |

**កិច្ចបញ្ជិកាគណនេយ្យ÷**

**ចំណាយមូលធន÷**

ឥណពន្ធ គណនី សំណង់អគារ (លេខ ២១០៣១) ៧០០ 000 000 រៀល

ឥណទាន គណនី អ្នកផ្គត់ផ្គង់ (៤០០១) ៧០០ 000 000 រៀល។

នៅពេលទូទាត់÷

ឥណពន្ធ គណនី អ្នកផ្គត់ផ្គង់ (លេខ ៤០០១) ៧០០ ០០០ ០០០ រៀល

ឥណទាន គណនី ធនាគារ (លេខ ១១..) ៧០០ ០០០ ០០០ រៀល។

**ចំណាយលើសោហ៊ុយសិក្សាពិសោធន៍÷**

ឥណពន្ធ គណនី សោហ៊ុយសិក្សាពិសោធន៍ (លេខ ៦១០៧១) ១៥ ០០០ ០០០ រៀល

ឥណទាន គណនី អ្នកផ្គត់ផ្គង់ (៤០០១) ១៥ ០០០ ០០០ រៀល។

នៅពេលទូទាត់÷

ឥណពន្ធ គណនី អ្នកផ្គត់ផ្គង់ (លេខ ៤០០១) ១៥ ០០០ ០០០ រៀល

ឥណទាន គណនី ធនាគារ (លេខ ១១..) ១៥ ០០០ ០០០ រៀល។

**ចំណាំ**÷ ចំណាយលើសម្ភារសំណង់ចំនួន ៥០០ ០០០ ០០០រៀល និងថ្លៃពលកម្មលើការសាងសង់ ២០០ ០០០ ០០០រៀល ត្រូវបានកត់ត្រាជាចំណាយមូលធន ដោយសារតែចំណាយទាំងនេះជាប់ពាក់ព័ន្ធដោយផ្ទាល់លើការសាងសង់សំណង់អគារ។ ចំណែកចំណាយលើការពិនិត្យលទ្ធភាពក្នុងការសាងសង់ចំនួន ១០ ០០០ ០០០ រៀល និងចំណាយលើការវាយតម្លៃការដ្ឋានមុនសាងសង់ចំនួន ៥ ០០០ ០០០ រៀល ត្រូវបានកត់ត្រាជាចំណាយថែទាំនិងប្រតិបត្តិការ ដោយសារតែចំណាយទាំងនេះ មិនជាប់ពាក់ព័ន្ធដោយផ្ទាល់ក្នុងការសាងសង់ ឬ ការទទួលបានសំណង់អគារ។

**ឧទាហរណ៍ទី៣÷ ការទិញអាជ្ញាបណ្ណកម្មវិធីកុំព្យូទ័រ**

ក្រសួងព័ត៌មានទិញកម្មវិធីកុំព្យូទ័រក្នុងទឹកប្រាក់ចំនួន ១៥ ០០០ ០០០ រៀល។ ដើម្បីបន្តប្រើប្រាស់កម្មវិធីកុំព្យូទ័រនេះ ក្រសួងព័ត៌មានត្រូវបង់សេវាថែទាំប្រចាំឆ្នាំ ចំនួន ២ ០០០ ០០០ រៀងរាល់ឆ្នាំ។

**កិច្ចបញ្ជិកាគណនេយ្យ÷**

ឥណពន្ធ គណនី កម្មវិធីកុំព្យូទ័រ (លេខ ២០០៥៤) ១៥ ០០០ ០០០ រៀល

ឥណទាន គណនី អ្នកផ្គត់ផ្គង់ (៤០០១) ១៥ ០០០ ០០០ រៀល ។

នៅពេលទូទាត់÷

ឥណពន្ធ គណនី អ្នកផ្គត់ផ្គង់ (លេខ ៤០០១) ១៥ ០០០ ០០០ រៀល

ឥណទាន គណនី ធនាគារ (លេខ ១១..) ១៥ ០០០ ០០០ រៀល ។

**ចំណាំ**÷ ចំណាយក្នុងការថែទាំប្រចាំឆ្នាំចំនួន ២ ០០០ ០០០ រៀល ត្រូវកត់ត្រាជាចំណាយថែទាំនិងប្រតិបត្តិការ។

**ឧទាហរណ៍ទី៤÷ ការទិញប្រកាសនីយបត្រ**

ក្រសួងសុខាភិបាល ទិញប្រកាសនីយបត្រលើរូបមន្តក្នុងការផលិតថ្នាំបង្ការការពារជំងឺរលាកថ្លើមប្រភេទ B (វ៉ាក់សាំង) ពីក្រុមហ៊ុនផលិតថ្នាំបង្ការការពារជំងឺ កខគ។ ថ្នាំបង្ការការពារជំងឺរលាកថ្លើមប្រភេទ B គឺត្រូវបានការពារដោយប្រកាសនីយបត្រ និងត្រូវចំណាយទឹកប្រាក់ចំនួន ២០០ ០០០ ០០០ រៀល ដើម្បីទទួលបានរូបមន្តក្នុងការផលិត និងចែកចាយថ្នាំបង្ការការពារជំងឺរលាកថ្លើមប្រភេទ B។

**កិច្ចបញ្ជិកាគណនេយ្យ÷**

ឥណពន្ធ គណនី ប្រកាសនីយបត្រ (លេខ ២០០៥១) ២០០ ០០០ ០០០ រៀល

ឥណទាន គណនី អ្នកផ្គត់ផ្គង់ (៤០០១) ២០០ ០០០ ០០០ រៀល។

នៅពេលទូទាត់÷

ឥណពន្ធ គណនី អ្នកផ្គត់ផ្គង់ (លេខ ៤០០១) ២០០ ០០០ ០០០ រៀល

ឥណទាន គណនី ធនាគារ (លេខ ១១..) ២០០ ០០០ ០០០ រៀល។

**<u>ចំណាំ</u>÷** ចំណាយទឹកប្រាក់ចំនួន ២០០ ០០០ ០០០ រៀល ត្រូវបានទទួលស្គាល់ជាទ្រព្យសកម្មរយៈពេលវែងអរូបី ដោយសារតែចំណាយនេះបំពេញលក្ខខណ្ឌនៃការទទួលស្គាល់ និងមានតម្លៃលើសតម្លៃអប្បបរមានៃការទទួលស្គាល់។

**ឧទាហរណ៍ទី៥÷ ការទិញដី**

ក្រសួងអប់រំ យុវជន និងកីឡា សម្រេចបង្កើតវិទ្យាល័យថ្មីមួយក្នុងឃុំ ក. ដើម្បីជួយសម្រួលដល់ការធ្វើដំណើរឆ្ងាយពីផ្ទះរបស់សិស្សានុសិស្សទៅសាលារៀនរបស់ពួកគេ ដោយបានទិញដីមួយកន្លែងក្នុងឃុំ ក. ដែលមានបណ្តោយ ៥០ ម៉ែត្រ និងទទឹង ៣០ ម៉ែត្រ ក្នុងទំហំទឹកប្រាក់ ២៤០ ០០០ ០០០ រៀល។

**កិច្ចបញ្ជិកាគណនេយ្យ÷**

ឥណពន្ធ គណនី ដីធ្លី (លេខ ២១០១១) ២៤០ ០០០ ០០០ រៀល

ឥណទាន គណនី អ្នកផ្គត់ផ្គង់ (៤០០១) ២៤០ ០០០ ០០០ រៀល។

នៅពេលទូទាត់÷

ឥណពន្ធ គណនី អ្នកផ្គត់ផ្គង់ (លេខ ៤០០១) ២៤០ ០០០ ០០០ រៀល

ឥណទាន គណនី ធនាគារ (លេខ ១១..) ២៤០ ០០០ ០០០ រៀល។

**៦.២. ការសាងសង់ទ្រព្យសកម្មរយៈពេលវែងកំពុងដំណើរការ**

ចំពោះទ្រព្យសកម្មរយៈពេលវែងដែលត្រូវសាងសង់ ឬ បញ្ចប់ក្នុងការិយបរិច្ឆេទច្រើនជាងមួយឆ្នាំ គណនីទ្រព្យសកម្មកំពុងដំណើរការ (ក្នុងជំពូក២៣ នៃប្លង់គណនេយ្យសាធារណៈ) ត្រូវបានប្រើប្រាស់សម្រាប់ចុះកិច្ចបញ្ជិកាគណនេយ្យ ទៅតាមដំណាក់កាលនៃការសាងសង់ ឬ បញ្ចប់។ នៅពេលដែលការសាងសង់ត្រូវបានបញ្ចប់ និងទ្រព្យសកម្មនោះត្រូវបានរៀបចំរួចរាល់សម្រាប់ការប្រើប្រាស់ គណនេយ្យករសាធារណៈត្រូវចាត់ចែងផ្ទេរសមតុល្យនៃគណនីទ្រព្យសកម្មកំពុងដំណើរការ ទៅគណនីទ្រព្យសកម្មរយៈពេលវែងដែលពាក់ព័ន្ធ។

**ឧទាហរណ៍ទី១÷ ការសាងសង់អគារ**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សាងសង់អគារថ្មីសម្រាប់អគ្គនាយកដ្ឋានរតនាគារជាតិ ដែលត្រូវការរយៈពេលសាងសង់ពីរឆ្នាំ ដើម្បីបញ្ចប់ក្នុងគម្រោងទឹកប្រាក់ចំនួន ៤០ ០០០ ០០០ ០០០ រៀល។ ឆ្នាំទី១ សាងសង់បាន៥០% និងឆ្នាំទី២ បញ្ចប់ការសាងសង់៥០%។ ការទូទាត់ប្រាក់គឺធ្វើឡើងតាមរយៈអាណត្តិបើកប្រាក់ ដោយមានភ្ជាប់ជាមួយនូវកិច្ចសន្យា និងកំណត់ហេតុវាយតម្លៃលើការងារសម្រាប់ដំណាក់កាលនីមួយៗ។



ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**នៅពេលទទួលបានអាណត្តិបើកប្រាក់សម្រាប់ការងារនៅដំណាក់កាលទី១÷**

ឥណពន្ធ គណនី អចលកម្មកំពុងដំណើរការ (លេខ ២៣០៣១) ២០ ០០០ ០០០ ០០០ រៀល

ឥណទាន គណនី អ្នកផ្គត់ផ្គង់ (លេខ ៤០០១) ២០ ០០០ ០០០ ០០០ រៀល។

**នៅពេលទូទាត់÷**

ឥណពន្ធ គណនី អ្នកផ្គត់ផ្គង់ (លេខ ៤០០១) ២០ ០០០ ០០០ ០០០ រៀល

ឥណទាន គណនី ធនាគារ (លេខ ១១..) ២០ ០០០ ០០០ ០០០ រៀល។

**នៅពេលទទួលបានអាណត្តិបើកប្រាក់សម្រាប់បញ្ចប់ការងារនៅដំណាក់កាលទី២÷**

ឥណពន្ធ គណនី អចលកម្មកំពុងដំណើរការ (លេខ ២៣០៣១) ២០ ០០០ ០០០ ០០០ រៀល

ឥណទាន គណនី អ្នកផ្គត់ផ្គង់ (លេខ ៤០០១) ២០ ០០០ ០០០ ០០០ រៀល។

**នៅពេលទូទាត់÷**

ឥណពន្ធ គណនី អ្នកផ្គត់ផ្គង់ (លេខ ៤០០១) ២០ ០០០ ០០០ ០០០ រៀល

ឥណទាន គណនី ធនាគារ (លេខ ១១..) ២០ ០០០ ០០០ ០០០ រៀល។

**ការផ្ទេរពីគណនីទ្រព្យសកម្មកំពុងដំណើរការទៅជាគណនីទ្រព្យសកម្មរយៈពេលវែង÷**

ឥណពន្ធ គណនី សំណង់អគារ (លេខ ២១០៣១) ៤០ ០០០ ០០០ ០០០ រៀល

ឥណទាន គណនី អចលកម្មកំពុងដំណើរការ (លេខ ២៣០៣១) ៤០ ០០០ ០០០ ០០០ រៀល។

<u>**ចំណាំ**</u>÷ គណនេយ្យករសាធារណៈត្រូវយោងលើអាណត្តិបើកប្រាក់ ដើម្បីធ្វើការផ្ទេរពីគណនីទ្រព្យសកម្មកំពុងដំណើរការទៅជាគណនីទ្រព្យសកម្មរយៈពេលវែង។

**ឧទាហរណ៍ទី២÷ ការសាងសង់ស្ពានដែលការទូទាត់មានច្រើនប្រភេទ និងច្រើនដំណាក់កាល**

ក្រសួងសាធារណការនិងដឹកជញ្ជូន សម្រេចសាងសង់ស្ពានឆ្លងកាត់ទន្លេបាសាក់ (គណនីផ្លូវថ្នល់ ផ្លូវទឹក) ដែលមានចំណាយសរុបជាទឹកប្រាក់ចំនួន ១៦០ ០០០ ០០០ ០០០ រៀល ដោយផ្តល់ឱ្យក្រុមហ៊ុន កខគ ជាអ្នកសាងសង់។ ការសាងសង់បានចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០X១ និងបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០X៣។ សំណើសុំបុរេប្រទានត្រូវបានធ្វើឡើងតាមរយៈក្រសួងសាធារណការនិងដឹកជញ្ជូន និងសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមនីតិវិធីជាធរមាន។ តាមរយៈកិច្ចសន្យាសាងសង់និងសំណើសុំបុរេប្រទានរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រេចផ្តល់បុរេប្រទានជាសាច់ប្រាក់ចំនួន ៦៤ ០០០ ០០០ ០០០ រៀល ដែលស្មើនឹង ៤០% នៃចំណាយសរុបនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០X១។ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០X២ ក្រសួងសាធារណការនិងដឹកជញ្ជូនបានធ្វើកំណត់ហេតុវាយតម្លៃលើការងារសម្រាប់ដំណាក់កាលទី១ ដែលសម្រេចបាន ៥០% និងស្នើសុំទូទាត់ ២០%បន្ថែមទៀត ដែលក្នុងនោះស្នើសុំទូទាត់១០% បន្ថែមលើបុរេប្រទានទី១ ដោយយោងតាមកំណត់ហេតុវាយតម្លៃលើការងារសម្រាប់ដំណាក់កាលទី១ និងស្នើសុំបុរេប្រទានជាសាច់ប្រាក់បន្ថែមចំនួន ១៦ ០០០ ០០០ ០០០ រៀល ដែលស្មើនឹង ១០% នៃចំណាយសរុប។ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០X៣ ក្រសួងសាធារណការនិងដឹកជញ្ជូន បានធ្វើកំណត់ហេតុវាយតម្លៃបញ្ចប់ការងារដោយ



ព្រះរាជាណាចក្រកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេចបាន ១០០% និងស្នើសុំទូទាត់ទឹកប្រាក់ ៣០% នៃចំណាយសរុប បន្ទាប់ពីកាត់កងបុរេប្រទានជាសាច់ប្រាក់។ ក្រោយពីបំពេញកម្រិតគុណភាពតាមកិច្ចសន្យាធានា នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០X៤ ក្រសួងសាធារណការនិងដឹកជញ្ជូន បានធ្វើអាណត្តិទូទាត់បើកប្រាក់១០% ដែលនៅសល់ដើម្បីទូទាត់ជូនក្រុមហ៊ុន។ តារាងលម្អិតនៃសំណើសុំបុរេប្រទាននិងការទូទាត់ត្រូវបានរៀបរាប់លម្អិតដូចខាងក្រោម÷

| កាលបរិច្ឆេទ | កាលវិភាគទូទាត់ | កំណត់ហេតុវាយតម្លៃលើការងារតាមដំណាក់កាល (លានរៀល) | បុរេប្រទានជា សាច់ប្រាក់ (លានរៀល) | លំហូរសាច់ប្រាក់ចេញ (លានរៀល) |
|---|---|---|---|---|
| ថ្ងៃទី០១ ខែមករា ឆ្នាំ ២០X១ | បុរេប្រទានទី១ | 0 | (៦៤ 000) | (៦៤ 000) |
| ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០X២ | ការទូទាត់ទី១ | ៨0 000 | ៦៤ 000 | (១៦ 000) |
| ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០X២ | បុរេប្រទានទី២ | 0 | (១៦ 000) | (១៦ 000) |
| ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០X៣ | ការទូទាត់ទី២ | ៦៤ 000 | ១៦ 000 | (៤៨ 000) |
| ០១ ខែឧសភា ឆ្នាំ២០X៤ | ការទូទាត់លើទី៣ | ១៦ 000 | 0 | (១៦ 000) |
| **ចំណាយសរុប** | | **១៦0 000** | 0 | **១៦0 000** |

**កិច្ចបញ្ជិកាគណនេយ្យ÷**

១.កត់ត្រាចំណាយជាបណ្តោះអាសន្ន (បុរេប្រទានសាច់ប្រាក់) សម្រាប់វិនិយោគ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០X១

ឥណពន្ធ គណនី ចំណាយជាបណ្តោះអាសន្ន (បុរេប្រទានសាច់ប្រាក់) សម្រាប់វិនិយោគ (លេខ ១៥០៥២) ៦៤ 000 000 000 រៀល

ឥណទាន គណនី ធនាគារ (លេខ ១១..) ៦៤ 000 000 000 រៀល។

២. កត់ត្រាការទូទាត់លើកទី១ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០X២

ឥណពន្ធ គណនី ផ្លូវថ្នល់ ផ្លូវទឹក កំពុងដំណើរការ (លេខ ២៣០៤១) ៨០ 000 000 000 រៀល

ឥណទាន គណនី អ្នកផ្គត់ផ្គង់ (លេខ ៤០០១) ៨០ 000 000 000 រៀល។

**នៅពេលទូទាត់និងកាត់កងជាមួយចំណាយជាបណ្តោះអាសន្ន (បុរេប្រទានសាច់ប្រាក់) សម្រាប់វិនិយោគ÷**

ឥណពន្ធ គណនី អ្នកផ្គត់ផ្គង់ (លេខ ៤០០១) ៨០ 000 000 000 រៀល

ឥណទាន គណនី ធនាគារ (លេខ ១១..) ១៦ 000 000 000 រៀល

ឥណទាន គណនី ចំណាយជាបណ្តោះអាសន្ន (បុរេប្រទានសាច់ប្រាក់) សម្រាប់វិនិយោគ (លេខ ១៥០៥២) ៦៤ 000 000 000 រៀល។

៣. កត់ត្រាចំណាយជាបណ្តោះអាសន្ន (បុរេប្រទានសាច់ប្រាក់) សម្រាប់វិនិយោគ បន្ថែម ១០%នៃចំណាយសរុប នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០X២

ឥណពន្ធ គណនី ចំណាយជាបណ្តោះអាសន្ន(បុរេប្រទានសាច់ប្រាក់) សម្រាប់វិនិយោគ (លេខ ១៥០៥២) ១៦ 000 000 000 រៀល

ឥណទាន គណនី ធនាគារ (លេខ ១១..) ១៦ 000 000 000 រៀល។

៤. កត់ត្រាការទូទាត់លើកទី២ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០X៣

ឥណពន្ធ គណនី ផ្លូវថ្នល់ ផ្លូវទឹក កំពុងដំណើរការ (លេខ ២៣០៤១) ៦៤ ០០០ ០០០ ០០០ រៀល

ឥណទាន គណនី អ្នកផ្គត់ផ្គង់ (លេខ ៤០០១) ៦៤ ០០០ ០០០ ០០០ រៀល។

**នៅពេលទូទាត់និងកាត់កងជាមួយចំណាយជាបណ្តោះអាសន្ន (បុរេប្រទានសាច់ប្រាក់) សម្រាប់វិនិយោគ÷**

ឥណពន្ធ គណនី អ្នកផ្គត់ផ្គង់ (លេខ ៤០០១) ៦៤ ០០០ ០០០ ០០០ រៀល

ឥណទាន គណនី ធនាគារ (លេខ ១១..) ៤៨ ០០០ ០០០ ០០០ រៀល

ឥណទាន គណនី ចំណាយជាបណ្តោះអាសន្ន (បុរេប្រទានសាច់ប្រាក់) សម្រាប់វិនិយោគ (លេខ ១៥០៥២) ១៦ ០០០ ០០០ ០០០ រៀល។

៥. នៅពេលការសាងសង់ស្ពានចប់សព្វគ្រប់ និងផ្ទេរពីគណនីទ្រព្យសកម្មកំពុងដំណើរការទៅជាហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០X៣

កិច្ចបញ្ជិកាគណនេយ្យ÷

ឥណពន្ធ គណនី ផ្លូវថ្នល់ ផ្លូវទឹក (លេខ ២១០៤១) ១៤៤ ០០០ ០០០ ០០០ រៀល

ឥណទាន គណនី ផ្លូវថ្នល់ ផ្លូវទឹក កំពុងដំណើរការ (លេខ ២៣០៤១) ១៤៤ ០០០ ០០០ ០០០ រៀល។

៦. កត់ត្រាការទូទាត់លើកទី៣ (សម្រាប់ការធានាសុពលភាព) នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០X៤

ឥណពន្ធ គណនី ផ្លូវថ្នល់ ផ្លូវទឹក (លេខ ២១០៤១) ១៦ ០០០ ០០០ ០០០ រៀល

ឥណទាន គណនី អ្នកផ្គត់ផ្គង់ (លេខ ៤០០១) ១៦ ០០០ ០០០ ០០០ រៀល។

នៅពេលទូទាត់÷

ឥណពន្ធ គណនី អ្នកផ្គត់ផ្គង់ (លេខ ៤០០១) ១៦ ០០០ ០០០ ០០០ រៀល

ឥណទាន គណនី ធនាគារ (លេខ ១១..) ១៦ ០០០ ០០០ ០០០ រៀល។

### ៦.៣. ការទិញ ឬ ការសាងសង់ក្នុងតម្លៃទាបខ្លាំងធៀបនឹងថ្លៃដើម

ស្ថាប័នសាធារណៈដែលទទួលបានថវិកាបដិភាគក្នុងការទិញ ឬ ការសាងសង់ទ្រព្យសកម្មរយៈពេលវែង ត្រូវរៀបចំសលាកបត្របង់ចំណូលថវិកា ដូចមានគំរូភ្ជាប់ក្នុងឧបសម្ព័ន្ធ ៤ និងសលាកបត្រទទួលស្គាល់ចំណាយថវិកា ដូចមានគំរូភ្ជាប់ក្នុងឧបសម្ព័ន្ធ ៥ នៃគោលការណ៍ណែនាំនេះ សម្រាប់ចំណែកទឹកប្រាក់ដែលត្រូវបានទូទាត់ត្រង់ដោយដៃគូអភិវឌ្ឍ ឬ ភាគីទីបី ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ និងបញ្ជូនមកគណនេយ្យករសាធារណៈ ដើម្បីអនុវត្តមុខងារបន្ត។

**ឧទាហរណ៍ទី១÷ ការទិញរថយន្តដោយការមានការឧបត្ថម្ភពីអ្នកលក់ ឬ ភាគីទី៣**

ក្រសួងព័ត៌មានទិញរថយន្ត ១គ្រឿង ក្នុងតម្លៃ ២៤០ ០០០ ០០០ រៀល ប៉ុន្តែត្រូវបានតម្រូវឱ្យទូទាត់ត្រឹមតែ ៨០ ០០០ ០០០ រៀល រីឯ ១៦០ ០០០ ០០០ រៀល ជាការឧបត្ថម្ភរបស់អ្នកលក់ ឬ ភាគីទី៣ ដោយទូទាត់ត្រង់ទៅអ្នកផ្គត់ផ្គង់។

**កិច្ចបញ្ជិកាគណនេយ្យ÷**

ឥណពន្ធ គណនី សម្ភារ ឧបករណ៍ដឹកជញ្ជូន (លេខ ២១០៨១) ២៤០ ០០០ ០០០ រៀល

ឥណទាន គណនី ការឧបត្ថម្ភ និងអំណោយ (លេខ ៧៥..) ១៦០ ០០០ ០០០ រៀល

ឥណទាន គណនី អ្នកផ្គត់ផ្គង់ (លេខ ៤០០១) ៨០ ០០០ ០០០ រៀល។

នៅពេលទូទាត់÷

ឥណពន្ធ គណនី អ្នកផ្គត់ផ្គង់ (លេខ ៤០០១) ៨០ ០០០ ០០០ រៀល

ឥណទាន គណនី ធនាគារ (លេខ ១១..) ៨០ ០០០ ០០០ រៀល។

**ឧទាហរណ៍ទី២÷ ការសាងសង់ផ្លូវថ្នល់ដោយមានការឧបត្ថម្ភពីភាគីទី៣**

ក្រសួងអភិវឌ្ឍន៍ជនបទ សាងសង់ផ្លូវលំមួយខ្សែដោយចំណាយទឹកប្រាក់សរុបចំនួន ៣០០ ០០០ ០០០ រៀល។ ក្នុងការសាងសង់ផ្លូវលំនេះ ក្រសួងបានទទួលថវិកាពីដៃគូអភិវឌ្ឍចំនួន ១៥០ ០០០ ០០០ រៀល ដែលថវិកា ត្រូវបានទូទាត់ត្រង់ដោយដៃគូអភិវឌ្ឍទៅអ្នកផ្គត់ផ្គង់។

**កិច្ចបញ្ជិកាគណនេយ្យ÷**

ឥណពន្ធ គណនី ផ្លូវថ្នល់ ផ្លូវទឹក (លេខ ២១០៤១) ៣០០ ០០០ ០០០ រៀល

ឥណទាន គណនី ការឧបត្ថម្ភ និងអំណោយ (លេខ ៧៥..) ១៥០ ០០០ ០០០ រៀល

ឥណទាន គណនី អ្នកផ្គត់ផ្គង់ (លេខ ៤០០១) ១៥០ ០០០ ០០០ រៀល។

នៅពេលទូទាត់÷

ឥណពន្ធ គណនី អ្នកផ្គត់ផ្គង់ (លេខ ៤០០១) ១៥០ ០០០ ០០០ រៀល

ឥណទាន គណនី ធនាគារ (លេខ ១១..) ១៥០ ០០០ ០០០ រៀល។

### ៦.៤. ទ្រព្យសកម្មរយៈពេលវែងជាអំណោយ

ស្ថាប័នសាធារណៈដែលទទួលបានអំណោយជាទ្រព្យសកម្មរយៈពេលវែង ត្រូវរៀបចំសលាកបត្របង់ចំណូលថវិកា ដូចមានគំរូភ្ជាប់ក្នុងឧបសម្ព័ន្ធ ៤ និងសលាកបត្រទទួលស្គាល់ចំណាយថវិកា ដូចមានគំរូភ្ជាប់ក្នុងឧបសម្ព័ន្ធ ៥ នៃគោលការណ៍ណែនាំនេះ សម្រាប់ទឹកប្រាក់ដែលត្រូវបានទូទាត់ ឬ ផ្តល់ដោយដៃគូអភិវឌ្ឍ ឬ ភាគីទីបី ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ និងបញ្ជូនមកគណនេយ្យករសាធារណៈ ដើម្បីអនុវត្តមុខងារបន្ត។

**ឧទាហរណ៍ទី១÷ការផ្តល់អំណោយជាស្ពាន**

ដៃគូអភិវឌ្ឍ បានផ្តល់អំណោយជាស្ពានឆ្លងទន្លេមួយដល់រាជរដ្ឋាភិបាលកម្ពុជា ដែលចំណាយទឹកប្រាក់សាងសង់អស់ចំនួន ២០០ ០០០ ០០០ ០០០ រៀល។

**កិច្ចបញ្ជិកាគណនេយ្យ÷**

ឥណពន្ធ គណនី ផ្លូវថ្នល់ ផ្លូវទឹក (លេខ ២១០៤១) ២០០ ០០០ ០០០ ០០០ រៀល

ឥណទាន គណនី ការឧបត្ថម្ភ និងអំណោយ (លេខ ៧៥..) ២០០ ០០០ ០០០ ០០០ រៀល។

**ឧទាហរណ៍ទី២÷ការផ្តល់អំណោយជារថយន្តក្រុងសាធារណៈ**

រដ្ឋាភិបាលជប៉ុន តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន បានផ្តល់រថយន្តក្រុងសាធារណៈដល់រាជរដ្ឋាភិបាលកម្ពុជា ចំនួន១០ គ្រឿងក្នុងទំហំទឹកប្រាក់ចំនួន ៤០ ០០០ ០០០ ០០០ រៀល។ រាជរដ្ឋាភិបាលកម្ពុជាបានចំណាយទឹកប្រាក់អស់ចំនួន ២០ ០០០ ០០០ រៀល លើការដឹកជញ្ជូន និងចំណាយដែលទាក់ទងដោយផ្ទាល់ផ្សេងៗ។

**កិច្ចបញ្ជិកាគណនេយ្យ÷**

ឥណពន្ធ គណនី សម្ភារ ឧបករណ៍ដឹកជញ្ជូន (លេខ ២១០៨១) ៤០ ០២០ ០០០ ០០០ រៀល

ឥណទាន គណនី ការឧបត្ថម្ភ និងអំណោយ (លេខ ៧៥..) ៤០ ០០០ ០០០ ០០០ រៀល

ឥណទាន គណនី អ្នកផ្គត់ផ្គង់ (លេខ ៤០០១) ២០ ០០០ ០០០ រៀល។

នៅពេលទូទាត់÷

ឥណពន្ធ គណនី អ្នកផ្គត់ផ្គង់ (លេខ ៤០០១) ២០ ០០០ ០០០ រៀល

ឥណទាន គណនី ធនាគារ (លេខ ១១..) ២០ ០០០ ០០០ រៀល។

## ៦.៥. ការដោះដូរទ្រព្យសកម្មរយៈពេលវែងជាមួយភាគីទីបី

រាជរដ្ឋាភិបាលកម្ពុជាអាចសម្រេចលើការដោះដូរទ្រព្យសកម្មរយៈពេលវែងចាស់ ជាមួយទ្រព្យសម្មរយៈពេលវែងថ្មី។ ការដោះដូរទ្រព្យសកម្មរយៈពេលវែងជាមួយភាគីទីបី តម្រូវឱ្យការទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែងថ្មី និងលុបចោលតម្លៃយោងគណនេយ្យទ្រព្យសកម្មរយៈពេលវែងចាស់។ ការដោះដូរអាចធ្វើឱ្យមានចំណេញ ឬ ខាត ដោយផ្អែកលើការចរចារវាងភាគីពាក់ព័ន្ធ។ ប្រសិនបើតម្លៃទ្រព្យសកម្មរយៈពេលវែងថ្មី មានតម្លៃធំជាងតម្លៃយោងគណនេយ្យរបស់ទ្រព្យសកម្មរយៈពេលវែងចាស់ នោះរាជរដ្ឋាភិបាលចំណេញពីការដោះដូរ។ ផ្ទុយមកវិញ រាជរដ្ឋាភិបាលខាតពីការដោះដូរ ប្រសិនបើតម្លៃទ្រព្យសកម្មថ្មីមានតម្លៃទាបជាងតម្លៃយោងគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែងចាស់។

ឧទាហរណ៍ទី១÷ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចដោះដូរដី និងអគាររបស់ក្រសួង ក. ជាមួយក្រុមហ៊ុនឯកជន ក.ខ.គ. នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០X១។ ព័ត៌មានលម្អិតនៃការដោះដូរនេះ ត្រូវបានរៀបរាប់លម្អិតដូចខាងក្រោម÷

| ល.រ | បរិយាយ | តម្លៃ (លានរៀល) | សរុប (លានរៀល) |
|---|---|---|---|
| តារាងលម្អិតពីតម្លៃដី និងអគារចាស់របស់ក្រសួង ក. | | | |
| ១ | តម្លៃយោងគណនេយ្យនៅក្នុងបញ្ជីរបស់ដីចាស់របស់ក្រសួង ក. | | ៦ ០០០ |
| ២ | តម្លៃទីផ្សារក្រោយការវាយតម្លៃ | | ៨ ០០០ |
| ៣ | ចំណេញ/ (ខាត) ពីការវាយតម្លៃឡើងវិញ | | ២ ០០០ |
| ៤ | តម្លៃអគារចាស់របស់ក្រសួង ក. | ១ ៦០០ | |
| ៥ | រំលស់បូកបន្តនៃអគារ | (៨០០) | |
| ៦ | តម្លៃយោងគណនេយ្យ | ៨០០ | ៨០០ |
| តារាងលម្អិតពីតម្លៃដី និងអគារថ្មីរបស់ក្រសួង ក. និងសាច់ប្រាក់ដែលទទួលបានពីការដោះដូរ | | | |
| ១ | តម្លៃដីថ្មី | | ៧ ៦០០ |
| ២ | តម្លៃអគារថ្មី | | ២ ០០០ |
| ៣ | សាច់ប្រាក់ដែលទទួលបាន | | ៤០០ |

**កិច្ចបញ្ជិកាគណនេយ្យ÷**

១. ការទទួលស្គាល់ចំណេញពីការវាយតម្លៃដីចាស់ឡើងវិញមុនការដោះដូរ

ឥណពន្ធ គណនី ដីធ្លី (លេខ ២១០១១) ២ ០០០ ០០០ ០០០ រៀល

ឥណទាន គណនី លំអៀងពីការវាយតម្លៃឡើងវិញអចលកម្ម(លេខ ៣០០២) ២ ០០០ ០០០ ០០០ រៀល។

២. ការទទួលស្គាល់តម្លៃដីថ្មី និងការលុបតម្លៃយោងគណនេយ្យដីចាស់

ឥណពន្ធ គណនី ដីធ្លី (លេខ ២១០១១) ៧ ៦០០ ០០០ ០០០ រៀល

ឥណពន្ធ គណនី តំលៃគណនេយ្យនៃចំណែកសកម្មបានលក់ (តំលៃនៅសល់) (លេខ ៦៧០៥១) ៤០០ ០០០ ០០០ រៀល

ឥណទាន គណនី ដីធ្លី (លេខ ២១០១១) ៨ ០០០ ០០០ ០០០ រៀល។

៣. ការទទួលស្គាល់តម្លៃអគារថ្មី និងការលុបតម្លៃយោងគណនេយ្យអគារចាស់

ឥណពន្ធ គណនី សំណង់អគារ (លេខ ២១០៣១) ២ ០០០ ០០០ ០០០ រៀល

ឥណពន្ធ គណនី រំលស់សំណង់អគារ (លេខ ២៨០៣១) ៨០០ ០០០ ០០០ រៀល

ឥណទាន គណនី ចំណូលពីការលក់អគារជម្រះបញ្ជីសារពើភណ្ឌ (លេខ ៧៧០៤១) ១ ២០០ ០០០ ០០០ រៀល

ឥណទាន គណនី សំណង់អគារ (លេខ ២១០៣១) ១ ៦០០ ០០០០ ០០០ រៀល។

៤. ការកត់ត្រាចំនួនទឹកប្រាក់ដែលបានទទួល និងការទទួលស្គាល់ជាចំណូលថវិកា

ឥណពន្ធ គណនី ធនាគារ (លេខ ១១..) ៤០០ ០០០ ០០០ រៀល

ឥណទាន គណនី ចំណូលបណ្តោះអាសន្ន (៤៧០៥) ៤០០ ០០០ ០០០ រៀល។

នៅពេលទទួលបានសាលាកបត្រដើម្បីទទួលស្គាល់ចំណូល÷

ឥណពន្ធ គណនី ចំណូលបណ្តោះអាសន្ន (៤៧០៥) ៤០០ ០០០ ០០០ រៀល

ឥណទាន គណនី ចំណូលពីការលក់អគារជម្រះបញ្ជីសារពើភណ្ឌ (លេខ ៧៧០៤១) ៤០០ ០០០ ០០០ រៀល។

**<u>ចំណាំ</u>**÷ ចំណេញសុទ្ធពីការដោះដូរ មានរៀបរាប់ដូចខាងក្រោម÷

| ល.រ | បរិយាយ | សរុប (លានរៀល) |
|---|---|---|
| ១ | ចំណេញពីការដោះដូរអគារ | ១ ២០០ |
| ២ | ចំណេញជាសាច់ប្រាក់ពីការដោះដូរ | ៤០០ |
| ៣ | ខាតពីការដោះដូរលើដី | (៤០០) |
| ៤ | ចំណេញសុទ្ធ | ១ ២០០ |

ឧទាហរណ៍ទី២÷ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានទិញម៉ូតូថ្មីមួយគ្រឿង ដោយដោះដូរជាមួយម៉ូតូចាស់។ ម៉ូតូថ្មីមានតម្លៃ១២ ០០០ ០០០ រៀល និងម៉ូតូចាស់មានតម្លៃយោងគណនេយ្យ ២ ៨០០ ០០០ រៀល ដោយមានថ្លៃដើម

៨ ៨០០ ០០០ រៀល និងរំលស់បូកបន្ត ៦ ០០០ ០០០ រៀល ប៉ុន្តែតាមរយៈការដោះដូរ ក្រុមហ៊ុនឯកជនតម្រូវឱ្យស្នងការនគរបាលរាជធានីភ្នំពេញ បង់ប្រាក់ចំនួន ១០ ០០០ ០០០ រៀល ជាថ្នូរនៃការដោះដូរដែលធ្វើឱ្យខាតអស់ទឹកប្រាក់ ៨០០ ០០០ រៀល។

**កិច្ចបញ្ជិកាគណនេយ្យ÷**

ឥណពន្ធ គណនី សម្ភារ ឧបករណ៍ដឹកជញ្ជូន (លេខ ២១០៨១) ១២ ០០០ ០០០ រៀល

ឥណពន្ធ គណនី រំលស់សម្ភារ ឧបករណ៍ដឹកជញ្ជូន (លេខ ២៨០៨១) ៦ ០០០ ០០០ រៀល

ឥណពន្ធ គណនី តំលៃគណនេយ្យនៃចំណែកសកម្មបានលក់ (តំលៃនៅសល់) (លេខ ៦៧០៥១) ៨០០ ០០០ រៀល

ឥណទាន គណនី សម្ភារ ឧបករណ៍ដឹកជញ្ជូន (លេខ ២១០៨១) ៨ ៨០០ ០០០ រៀល

ឥណទាន គណនី អ្នកផ្គត់ផ្គង់ (លេខ ៤០០១ ) ១០ ០០០ ០០០ រៀល។

នៅពេលទូទាត់÷

ឥណពន្ធ គណនី អ្នកផ្គត់ផ្គង់ (លេខ ៤០០១ ) ១០ ០០០ ០០០ រៀល

ឥណទាន គណនី ធនាគារ (លេខ ១០០១ ) ១០ ០០០ ០០០ រៀល។

**៦.៦.ការទទួលស្គាល់ទ្រព្យសកម្មដែលមិនទាន់បានទទួលស្គាល់ក្នុងការិយបរិច្ឆេទមុនៗ**

ជាគោលការណ៍ ទ្រព្យសកម្មរយៈពេលវែងដែលពុំទាន់បានទទួលស្គាល់ក្នុងការិយបរិច្ឆេទមុនៗ និងនៅមានតម្លៃជាសារវ័ន្ត និងអាចបន្តប្រើប្រាស់សម្រាប់ការិយបរិច្ឆេទខាងមុខតទៅទៀត ទ្រព្យសកម្មទាំងនោះត្រូវយកមកឆ្លុះបញ្ចាំងនៅក្នុងតារាងតុល្យការរបស់រដ្ឋ ដោយត្រូវប្រើប្រាស់គណនី ទាយជ្ជទាន សម្រាប់ការធ្វើសមាហរណកម្មទ្រព្យសកម្មទាំងនោះ។ វិធីសាស្ត្រដុល ត្រូវបានប្រើប្រាស់ដើម្បីអាចតាមដានពីតម្លៃដើមនៃទ្រព្យសកម្មរយៈពេលវែង និងរំលស់បូកបន្ត ក្នុងការកត់ត្រាតម្លៃយោងគណនេយ្យចូលក្នុងបញ្ជីឡើងវិញ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចចេញគោលការណ៍ណែនាំលម្អិតដាច់ដោយឡែក សម្រាប់ការទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែងដែលមិនទាន់បានទទួលស្គាល់ក្នុងការិយបរិច្ឆេទមុនៗ ទៅតាមលក្ខខណ្ឌតម្រូវ និងពេលវេលាសមស្រប។

ឧទាហរណ៍ ក្រសួងសាធារណការ និងដឹកជញ្ជូន បានទិញរថយន្តមួយគ្រឿងដែលមានតម្លៃ ២៤០ ០០០ ០០០ រៀល នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០X០ ដែលត្រូវបានកត់ត្រាជាចំណាយចរន្តក្នុងគណនី សម្ភារ និងឧបករណ៍ដឹកជញ្ជូន (លេខ ៦០០៥៤)។ នៅថ្ងៃ៣១ ខែធ្នូ ឆ្នាំ ២០X៥ រាជរដ្ឋាភិបាល តម្រូវឱ្យមានការវាយតម្លៃ និងធ្វើសមាហរណកម្មតម្លៃយោងគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែងដែលបំពេញតាមលក្ខខណ្ឌនៃការទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង។ នៅថ្ងៃទី០១ ខែមករា ឆ្នាំ ២០X៦ ក្រសួងសាធារណការនិងដឹកជញ្ជូន បានវាយតម្លៃអាយុកាលប្រើប្រាស់របស់រថយន្តចំនួន១០ ឆ្នាំ និងមានព័ត៌មានលម្អិតដូចមានរៀបរាប់ខាងក្រោម÷

| | |
|---|---|
| ថ្លៃដើមរថយន្តនៅថ្ងៃទី១ ខែមករា ឆ្នាំ២០X០ | ២៤០ ០០០ ០០០ រៀល |
| រំលស់បូកបន្ត (២៤០ ០០០ ០០០/១០) x ៥ | (១២០ ០០០ ០០០) រៀល |
| ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០X០-រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០X៥ | |
| តម្លៃយោងគណនេយ្យនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០X៦ | ១២០ ០០០ ០០០ រៀល |

**កិច្ចបញ្ជិកាគណនេយ្យ÷**

ឥណពន្ធ គណនី សម្ភារ ឧបករណ៍ដឹកជញ្ជូន (លេខ ២១០៨១) ២៤០ 0000 00 រៀល

ឥណទាន គណនី រំលស់សម្ភារ ឧបករណ៍ដឹកជញ្ជូន (លេខ ២៨០៨១) ១២០ 000 000 រៀល

ឥណទាន គណនី ទាយជ្ជទាន (លេខ ៣០០១) ១២០ 000 000 រៀល។

<u>**ចំណាំ**</u>÷ ដោយហេតុតែក្រសួងសាធារណការនិងដឹកជញ្ជូន បានចុះកិច្ចបញ្ជិកាគណនេយ្យលើថ្លៃដើមរថយន្តជាចំណាយចរន្តក្នុងការិយបរិច្ឆេទមុនៗរួចហើយ គណនី ទាយជ្ជទាន ត្រូវបានប្រើប្រាស់ដើម្បីកត់ត្រាតម្លៃយោងគណនេយ្យនៃរថយន្តចូលក្នុងបញ្ជីគណនេយ្យវិញ។

### ៦.៧. ចំណាយបន្តបន្ទាប់

#### ក. ចំណាយថែទាំនិងប្រតិបត្តិការ

ស្ថាប័នសាធារណៈត្រូវទទួលស្គាល់និងកត់ត្រាជាចំណាយថែទាំនិងប្រតិបត្តិការ នូវចំណាយទាំងឡាយណាដែលមិនបង្កើនអាយុកាលប្រើប្រាស់នៃទ្រព្យសកម្មរយៈពេលវែង និងមានតម្លៃតិចជាងតម្លៃអប្បបរមានៃការទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង។

ឧទាហរណ៍÷ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជួសជុលម៉ាស៊ីនភ្លើងអស់ទឹកប្រាក់ ចំនួន ១ ៤០០ 000 រៀល និងបានចាត់ថ្នាក់ចំណាយនេះជាចំណាយជួសជុល ដោយសារមុខសញ្ញាចំណាយនេះមិនបង្កើនអាយុកាលប្រើប្រាស់របស់ម៉ាស៊ីនភ្លើង និងចំណាយនេះមានតម្លៃទាបជាងតម្លៃអប្បបរមានៃការទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង។

**កិច្ចបញ្ជិកាគណនេយ្យ÷**

ឥណពន្ធ គណនី ថែទាំនិងជួសជុលសម្ភារ និងឧបករណ៍បច្ចេកទេស (លេខ ៦១០៥៧) ១ ៤០០ 000 រៀល

ឥណទាន គណនី អ្នកផ្គត់ផ្គង់ (លេខ ៤០០១) ១ ៤០០ 000 រៀល។

នៅពេលទូទាត់÷

ឥណពន្ធ គណនី អ្នកផ្គត់ផ្គង់ (លេខ ៤០០១) ១ ៤០០ 000 រៀល

ឥណទាន គណនី ធនាគារ (លេខ ១១..) ១ ៤០០ 000 រៀល។

#### ខ. ចំណាយមូលធន-ការកែលម្អ (រាប់បញ្ចូលទាំងការលុបចោលផ្នែកនៃទ្រព្យ)

ស្ថាប័នសាធារណៈត្រូវទទួលស្គាល់និងកត់ត្រាជាចំណាយមូលធន នូវចំណាយទាំងឡាយណាដែលបង្កើនអាយុកាលប្រើប្រាស់នៃទ្រព្យសកម្មបន្ថែមលើសពីរយៈពេល ១២ខែ និងមានតម្លៃស្មើ ឬ លើសតម្លៃអប្បបរមានៃការទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង។

ឧទាហរណ៍÷ ក្រសួងសុខាភិបាលផ្លាស់ប្តូរម៉ាស៊ីនត្រជាក់ខ្នាតធំថ្មី (Air Cooled Chiller) ចំនួន១គ្រឿង អស់ទឹកប្រាក់ចំនួន ២០ 000 000 រៀល។ តម្លៃយោងគណនេយ្យ (តម្លៃនៅសល់) របស់ម៉ាស៊ីនត្រជាក់ខ្នាតធំចាស់មានតម្លៃ ៤ 000 000 រៀល ដែលថ្លៃដើមមានចំនួន ១៥ 000 000 រៀល និងរំលស់បូកបន្តមានចំនួន ១១ 000 000 រៀល។

**កិច្ចបញ្ជិកាគណនេយ្យ÷**

ឥណពន្ធ គណនី សម្ភារ ឧបករណ៍ការិយាល័យ (លេខ ២១០៨២) ២០ ០០០ ០០០ រៀល

ឥណទាន គណនី អ្នកផ្គត់ផ្គង់ (លេខ ៤០០១) ២០ ០០០ ០០០ រៀល។

នៅពេលទូទាត់÷

ឥណពន្ធ គណនី អ្នកផ្គត់ផ្គង់ (លេខ ៤០០១) ២០ ០០០ ០០០ រៀល

ឥណទាន គណនី ធនាគារ (លេខ ១១..) ២០ ០០០ ០០០ រៀល។

**ការលុបតម្លៃយោងគណនេយ្យចេញពីបញ្ជីគណនេយ្យ÷**

ឥណពន្ធ គណនី តម្លៃគណនេយ្យនៃចំណែកទ្រព្យសកម្មដែលបានលក់ (លេខ ៦៧០៥១) ៤ ០០០ ០០០ រៀល

ឥណពន្ធ គណនី រំលស់សម្ភារ ឧបករណ៍ការិយាល័យ (លេខ ២៨០៨២) ១១ ០០០ ០០០ រៀល

ឥណទាន គណនី សម្ភារ ឧបករណ៍ការិយាល័យ (លេខ ២១០៨២) ១៥ ០០០ ០០០ រៀល ។

**គ. ការធ្វើឱ្យប្រសើរឡើង**

ឧទាហរណ៍÷ ក្រសួងសាធារណការនិងដឹកជញ្ជូន បានពង្រីកទ្រូងផ្លូវជាតិលេខ ៣ ចំណាយទឹកប្រាក់សរុបចំនួន ៤ ០០០ ០០០ ០០០ រៀល ប៉ុន្តែការពង្រីកនោះ ក្រសួងបានគាស់លូបង្ហូរទឹកចេញទាំងអស់ ដែលមានតម្លៃយោងគណនេយ្យ ចំនួន ៨០ ០០០ ០០០ រៀល (ថ្លៃដើម ១៦០ ០០០ ០០០ រៀល និងរំលស់បូកបន្តមានចំនួន ៨០ ០០០ ០០០ រៀល)។

**កិច្ចបញ្ជិកាគណនេយ្យ÷**

ឥណពន្ធ គណនី ផ្លូវថ្នល់ ផ្លូវទឹក (លេខ ២១០៤១) ៤ ០០០ ០០០ ០០០ រៀល

ឥណទាន គណនី អ្នកផ្គត់ផ្គង់ (លេខ ៤០០១) ៤ ០០០ ០០០ ០០០ រៀល។

នៅពេលទូទាត់÷

ឥណពន្ធ គណនី អ្នកផ្គត់ផ្គង់ (លេខ ៤០០១) ៤ ០០០ ០០០ ០០០ រៀល

ឥណទាន គណនី ធនាគារ (លេខ ១១..) ៤ ០០០ ០០០ ០០០ រៀល។

**ការលុបតម្លៃយោងគណនេយ្យចេញពីបញ្ជីគណនេយ្យ÷**

ឥណពន្ធ គណនី តម្លៃគណនេយ្យនៃចំណែកទ្រព្យសកម្មដែលបានលក់ (លេខ ៦៧០៥១) ៨០ ០០០ ០០០ រៀល

ឥណពន្ធ គណនី រំលស់លើបណ្តាញបង្ហូរទឹក និងអនាម័យ (លេខ ២៨០៤៧) ៨០ ០០០ ០០០ រៀល

ឥណទាន គណនី បណ្តាញបង្ហូរទឹក និងអនាម័យ (លេខ ២១០៤៧) ១៦០ ០០០ ០០០ រៀល។

## ជំពូកទី ៣
## រំលស់

### ១. គោលការណ៍រំលស់

តម្លៃដែលអាចរំលស់នៃទ្រព្យសកម្មរយៈពេលវែង គឺត្រូវរំលស់តាមមូលដ្ឋានដែលមានលក្ខណៈជាប្រព័ន្ធលើអាយុកាលប្រើប្រាស់របស់ទ្រព្យទាំងនោះ តាមវិធីសាស្ត្រមួយដែលឆ្លុះបញ្ចាំងពីគំរូនៃអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតរបស់ទ្រព្យសកម្មរយៈពេលវែងដែលត្រូវបានរំពឹងទុក ដើម្បីប្រើប្រាស់ដោយស្ថាប័នសាធារណៈ។

ការកំណត់អាយុកាលប្រើប្រាស់ត្រូវពិចារណាលើបទពិសោធន៍ជាក់ស្តែងរហូតដល់បច្ចុប្បន្នជាមួយនឹងការកែសម្រួលនានាដែលឆ្លុះបញ្ចាំងអំពីលទ្ធផលនៃការគ្រោងទុកពីការផ្លាស់ប្តូរបទពិសោធន៍ក្នុងការគ្រប់គ្រងទ្រព្យសកម្មរយៈពេលវែង និងកត្តាបរិស្ថាន។ វាពិតជាមានសារៈសំខាន់ក្នុងការប៉ាន់ប្រមាណអាយុកាលប្រើប្រាស់ឱ្យឆ្លុះបញ្ចាំងពីទិដ្ឋភាពពិត តាមតែអាចអនុវត្តបាន។

រំលស់ចាប់ផ្តើមនៅពេលដែលទ្រព្យសកម្មត្រូវបានដាក់ឱ្យដំណើរការ ឬ ប្រើប្រាស់ ដោយស្ថាប័នសាធារណៈ ឬ នៅពេលដែលទ្រព្យសកម្មរយៈពេលវែងនោះ ត្រូវបានទទួលស្គាល់ ដោយគណនេយ្យករសាធារណៈ (ក្រោយពីបានផ្ទេរពីទ្រព្យសកម្មកំពុងដំណើរការ) ដោយផ្អែកលើអាណត្តិបើកប្រាក់ទូទាត់ចំណាយ។

រំលស់សម្រាប់ការិយបរិច្ឆេទរាយការណ៍នីមួយៗ ត្រូវបានគណនារៀងរាល់ឆ្នាំ នៅចុងការិយបរិច្ឆេទរាយការណ៍ និងត្រូវទទួលស្គាល់ទៅក្នុងរបាយការណ៍ចំណូល ចំណាយ។ រំលស់សម្រាប់ការិយបរិច្ឆេទរាយការណ៍ ត្រូវបានគណនាតាមមូលដ្ឋានសមាមាត្រ នៅថ្ងៃដែលទ្រព្យសកម្មរយៈពេលវែងនោះត្រូវបានដាក់ឱ្យដំណើរការ ឬ ប្រើប្រាស់ ឬ ទទួលស្គាល់ដោយគណនេយ្យករសាធារណៈសម្រាប់ទ្រព្យសកម្មរយៈពេលវែងដែលត្រូវបានផ្ទេរពីទ្រព្យសកម្មកំពុងដំណើរការ។ សម្រាប់ការគណនាតាមមូលដ្ឋានសមាមាត្រ គឺ ១ឆ្នាំ មាន១២ខែ។ រំលស់ក្នុងខែនីមួយៗ ត្រូវទទួលស្គាល់មួយខែពេញ ដោយមិនគិតថាទ្រព្យសកម្មរយៈពេលវែង ត្រូវបានដាក់ឱ្យដំណើរការ ឬ ប្រើប្រាស់ នៅដើមខែ ពាក់កណ្តាលខែ ឬ ចុងខែឡើយ។

សម្រាប់ការលក់ ឬ ការលុបចេញពីបញ្ជីគណនេយ្យ គឺមិនត្រូវគិតរំលស់នៅក្នុងខែនោះទេ។

រំលស់មិនត្រូវបានអនុវត្តចំពោះទ្រព្យសកម្មអរូបី ដែលមិនអាចកំណត់អាយុកាលប្រើប្រាស់បាន។ រំលស់ក៏មិនអនុវត្តចំពោះទ្រព្យសកម្ម ដូចមានរៀបរាប់ក្នុងឧបសម្ព័ន្ធ១ នៃគោលការណ៍ណែនាំនេះ។

ក្នុងការកំណត់ពីអាយុកាលប្រើប្រាស់នៃទ្រព្យសកម្មរយៈពេលវែង ស្ថាប័នសាធារណៈត្រូវពិចារណាឱ្យបានល្អិតល្អន់លើចំណុចដូចខាងក្រោម÷

- វិធីសាស្ត្រដែលប្រើប្រាស់ក្នុងការផ្គូផ្គងពីគំរូនៃការប្រើប្រាស់អត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតរបស់ទ្រព្យសកម្ម
- នៅពេលដែលទ្រព្យសកម្មមានសមាសធាតុ ឬ ផ្នែកច្រើន ជាមួយនឹងគំរូនៃការប្រើប្រាស់ខុសគ្នា នោះសមាសធាតុ ឬ ផ្នែកទាំងនោះត្រូវរំលស់ដាច់ដោយឡែកពីគ្នា
- រំលស់ត្រូវបានគណនាតាមមូលដ្ឋានដែលមានលក្ខណៈជាប្រព័ន្ធលើអាយុកាលប្រើប្រាស់នៃទ្រព្យសកម្មរយៈពេលវែង
- តម្លៃកាកសំណល់ត្រូវបានកំណត់ដើម្បីធានាថា រំលស់ត្រូវបានបែងចែកលើតម្លៃដែលអាចរំលស់បាន។

តម្លៃកាកសំណល់ គឺត្រូវបានសន្មតថាស្មើសូន្យ ក្នុងករណីដែលតម្លៃកាកសំណល់នៃទ្រព្យសកម្មរយៈពេលវែងនោះ ពុំអាចកំណត់បាននៅក្នុងទីផ្សារសកម្ម។

វិធីសាស្ត្ររំលស់ថេរ ត្រូវបានអនុវត្តចំពោះថ្នាក់នីមួយៗនៃទ្រព្យសកម្មរយៈពេលវែង លើកលែងតែទ្រព្យដែលមិនត្រូវអនុវត្តរំលស់ ដូចមានភ្ជាប់មកនៅក្នុងឧបសម្ព័ន្ធ ១ នៃគោលការណ៍ណែនាំនេះ ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចចេញគោលការណ៍អនុវត្តរំលស់ ចំពោះទ្រព្យដែលមិនត្រូវបានអនុវត្តរំលស់ ទៅតាមលក្ខខណ្ឌតម្រូវ និងពេលវេលាសមស្រប។

## ២. ការត្រួតពិនិត្យឡើងវិញលើចំណាយរំលស់

ស្ថាប័នសាធារណៈ ត្រូវធ្វើការត្រួតពិនិត្យឡើងវិញលើធាតុចូលនានា ដើម្បីជាមូលដ្ឋានដល់ការគណនាចំណាយរំលស់។ ការត្រួតពិនិត្យឡើងវិញនេះ រាប់បញ្ចូលនូវការត្រួតពិនិត្យឡើងវិញលើការផ្លាស់ប្ដូរដូចខាងក្រោម÷

- អាយុកាលប្រើប្រាស់ (ផ្នែកដែលមានអាយុកាលប្រើប្រាស់ខ្លី និងផ្នែកដែលមានអាយុកាលវែង)
- គំរូនៃការប្រើប្រាស់។

## ៣. វិធីសាស្ត្ររំលស់

គ្រប់ប្រភេទនៃទ្រព្យសកម្មរយៈពេលវែងទាំងអស់ ត្រូវប្រើប្រាស់វិធីសាស្ត្ររំលស់ថេរទៅតាមអាយុកាលប្រើប្រាស់លើតម្លៃដែលអាចរំលស់បាន លើកលែងតែទ្រព្យដែលមិនអនុវត្តរំលស់ ដូចមានលម្អិតនៅក្នុងឧបសម្ព័ន្ធ ១ នៃគោលការណ៍ណែនាំនេះ។

រំលស់ ត្រូវបានគណនាតាមវិធីសាស្ត្រដូចខាងក្រោម÷

$$\text{រំលស់ក្នុងមួយឆ្នាំ} = \left(\frac{\text{ថ្លៃដើមនៃទ្រព្យសកម្ម} - \text{តម្លៃកាកសំណល់}}{\text{អាយុកាលប្រើប្រាស់}}\right)$$

$$\text{រំលស់ក្នុងមួយខែ} = \left(\frac{\text{រំលស់ក្នុងមួយឆ្នាំ}}{\text{១២ខែ}}\right)$$

$$\text{រំលស់សម្រាប់ការិយបរិច្ឆេទរាយការណ៍} = \text{រំលស់ក្នុងមួយខែ} \times \text{ចំនួនខែ}$$

## ៤. អាយុកាលប្រើប្រាស់

អាយុកាលប្រើប្រាស់នៃទ្រព្យសកម្មរយៈពេលវែង ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធ ១ នៃគោលការណ៍ណែនាំនេះ។

ក្នុងករណីដែលស្ថាប័នសាធារណៈមានតម្រូវការកំណត់អាយុកាលប្រើប្រាស់ផ្សេង ក្រៅពីការកំណត់អាយុកាលប្រើប្រាស់ដូចបានរៀបរាប់លម្អិតក្នុងឧបសម្ព័ន្ធ ១ នៃគោលការណ៍ណែនាំនេះ ស្ថាប័នសាធារណៈត្រូវស្នើសុំការអនុញ្ញាតជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ។

## ៥. ប្រតិបត្តិការតាមដីកាមិនមែនថវិកា សម្រាប់រំលស់

សម្រាប់ការអនុវត្តថវិកា រំលស់គឺជាប្រតិបត្តិការតាមដីកាមិនមែនថវិកា។ ប្រតិបត្តិការតាមដីកាមិនមែនថវិកា សម្រាប់រំលស់ មិនតម្រូវឱ្យមានការរៀបចំអាណត្តិបើកប្រាក់នោះទេ ប៉ុន្តែតម្រូវឱ្យស្ថាប័នសាធារណៈរៀបចំរបាយការណ៍ចំណាយរំលស់ទ្រព្យសកម្មរយៈពេលវែង ដែលបង្ហាញពីលេខកូដស្ថាប័នសាធារណៈ, ឈ្មោះស្ថាប័នសាធារណៈ, ឈ្មោះនិងអាសយដ្ឋានអង្គភាពគ្រប់គ្រង, មាតិកាគណនី, បរិយាយ, ទឹកប្រាក់រំលស់បូកបន្តសម្រាប់ការិយបរិច្ឆេទរាយការណ៍ ទៅតាមថ្នាក់នីមួយៗនៃទ្រព្យសកម្មរយៈពេលវែង ដូចមានគំរូភ្ជាប់មកជាមួយក្នុងឧបសម្ព័ន្ធ ៣ នៃគោលការណ៍ណែនាំនេះ។ របាយការណ៍ទាំងនោះត្រូវមានហត្ថលេខារបស់អ្នករៀបចំ, អ្នកត្រួតពិនិត្យ ឬ អនុញ្ញាតរបស់ស្ថាប័នសាធារណៈ លើកលែងតែមានគោលការណ៍ណែនាំដាច់ដោយឡែកដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងភ្ជាប់មកជាមួយនូវបញ្ជីទ្រព្យសកម្មរយៈពេលវែងរបស់ស្ថាប័នសាធារណៈ។

ស្ថាប័នសាធារណៈ ត្រូវបញ្ជូនរបាយការណ៍ចំណាយរំលស់ទ្រព្យសកម្មរយៈពេលវែងទៅគណនេយ្យករសាធារណៈ ដើម្បីពិនិត្យ និងអនុវត្តមុខងារបន្ត។ គណនេយ្យករសាធារណៈ អាចបញ្ជូនរបាយការណ៍ចំណាយរំលស់ទ្រព្យសកម្មរយៈពេលវែងទៅស្ថាប័នសាធារណៈវិញ ដើម្បីកែតម្រូវ ក្នុងករណីពិនិត្យឃើញថា ពុំទាន់មានលក្ខណៈត្រឹមត្រូវ។ ក្នុងករណីពិនិត្យឃើញថាត្រឹមត្រូវហើយ គណនេយ្យករសាធារណៈត្រូវអនុវត្តមុខការបន្ត។

របាយការណ៍ចំណាយរំលស់ទ្រព្យសកម្មរយៈពេលវែងដែលមានទម្រង់ដូចមានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ ៣ នៃគោលការណ៍ណែនាំនេះ ត្រូវបញ្ជូនមកគណនេយ្យករសាធារណៈ យ៉ាងយូរត្រឹមថ្ងៃទី២៨ ខែកុម្ភៈ នៃឆ្នាំបន្ទាប់។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចចេញគោលការណ៍ណែនាំលម្អិតបន្ថែមអំពីនីតិវិធីនៃការកត់ត្រាសម្រាប់ប្រតិបត្តិការចំណាយរំលស់ទ្រព្យសកម្មរយៈពេលវែង នៅពេលអនុវត្តកិច្ចបញ្ជិការរំលស់នៃទ្រព្យសកម្មរយៈពេលវែង ក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)។

## ៦. គណនេយ្យកម្មសម្រាប់រំលស់

### ឧទាហរណ៍ទី១÷ រំលស់ផ្លូវ

ក្រសួងសាធារណការនិងដឹកជញ្ជូនសាងសង់ផ្លូវលេខ៥៥ ដោយចំណាយអស់ទឹកប្រាក់ចំនួន ៤ ៥០០ ០០០ ០០០ រៀល។ ផ្លូវលេខ៥៥នេះ ត្រូវបានបញ្ចប់ជាស្ថាពរ និងត្រូវបានទទួលស្គាល់ជាទ្រព្យសកម្មរយៈពេលវែងដោយគណនេយ្យករសាធារណៈ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០x១។ អាយុកាលប្រើប្រាស់ផ្លូវ មានរយៈពេល៣០ឆ្នាំ និងមានតម្លៃកាកសំណល់ស្មើសូន្យ ព្រមទាំងប្រើប្រាស់វិធីសាស្ត្ររំលស់ថេរសម្រាប់ការគិតរំលស់។

$$\text{រំលស់ផ្លូវក្នុងមួយឆ្នាំ} = \frac{\text{៤ ៥០០ ០០០ ០០០} - \text{០}}{\text{៣០}} = \text{១៥០ ០០០ ០០០ រៀល}$$

$$\text{រំលស់ផ្លូវក្នុងមួយខែ} = \frac{\text{១៥០ ០០០ ០០០}}{\text{១២}} = \text{១២ ៥០០ ០០០ រៀល}$$

រំលស់ផ្លូវសម្រាប់ការិយបរិច្ឆេទរាយការណ៍ = ១២ ៥០០ ០០០ រៀល x ០៦ ខែ = ៧៥ ០០០ ០០០ រៀល

**កិច្ចបញ្ជិកាគណនេយ្យ÷**

ឥណពន្ធ គណនី ទាយជ្ជទានឱ្យដល់រំលស់អចលកម្មរូបី (លេខ ៦៨០១២) ៧៥ ០០០ ០០០ រៀល

ឥណទាន គណនី រំលស់ផ្លូវថ្នល់ (លេខ ២៨០៤១) ៧៥ ០០០ ០០០ រៀល ។

**ឧទាហរណ៍ទី២÷ រំលស់រថយន្ត**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទិញរថយន្ត១គ្រឿងអស់ទឹកប្រាក់ចំនួន ២៦០ ០០០ ០០០ រៀល នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០x១។ រថយន្តមានអាយុកាលប្រើប្រាស់ ៥ឆ្នាំ និងមានតម្លៃកាកសំណល់ចំនួន ២០ ០០០ ០០០ រៀល ព្រមទាំងប្រើប្រាស់វិធីសាស្ត្ររំលស់ថេរសម្រាប់ការគិតរំលស់។

រំលស់រថយន្តក្នុងមួយឆ្នាំ $= \frac{\text{២៦០ ០០០ ០០០} - \text{២០ ០០០ ០០០}}{\text{៥}} =$ ៤៨ ០០០ ០០០ រៀល

រំលស់រថយន្តក្នុងមួយខែ $= \frac{\text{៤៨ ០០០ ០០០}}{\text{១២}} =$ ៤ ០០០ ០០០ រៀល

រំលស់រថយន្តសម្រាប់ការិយបរិច្ឆេទរាយការណ៍ = ៤ ០០០ ០០០ រៀល x ១០ ខែ = ៤០ ០០០ ០០០ រៀល

**កិច្ចបញ្ជិកាគណនេយ្យ÷**

ឥណពន្ធ គណនី ទាយជ្ជទានឱ្យដល់រំលស់អចលកម្មរូបី (លេខ ៦៨០១២) ៤០ ០០០ ០០០ រៀល

ឥណទាន គណនី សម្ភារ ឧបករណ៍ដឹកជញ្ជូន (លេខ ២៨០៨១) ៤០ ០០០ ០០០ រៀល។

## ជំពូកទី ៤

## ការលក់ ឬ ការលុបចេញពីបញ្ជីគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែង

### ១. ការឈប់ទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង

តម្លៃយោងគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែង ត្រូវបានឈប់ទទួលស្គាល់នៅពេលដែលទ្រព្យនោះត្រូវបានលក់ ឬ គ្មានអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត។ ការលក់ ឬ ការលុបចេញពីបញ្ជីគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែង អាចកើតឡើងតាមរូបភាពដូចខាងក្រោម៖

- ការលក់ ឬ ការបាត់បង់ ឬ ការខូចខាតទ្រព្យសកម្មរយៈពេលវែង
- ការបរិច្ចាគ
- ការរុះរើ ឬ បំផ្លាញទ្រព្យចោល
- ការផ្លាស់ប្តូរផ្នែកណាមួយ ឬ កម្មវិធីកែលម្អទ្រព្យសកម្មរយៈពេលវែង។

នៅពេលដែលលក់ ឬ លុបចេញពីបញ្ជីគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែង តម្លៃយោងគណនេយ្យនៃផ្នែក ឬ គ្រឿងបន្លាស់នានាដែលត្រូវបានផ្លាស់ប្តូរ ឬ ជំនួស អាចត្រូវលុបចេញពីបញ្ជីគណនេយ្យ ក្នុងករណីដែលអាចវាស់វែងបានដោយដាក់លាក់ពីតម្លៃយោងគណនេយ្យនៃផ្នែក ឬ គ្រឿងបន្លាស់ដែលត្រូវបានផ្លាស់ប្តូរ ឬ ជំនួស។

ចំណេញ ឬ ខាតដែលកើតឡើងពីការឈប់ទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង ត្រូវបានកំណត់ជាភាពខុសគ្នានៃប្រាក់ដែលទទួលបានពីការលក់សុទ្ធ និងតម្លៃយោងគណនេយ្យនៃទ្រព្យនោះ។

ចំណេញ ឬ ខាតដែលកើតឡើងពីការឈប់ទទួលស្គាល់នៃទ្រព្យសកម្មរយៈពេលវែង ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ចំណូល ចំណាយ នៅពេលដែលទ្រព្យនោះត្រូវបានឈប់ទទួលស្គាល់។

### ២. គណនេយ្យកម្មសម្រាប់ការលក់ ឬ ការលុបចេញពីបញ្ជីគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែង

#### ក. ការលក់ទ្រព្យសកម្មរយៈពេលវែង

ឧទាហរណ៍៖ការលក់រថយន្ត

ក្រសួងអប់រំ យុវជន និងកីឡាលក់រថយន្តមួយគ្រឿង ដែលមានតម្លៃយោងគណនេយ្យក្នុងបញ្ជីចំនួន ១០ ០០០ ០០០ រៀល ដោយមានថ្លៃដើម ១០០ ០០០ ០០០ រៀល និងរំលស់បូកបន្ត ៩០ ០០០ ០០០ រៀល។ រថយន្តនេះ ត្រូវបានលក់ក្នុងតម្លៃ ១៥ ០០០ ០០០ រៀល។

**កិច្ចបញ្ជិកាគណនេយ្យ៖**

ក. ចំណូលពីការលក់

ឥណពន្ធ គណនី ធនាគារ (លេខ ១១..) ១៥ ០០០ ០០០ រៀល

ឥណទាន គណនី ចំណូលពីការលក់រថយន្ត (លេខ ៧៧០៥២) ១៥ ០០០ ០០០ រៀល។



ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ខ. លេខនាសម្រាប់ជម្រះតម្លៃយោងគណនេយ្យ

ឥណពន្ធ គណនី រំលស់សម្ភារ ឧបករណ៍ដឹកជញ្ជូន (លេខ ២៨០៨១) ៩០ ០០០ ០០០ រៀល

ឥណពន្ធ គណនី តម្លៃគណនេយ្យនៃចំណែកសកម្មដែលបានលក់ (លេខ ៦៧០៥១) ១០ ០០០ ០០០ រៀល

ឥណទាន គណនី សម្ភារ ឧបករណ៍ដឹកជញ្ជូន (លេខ ២១០៨១) ១០០ ០០០ ០០០ រៀល។

ឧទាហរណ៍÷ ការលក់ម៉ូតូ

ក្រសួងអភិវឌ្ឍន៍ជនបទ បានលក់ម៉ូតូមួយគ្រឿង ដែលមានតម្លៃយោងគណនេយ្យ ២ ៨០០ ០០០ រៀល ដោយមានថ្លៃដើម ៨ ៨០០ ០០០ រៀល និងរំលស់បូកបន្ត ៦ ០០០ ០០០ រៀល។ ម៉ូតូនោះ ត្រូវបានលក់ចេញក្នុងតម្លៃត្រឹមតែ ២ ០០០ ០០០ រៀល ប៉ុណ្ណោះ ជាហេតុធ្វើឱ្យក្រសួងអភិវឌ្ឍន៍ជនបទខាតអស់ ចំនួន ៨០០ ០០០ រៀល។

**កិច្ចបញ្ជិកាគណនេយ្យ÷**

ក. កត់ត្រាចំណូលពីការលក់

ឥណពន្ធ គណនី ធនាគារ (លេខ ១១..) ២ ០០០ ០០០ រៀល

ឥណទាន គណនី ចំណូលពីការលក់រថយន្ត (លេខ ៧៧០៥២) ២ ០០០ ០០០ រៀល។

ខ. លេខនាសម្រាប់ជម្រះតម្លៃយោងគណនេយ្យ

ឥណពន្ធ គណនី រំលស់សម្ភារ ឧបករណ៍ដឹកជញ្ជូន (លេខ ២៨០៨១) ៦ ០០០ ០០០ រៀល

ឥណពន្ធ គណនី តម្លៃគណនេយ្យនៃចំណែកសកម្មដែលបានលក់ (លេខ ៦៧០៥១) ២ ៨០០ ០០០ រៀល

ឥណទាន គណនី សម្ភារ ឧបករណ៍ដឹកជញ្ជូន (លេខ ២១០៨១) ៨ ៨០០ ០០០ រៀល។

**ខ. ការលុបចេញពីបញ្ជីគណនេយ្យ**

ឧទាហរណ៍÷ ការលុបតម្លៃយោងគណនេយ្យនៃអគារ

អគ្គនាយដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រេចចិត្តសាងសង់អគារថ្មីសម្រាប់បុគ្គលិកធ្វើការលើទីតាំងអគារចាស់។ តម្លៃយោងគណនេយ្យនៃអគារចាស់មានតម្លៃ ១០០ ០០០ ០០០ រៀល ដែលត្រូវលុបចេញពីបញ្ជីគណនេយ្យដើម្បីសាងសង់អគារថ្មី ដោយថ្លៃដើមមានចំនួន ៩០០ ០០០ ០០០ រៀល និងរំលស់បូកបន្តមានចំនួន ៨០០ ០០០ ០០០ រៀល។

**កិច្ចបញ្ជិកាគណនេយ្យ÷**

ឥណពន្ធ គណនី រំលស់សំណង់អគារ (លេខ ២៨០៣១) ៨០០ ០០០ ០០០ រៀល

ឥណពន្ធ គណនី តម្លៃគណនេយ្យនៃចំណែកសកម្មដែលបានលក់ (លេខ ៦៧០៥១) ១០០ ០០០ ០០០ រៀល

ឥណទាន គណនី សំណង់អគារ (លេខ ២១០៣១) ៩០០ ០០០ ០០០ រៀល។

## ជំពូកទី ៥
## ការត្រួតពិនិត្យផ្ទៃក្នុងពាក់ព័ន្ធនឹងទ្រព្យសកម្មរយៈពេលវែង

ការត្រួតពិនិត្យផ្ទៃក្នុងពាក់ព័ន្ធនឹងទ្រព្យសកម្មរយៈពេលវែង គួរត្រូវបានអភិវឌ្ឍ និងថែរក្សា ដើម្បីធានាពីភាពគ្រប់ជ្រុងជ្រោយ និងភាពត្រឹមត្រូវនៃបញ្ជីទ្រព្យសកម្មរយៈពេលវែង និងអត្ថិភាពនៃទ្រព្យសកម្មរយៈពេលវែង។

ការត្រួតពិនិត្យផ្ទៃក្នុងពាក់ព័ន្ធនឹងទ្រព្យសកម្មរយៈពេលវែងអាចមានច្រើនជាងនេះ ប៉ុន្តែការត្រួតពិនិត្យផ្ទៃក្នុងពាក់ព័ន្ធនឹងទ្រព្យសកម្មរយៈពេលវែងរបស់ស្ថាប័នសាធារណៈត្រូវមានយ៉ាងហោចណាស់នូវចំណុចដូចខាងក្រោម÷

### ១. ការត្រួតពិនិត្យផ្ទៃក្នុង

#### ក. ការរាប់

ជាគោលការណ៍ ស្ថាប័នសាធារណៈត្រូវទទួលខុសត្រូវក្នុងការរាប់ទ្រព្យសកម្មរយៈពេលវែងទាំងអស់ ដែលស្ថិតក្នុងការគ្រប់គ្រងរបស់ខ្លួន។ ទ្រព្យសកម្មមួយចំនួនមិនតម្រូវឱ្យរាប់នោះទេ ដូចជាទ្រព្យជាហេដ្ឋារចនាសម្ព័ន្ធ ដោយសារតែទ្រព្យទាំងនោះមិនអាចចល័ត ឬ ប្តូរទីតាំងចេញបាន។ ប៉ុន្តែស្ថាប័នសាធារណៈត្រូវធ្វើការត្រួតពិនិត្យជាប្រចាំ ដើម្បីធានាដល់ប្រសិទ្ធភាពនៃការគ្រប់គ្រងទ្រព្យសកម្មទាំងនោះ។

ទ្រព្យសកម្មរយៈពេលវែង ក្រៅពីទ្រព្យខាងលើនេះ គឺតម្រូវឱ្យមានដំណើរការរាប់ និងត្រួតពិនិត្យជារៀងរាល់ឆ្នាំ និងត្រូវគោរពតាមលិខិតបទដ្ឋានគតិយុត្តិនានា ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ។

| ចំណាត់ថ្នាក់ទ្រព្យសកម្មរយៈពេលវែង | ប្រភេទនៃថ្នាក់ | ប្រភេទនៃការរាប់ | វដ្តជុំ |
|---|---|---|---|
| ស្នាដៃសិល្បៈនិងការប្រមូល(សន្សំ) និងទ្រព្យសម្បត្តិបេតិកភណ្ឌ | ទាំងអស់ | រៀងរាល់ឆ្នាំ | ១ ឆ្នាំ |
| សព្វាវុធយោធា | ទាំងអស់ | រៀងរាល់ឆ្នាំ | ១ ឆ្នាំ |
| ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន | ទាំងអស់ | រៀងរាល់ឆ្នាំ | ១ ឆ្នាំ |
| គ្រឿងចក្រ និងឧបករណ៍ | ទាំងអស់ | រៀងរាល់ឆ្នាំ | ១ ឆ្នាំ |
| សម្ភារ ឧបករណ៍ដឹកជញ្ជូន | ទាំងអស់ | រៀងរាល់ឆ្នាំ | ១ ឆ្នាំ |
| អគារ | ទាំងអស់ | រៀងរាល់ឆ្នាំ | ១ ឆ្នាំ |
| សម្ភារ ឧបករណ៍ការិយាល័យ | ទាំងអស់ | រៀងរាល់ឆ្នាំ | ១ ឆ្នាំ |
| សម្ភារ ព័ត៌មានវិទ្យា និងទូរគមនាគមន៍ | ទាំងអស់ | រៀងរាល់ឆ្នាំ | ១ ឆ្នាំ |
| គ្រឿងសង្ហារឹម និងបរិក្ខារបំពាក់ | ទាំងអស់ | រៀងរាល់ឆ្នាំ | ១ ឆ្នាំ |
| អចលកម្មរូបីផ្សេងៗ | ទាំងអស់ | រៀងរាល់ឆ្នាំ | ១ ឆ្នាំ |

### ខ. ការភ្ជាប់លេខសម្គាល់

ទ្រព្យសកម្មរយៈពេលវែងទាំងអស់ ត្រូវតែមានភ្ជាប់លេខអត្តសញ្ញាណសម្រាប់សម្គាល់ និងត្រូវបិទភ្ជាប់នឹងទ្រព្យសកម្មនោះ លើកលែងតែមិនអាចអនុវត្តបាន។ គំរូនៃលេខអត្តសញ្ញាណត្រូវអនុវត្តតាមជំពូកទី២ ផ្នែកទី១ ចំណុច២ អំពីលេខអត្តសញ្ញាណនៃទ្រព្យសកម្មរយៈពេលវែង។

## ២. ទំនាក់ទំនងជាមួយនឹងបញ្ជីទ្រព្យសកម្មរយៈពេលវែង

ដើម្បីធានាពីភាពគ្រប់ជ្រុងជ្រោយ និងភាពត្រឹមត្រូវនៃបញ្ជីទ្រព្យសកម្មរយៈពេលវែង ស្ថាប័នសាធារណៈ ត្រូវបង្កើតនិងចងក្រងឯកសារពាក់ព័ន្ធ ក៏ដូចជាចាត់វិធានការសមស្របដើម្បីធានាពីភាពគ្រប់ជ្រុងជ្រោយនៃបញ្ជីទ្រព្យសកម្មរយៈពេលវែង។

ស្ថាប័នសាធារណៈ ត្រូវបញ្ជូនបញ្ជីទ្រព្យសកម្មរយៈពេលវែង មកគណនេយ្យករសាធារណៈ យ៉ាងយូរត្រឹមថ្ងៃទី២៨ ខែកុម្ភៈ នៃឆ្នាំបន្ទាប់។

គណនេយ្យករសាធារណៈ ត្រូវផ្ទៀងផ្ទាត់បញ្ជីទ្រព្យសកម្មរយៈពេលវែង ជាមួយនឹងសមតុល្យគណនីទ្រព្យសកម្មរយៈពេលវែងដែលត្រូវបានកត់ត្រានៅក្នុងប្រព័ន្ធ និងបានរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនៅចុងការិយបរិច្ឆេទ។

ឧបសម្ព័ន្ធ ១÷តារាងចំណាត់ថ្នាក់ តម្លៃអប្បបរមានៃការទទួលស្គាល់ អាយុកាលប្រើប្រាស់ និងវិធីសាស្ត្ររំលស់នៃទ្រព្យសកម្មរយៈពេលវែង

| ផ្នែក | លេខក្រុម | ក្រុម | លេខថ្នាក់ | ថ្នាក់ | លេខប្រភេទ | ប្រភេទទ្រព្យសកម្ម | មាតិកាគណនី | វិធីសាស្ត្រវាយតម្លៃ | តម្លៃអប្បបរមានៃការទទួលស្គាល់ | អាយុកាលប្រើប្រាស់គិតជាឆ្នាំ (សម្រាប់គិតរំលស់) | វិធីសាស្ត្ររំលស់ |
|---|---|---|---|---|---|---|---|---|---|---|---|
| ១÷ ផ្នែកទី១÷ ទ្រព្យសកម្មអរូបី | | | | | | | | | | | |
| | 0១ | ទ្រព្យសកម្មអរូបី | | | | | | | | | |
| | | | 0១ | ប្រកាសនីយបត្រ អាជ្ញាបណ្ណ | | | | | | | |
| | | | | | 0១ | ប្រកាសនីយបត្រ | 20051 | ថ្លៃដើម | ៨ លានរៀល | >=២ | រំលស់ថេរ |
| | | | | | 0២ | អាជ្ញាបណ្ណ | 20052 | ថ្លៃដើម | ៨ លានរៀល | >=២ | រំលស់ថេរ |
| | | | 0២ | កម្មសិទ្ធិបញ្ញា ឬ សិទ្ធិប្រហាក់ប្រហែល | | | | | | | |
| | | | | | 0១ | កម្មសិទ្ធិបញ្ញា | 20053 | ថ្លៃដើម | ៨ លានរៀល | >=២ | រំលស់ថេរ |
| | | | | | 0២ | សិទ្ធិលើទ្រព្យសកម្មឧស្សាហកម្ម | 20053 | ថ្លៃដើម | ៨ លានរៀល | >=២ | រំលស់ថេរ |
| | | | | | 0៣ | សិទ្ធិធ្វើប្រតិបត្តិការអាជីវកម្ម | 20053 | ថ្លៃដើម | ៨ លានរៀល | >=២ | រំលស់ថេរ |
| | | | | | 0៤ | ម៉ាកសញ្ញាពាណិជ្ជកម្ម | 20053 | ថ្លៃដើម | ៨ លានរៀល | >=២ | រំលស់ថេរ |
| | | | | | 0៥ | ចំណងជើងបោះពុម្ពផ្សាយ | 20053 | ថ្លៃដើម | ៨ លានរៀល | >=២ | រំលស់ថេរ |
| | | | | | 0៦ | សិទ្ធិផ្សព្វផ្សាយ | 20053 | ថ្លៃដើម | ៨ លានរៀល | >=២ | រំលស់ថេរ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ០៧ | ផ្សេងៗ | 20053 | ថ្ងៃដើម | ៨ លានរៀល | >=២ | រំលស់ថេរ |
| | | | ០៣ | កម្មវិធីកុំព្យូទ័រ | | | | | | | |
| | | | | | ០១ | កម្មវិធីកុំព្យូទ័រ | 20054 | ថ្ងៃដើម | ៨ លានរៀល | >=២ | រំលស់ថេរ |
| | | | ០៤ | ក្បួនធ្វើម្ហូប រូបមន្ត ការរចនា និងគំរូ | | | | | | | |
| | | | | | ០១ | ក្បួនធ្វើម្ហូប | 20058 | ថ្ងៃដើម | ៨ លានរៀល | >=២ | រំលស់ថេរ |
| | | | | | ០២ | រូបមន្ត | 20058 | ថ្ងៃដើម | ៨ លានរៀល | >=២ | រំលស់ថេរ |
| | | | | | ០៣ | ការរចនា, គួរប្លង់ | 20058 | ថ្ងៃដើម | ៨ លានរៀល | >=២ | រំលស់ថេរ |
| | | | | | ០៤ | គំរូ | 20058 | ថ្ងៃដើម | ៨ លានរៀល | >=២ | រំលស់ថេរ |
| | | | | | ០៥ | ផ្សេងៗ | 20058 | ថ្ងៃដើម | ៨ លានរៀល | >=២ | រំលស់ថេរ |
| | | | ០៥ | ទ្រព្យសកម្មអរូបីផ្សេងៗ | | | | | | | |
| | | | | | ០១ | ទ្រព្យសកម្មអរូបីផ្សេងៗ | 20058 | ថ្ងៃដើម | ៨ លានរៀល | >=២ | រំលស់ថេរ |
| **២÷ផ្នែកទី២÷ ទ្រព្យសកម្មរូបី** | | | | | | | | | | | |
| | ០១ | ដី | | | | | | | | | |
| | | | ០១ | ដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិផ្សេងៗ | | | | | | | |
| | | | | | ០១ | ដីធ្លី | 21011 | ថ្ងៃដើម | ១ រៀល | មិនអនុវត្ត | មិនអនុវត្ត |
| | | | | | ០២ | ដីរ៉ែ | 21012 | ថ្ងៃដើម | ១ រៀល | មិនអនុវត្ត | មិនអនុវត្ត |
| | | | | | ០៣ | ដីឧទ្យាន និងដីបម្រុងទុក | 21018 | ថ្ងៃដើម | ១ រៀល | មិនអនុវត្ត | មិនអនុវត្ត |
| | | | | | ០៤ | ផ្សេងៗ | 21018 | ថ្ងៃដើម | ១ រៀល | មិនអនុវត្ត | មិនអនុវត្ត |
| | | | ០២ | ការកែលម្អលើដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិផ្សេងៗ | | | | | | | |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ០១ | ការកែលម្អលើដីធ្លី | 21021 | ថ្លៃដើម | ២០ លានរៀល | ៥-៥០ | រំលស់ថេរ |
| | | | | | ០២ | ការកែលម្អដីរ៉ៃ | 21022 | ថ្លៃដើម | ២០ លានរៀល | ៥-៥០ | រំលស់ថេរ |
| | | | | | ០៣ | ផ្សេងៗ | 21028 | ថ្លៃដើម | ២០ លានរៀល | ៥-៥០ | រំលស់ថេរ |
| | ០២ | អគារ | | | | | | | | | |
| | | | ០១ | អគារ | | | | | | | |
| | | | | | ០១ | អគាររដ្ឋបាល | 21031 | ថ្លៃដើម | ២០ លានរៀល | ៥-៥០ | រំលស់ថេរ |
| | | | | | ០២ | អគារស្នាក់នៅ | 21031 | ថ្លៃដើម | ២០ លានរៀល | ៥-៥០ | រំលស់ថេរ |
| | | | | | ០៣ | ផ្សេងៗ | 21031 | ថ្លៃដើម | ២០ លានរៀល | ៥-៥០ | រំលស់ថេរ |
| | | | ០២ | ការកែលម្អលើអគារ | | | | | | | |
| | | | | | ០១ | ការកែលម្អលើអគារ | 21032 | ថ្លៃដើម | ២០ លានរៀល | ៥-៥០ | រំលស់ថេរ |
| | | | ០៣ | សំណង់ផ្សេងៗ | | | | | | | |
| | | | | | ០១ | ទ្រព្យសកម្មសម្រាប់សកម្មភាពកំសាន្ត | 21038 | ថ្លៃដើម | ២០ លានរៀល | ៥-៥០ | រំលស់ថេរ |
| | | | | | ០២ | ជញ្ជាំងទប់ដី | 21038 | ថ្លៃដើម | ២០ លានរៀល | ៥-៥០ | រំលស់ថេរ |
| | | | | | ០៣ | សាលកីឡា ឬ ទីកន្លែងហ្វឹកហាត់ផ្សេងៗ | 21038 | ថ្លៃដើម | ២០ លានរៀល | ៥-៥០ | រំលស់ថេរ |
| | | | | | ០៤ | កន្លែងចតឡាន | 21038 | ថ្លៃដើម | ៤ លានរៀល | ៥-៥០ | រំលស់ថេរ |
| | | | | | ០៥ | ផ្សេងៗ | 21038 | ថ្លៃដើម | ៤ លានរៀល | ៥-៥០ | រំលស់ថេរ |
| | ០៣ | ហេដ្ឋារចនាសម្ព័ន្ធ | | | | | | | | | |
| | | | ០១ | ហេដ្ឋារចនាសម្ព័ន្ធផ្លូវ ថ្នល់ | | | | | | | |
| | | | | | ០១ | ផ្លូវល្បឿនលឿន | 21041 | ថ្លៃដើម | ៤០ លានរៀល | ២០-៥០ | រំលស់ថេរ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | ០២ | ផ្លូវជាតិ | 21041 | ថ្លៃដើម | ៤០ លានរៀល | ៣-៥០ | រំលស់ថេរ |
| | | | | | ០៣ | ផ្លូវខេត្ត | 21041 | ថ្លៃដើម | ៤០ លានរៀល | ២-៥០ | រំលស់ថេរ |
| | | | | | ០៤ | ផ្លូវជនបទ | 21041 | ថ្លៃដើម | ៤០ លានរៀល | ២-៥០ | រំលស់ថេរ |
| | | | | | ០៥ | ផ្លូវក្នុងទីប្រជុំជន | 21041 | ថ្លៃដើម | ៤០ លានរៀល | ២-៥០ | រំលស់ថេរ |
| | | | | | ០៦ | ស្ពានជាប់ផ្លូវ ឬ ស្ពានថ្មល់ | 21041 | ថ្លៃដើម | ៤០ លានរៀល | ១០-៥០ | រំលស់ថេរ |
| | | | | | ០៧ | ផ្លូវក្រោមដី | 21041 | ថ្លៃដើម | ៤០ លានរៀល | ១០-៥០ | រំលស់ថេរ |
| | | | | | ០៨ | ផ្លូវផ្សេងៗ | 21041 | ថ្លៃដើម | ៤០ លានរៀល | ៣-១០ | រំលស់ថេរ |
| | | | | | ០៩ | ចិញ្ចើមផ្លូវ | 21041 | ថ្លៃដើម | ៤០ លានរៀល | ២-១០ | រំលស់ថេរ |
| | | | | | ១០ | ផ្លាកនិងភ្លើងសញ្ញាចរាចរណ៍ | 21041 | ថ្លៃដើម | ៤០ លានរៀល | ២-៥ | រំលស់ថេរ |
| | | | | | ១១ | ឧបករណ៍គ្រប់គ្រងចរាចរណ៍ | 21041 | ថ្លៃដើម | ៤០ លានរៀល | ២-៥ | រំលស់ថេរ |
| | | | | | ១២ | របាំងលូ លូ និងលូកាត់ផ្លូវ (របាំងចែកទ្រូងផ្លូវ) | 21041 | ថ្លៃដើម | ៤០ លានរៀល | ២-៥ | រំលស់ថេរ |
| | | | | | ១៣ | អណ្តូងលូ | 21041 | ថ្លៃដើម | ៤០ លានរៀល | ២-១០ | រំលស់ថេរ |
| | | | | | ១៤ | បង្គោលភ្លើង និងអំពូលភ្លើងបំភ្លឺផ្លូវសាធារណៈ | 21041 | ថ្លៃដើម | ៤០ លានរៀល | ២-១០ | រំលស់ថេរ |
| | | | | | ១៥ | ផ្សេងៗ | 21041 | ថ្លៃដើម | ៤០ លានរៀល | ២-៥ | រំលស់ថេរ |
| | | | ០២ | ស្ពាន | | | | | | | |
| | | | | | ០១ | ស្ពានអាកាស | 21041 | ថ្លៃដើម | ៤០ លានរៀល | ២០-៥០ | រំលស់ថេរ |
| | | | | | ០២ | ស្ពានបេតុង | 21041 | ថ្លៃដើម | ៤០ លានរៀល | ១០-៥០ | រំលស់ថេរ |
| | | | | | ០៣ | ស្ពានដែក | 21041 | ថ្លៃដើម | ៤០ លានរៀល | ៥-២០ | រំលស់ថេរ |
| | | | | | ០៤ | ស្ពានឈើ | 21041 | ថ្លៃដើម | ៤០ លានរៀល | ៥-១០ | រំលស់ថេរ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ០៥ | ស្ពានផ្សេងៗ | 21041 | ថ្ងៃដើម | ៤០ លានរៀល | ៥-២៥ | រំលស់ថេរ |
| | | | ០៣ | ហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក | | | | | | | |
| | | | | | ០១ | កំពង់ផែ ឬ កំពង់ចម្លង | 21041 | ថ្ងៃដើម | ៤០ លានរៀល | ៥-៣០ | រំលស់ថេរ |
| | | | | | ០២ | ផែបណ្តែតទឹក | 21041 | ថ្ងៃដើម | ៤០ លានរៀល | ៥-៣០ | រំលស់ថេរ |
| | | | | | ០៣ | ឧបករណ៍ទំនាក់ទំនង | 21041 | ថ្ងៃដើម | ៤០ លានរៀល | ៣-១៥ | រំលស់ថេរ |
| | | | | | ០៤ | បរិក្ខារផ្លូវនាវាចរណ៍ | 21041 | ថ្ងៃដើម | ៤០ លានរៀល | ៣-១៥ | រំលស់ថេរ |
| | | | | | ០៥ | ផ្សេងៗ | 21041 | ថ្ងៃដើម | ៤០ លានរៀល | ៣-១៥ | រំលស់ថេរ |
| | | | ០៤ | ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ | | | | | | | |
| | | | | | ០១ | ប្រព័ន្ធធារាសាស្ត្រ | 21042 | ថ្ងៃដើម | ៤០ លានរៀល | ៥-៣០ | រំលស់ថេរ |
| | | | | | ០២ | ការស្តារនិងការកែលម្អប្រព័ន្ធធារាសាស្ត្រ និងទន្លេបឹងបួរ | 21042 | ថ្ងៃដើម | ៤០ លានរៀល | ៥-៣០ | រំលស់ថេរ |
| | | | | | ០៣ | ច្រាំងទន្លេ | 21042 | ថ្ងៃដើម | ៤០ លានរៀល | ៥-៣០ | រំលស់ថេរ |
| | | | | | ០៤ | ឧបករណ៍ស្រោចស្រព | 21042 | ថ្ងៃដើម | ៤០ លានរៀល | ៥-៣០ | រំលស់ថេរ |
| | | | | | ០៥ | ប្រព័ន្ធបង្ហូរនិងទប់ស្កាត់ទឹកជំនន់ | 21042 | ថ្ងៃដើម | ៤០ លានរៀល | ៥-៣០ | រំលស់ថេរ |
| | | | | | ០៦ | ប្រឡាយស្រោចស្រព | 21042 | ថ្ងៃដើម | ៤០ លានរៀល | ៥-៣០ | រំលស់ថេរ |
| | | | | | ០៧ | ទ្វារទឹក ទំនប់ | 21042 | ថ្ងៃដើម | ៤០ លានរៀល | ៥-៣០ | រំលស់ថេរ |
| | | | | | ០៨ | ផ្សេងៗ | 21042 | ថ្ងៃដើម | ៤០ លានរៀល | ៥-៣០ | រំលស់ថេរ |
| | | | ០៥ | ហេដ្ឋារចនាសម្ព័ន្ធផ្លូវដែក | | | | | | | |
| | | | | | ០១ | ស្ថានីយ៍អាយស្ម័យយាន | 21043 | ថ្ងៃដើម | ៤០ លានរៀល | ៥-១៥ | រំលស់ថេរ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ០២ | ផ្លូវដែក | 21043 | ថ្លៃដើម | ៤០ លានរៀល | ៥-១៥ | រំលស់ថេរ |
| | | | | | ០៣ | ឧបករណ៍ទំនាក់ទំនង | 21043 | ថ្លៃដើម | ៤០ លានរៀល | ៥-១៥ | រំលស់ថេរ |
| | | | | | ០៤ | បរិក្ខារផ្លូវដែក | 21043 | ថ្លៃដើម | ៤០ លានរៀល | ៥-១៥ | រំលស់ថេរ |
| | | | | | ០៥ | ផ្សេងៗ | 21043 | ថ្លៃដើម | ៤០ លានរៀល | ៥-១៥ | រំលស់ថេរ |
| | | | ០៦ | ហេដ្ឋារចនាសម្ព័ន្ធផ្លូវអាកាស | | | | | | | |
| | | | | | ០១ | ស្ថានីយ៍អ្នកដំណើរ | 21044 | ថ្លៃដើម | ៤០ លានរៀល | ៨-២០ | រំលស់ថេរ |
| | | | | | ០២ | ផ្លូវចុះចតយន្តហោះ | 21044 | ថ្លៃដើម | ៤០ លានរៀល | ៨-២០ | រំលស់ថេរ |
| | | | | | ០៣ | ឧបករណ៍ទំនាក់ទំនង | 21044 | ថ្លៃដើម | ៤០ លានរៀល | ៨-២០ | រំលស់ថេរ |
| | | | | | ០៤ | ឧបករណ៍ជូនដំណឹងពីរន្ទះ | 21044 | ថ្លៃដើម | ៤០ លានរៀល | ៨-២០ | រំលស់ថេរ |
| | | | | | ០៥ | ឧបករណ៍ឧត្តុនិយមផ្លូវអាកាស | 21044 | ថ្លៃដើម | ៤០ លានរៀល | ៨-២០ | រំលស់ថេរ |
| | | | | | ០៦ | ប្រព័ន្ធគ្រប់គ្រងចរាចរណ៍ផ្លូវអាកាស | 21044 | ថ្លៃដើម | ៤០ លានរៀល | ៨-២០ | រំលស់ថេរ |
| | | | | | ០៧ | ផ្សេងៗ | 21044 | ថ្លៃដើម | ៤០ លានរៀល | ៨-២០ | រំលស់ថេរ |
| | | | ០៧ | ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និងកខ្វក់ | | | | | | | |
| | | | | | ០១ | រោងចក្រកែច្នៃទឹកកខ្វក់ អាងចម្រោះទឹកកខ្វក់ | 21047 | ថ្លៃដើម | ៤០ លានរៀល | ៥-៣០ | រំលស់ថេរ |
| | | | | | ០២ | រោងចក្រ អាងកែច្នៃទឹកស្អាត អាងចម្រោះទឹកស្អាត | 21047 | ថ្លៃដើម | ៤០ លានរៀល | ៥-៣០ | រំលស់ថេរ |
| | | | | | ០៣ | ប្រព័ន្ធទុយោទឹក | 21047 | ថ្លៃដើម | ៤០ លានរៀល | ៥-៣០ | រំលស់ថេរ |
| | | | | | ០៤ | ស្ថានីយ៍បូមទឹកកខ្វក់ និងទឹកស្អាត | 21047 | ថ្លៃដើម | ៤០ លានរៀល | ៥-៣០ | រំលស់ថេរ |
| | | | | | ០៥ | អាងស្តុកទឹកចំហ (មិនពាក់ព័ន្ធនឹងផ្លូវ) | 21047 | ថ្លៃដើម | ៤០ លានរៀល | ៥-៣០ | រំលស់ថេរ |
| | | | | | ០៦ | បណ្តាញលូ | 21047 | ថ្លៃដើម | ៤០ លានរៀល | ៥-៣០ | រំលស់ថេរ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ០៧ | ផ្សេងៗ | 21047 | ថ្លៃដើម | ៤០ លានរៀល | ៥-៣០ | រំលស់ថេរ |
| | | | ០៨ | ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ | | | | | | |
| | | | | ០១ | ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ | 21048 | ថ្លៃដើម | ៤០ លានរៀល | ៥-១៥ | រំលស់ថេរ |
| | ០៤ | ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន | | | | | | | | |
| | | | ០១ | ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន | | | | | | |
| | | | | ០១ | អង់តែន ប៉មទំនាក់ទំនង | 21045 | ថ្លៃដើម | ១០ លានរៀល | ៣-១០ | រំលស់ថេរ |
| | | | | ០២ | ផ្កាយរណប | 21045 | ថ្លៃដើម | ១០ លានរៀល | ៣-១០ | រំលស់ថេរ |
| | | | | ០៣ | ខ្សែកាប ខ្សែកាបអុបទិក | 21045 | ថ្លៃដើម | ១០ លានរៀល | ៣-១០ | រំលស់ថេរ |
| | | | | ០៤ | ឧបករណ៍ទំនាក់ទំនង | 21045 | ថ្លៃដើម | ៦ លានរៀល | ៣-១០ | រំលស់ថេរ |
| | | | | ០៥ | ឧបករណ៍តភ្ជាប់ | 21045 | ថ្លៃដើម | ៦ លានរៀល | ៣-១០ | រំលស់ថេរ |
| | | | | ០៦ | ផ្សេងៗ | 21045 | ថ្លៃដើម | ៦ លានរៀល | ៣-១០ | រំលស់ថេរ |
| | ០៥ | បណ្ដាញចែកចាយ និងផ្គត់ផ្គង់អគ្គិសនី | | | | | | | | |
| | | | ០១ | បណ្ដាញចែកចាយអគ្គិសនី | | | | | | |
| | | | | ០១ | បណ្ដាញបញ្ជូនអគ្គិសនី(ខ្សែកាប បង្គោល) | 21046 | ថ្លៃដើម | ៤០ លានរៀល | ៥-១៥ | រំលស់ថេរ |
| | | | | ០២ | ស្ថានីយ៍បញ្ជូនអគ្គិសនី ត្រង់ស្វូ កាប៊ីនភ្លើង | 21046 | ថ្លៃដើម | ៤០ លានរៀល | ៥-១៥ | រំលស់ថេរ |
| | | | | ០៣ | ផ្សេងៗ | 21046 | ថ្លៃដើម | ៤០ លានរៀល | ៥-១៥ | រំលស់ថេរ |
| | | | ០២ | ប្រព័ន្ធចាត់ចែងគ្រប់គ្រងអគ្គិសនី | | | | | | |
| | | | | ០១ | ប្រព័ន្ធគ្រប់គ្រងថាមពល និងចែកចាយ | 21046 | ថ្លៃដើម | ៤០ លានរៀល | ៥-១៥ | រំលស់ថេរ |
| | | | | ០២ | ផ្សេងៗ | 21046 | ថ្លៃដើម | ៤០ លានរៀល | ៥-១៥ | រំលស់ថេរ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ០៣ | រោងចក្រអគ្គិសនី | | | | | | | |
| | | | | | ០១ | ភារីអគ្គិសនី | 21046 | ថ្ងៃដើម | ៤០ លានរៀល | ១៥-៣០ | រំលស់ថេរ |
| | | | | | ០២ | រោងចក្រអគ្គិសនីដើរដោយថាមពលធ្យូងថ្ម | 21046 | ថ្ងៃដើម | ៤០ លានរៀល | ១៥-៣០ | រំលស់ថេរ |
| | | | | | ០៣ | រោងចក្រអគ្គិសនីដើរដោយថាមពលប្រេងឥន្ធនៈ | 21046 | ថ្ងៃដើម | ៤០ លានរៀល | ១៥-៣០ | រំលស់ថេរ |
| | | | | | ០៤ | រោងចក្រអគ្គិសនីដើរដោយថាមពលកកើតឡើងវិញ | 21046 | ថ្ងៃដើម | ៤០ លានរៀល | ១៥-៣០ | រំលស់ថេរ |
| | | | | | ០៥ | ផ្សេងៗ | 21046 | ថ្ងៃដើម | ៤០ លានរៀល | ១៥-៣០ | រំលស់ថេរ |
| | ០៦ | សម្ភារ ឧបករណ៍ដឹកជញ្ជូន | | | | | | | | | |
| | | | ០១ | សម្ភារ ឧបករណ៍ដឹកជញ្ជូនផ្លូវគោក | | | | | | | |
| | | | | | ០១ | រថយន្ត | 21081 | ថ្ងៃដើម | ៨ លានរៀល | ៥-១០ | រំលស់ថេរ |
| | | | | | ០២ | រថយន្តដឹកទំនិញ | 21081 | ថ្ងៃដើម | ៨ លានរៀល | ៥-១០ | រំលស់ថេរ |
| | | | | | ០៣ | ទោចក្រយានយន្ត | 21081 | ថ្ងៃដើម | ៤ លានរៀល | ៣-១០ | រំលស់ថេរ |
| | | | | | ០៤ | ត្រីចក្រយានយន្ត | 21081 | ថ្ងៃដើម | ៣ លានរៀល | ៣-១០ | រំលស់ថេរ |
| | | | | | ០៥ | ផ្សេងៗ | 21081 | ថ្ងៃដើម | ៣ លានរៀល | ៣-១០ | រំលស់ថេរ |
| | | | ០២ | សម្ភារ ឧបករណ៍ដឹកជញ្ជូនផ្លូវទឹក | | | | | | | |
| | | | | | ០១ | កប៉ាល់ | 21081 | ថ្ងៃដើម | ៨ លានរៀល | ៥-២០ | រំលស់ថេរ |
| | | | | | ០២ | សាឡង់ កាណូត | 21081 | ថ្ងៃដើម | ៤ លានរៀល | ៥-២០ | រំលស់ថេរ |
| | | | | | ០៣ | ម៉ូតូទឹក | 21081 | ថ្ងៃដើម | ៨ លានរៀល | ៥-២០ | រំលស់ថេរ |
| | | | | | ០៤ | ទូក | 21081 | ថ្ងៃដើម | ៣ លានរៀល | ៥-២០ | រំលស់ថេរ |
| | | | | | ០៥ | ផ្សេងៗ | 21081 | ថ្ងៃដើម | ៣ លានរៀល | ២-២០ | រំលស់ថេរ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ០៣ | សម្ភារ ឧបករណ៍ដឹកជញ្ជូនផ្លូវដែក | | | | | | | |
| | | | | | ០១ | ក្បាលរថភ្លើង | 21081 | ថ្លៃដើម | ៨ លានរៀល | ៥-២០ | វិលស់ថេរ |
| | | | | | | ទូរថភ្លើង | 21081 | ថ្លៃដើម | ៤ លានរៀល | ៣-២០ | វិលស់ថេរ |
| | | | | | ០២ | ផ្សេងៗ | 21081 | ថ្លៃដើម | ៤ លានរៀល | ៥-២០ | វិលស់ថេរ |
| | | | ០៤ | សម្ភារ ឧបករណ៍ដឹកជញ្ជូនផ្លូវអាកាស | | | | | | | |
| | | | | | ០១ | យន្តហោះ | 21081 | ថ្លៃដើម | ១០ លានរៀល | ១០-២០ | វិលស់ថេរ |
| | | | | | ០២ | ឧទ្ធម្ភាគចក្រ | 21081 | ថ្លៃដើម | ១០ លានរៀល | ១០-២០ | វិលស់ថេរ |
| | | | | | ០៣ | ផ្សេងៗ | 21081 | ថ្លៃដើម | ១០ លានរៀល | ១០-២០ | វិលស់ថេរ |
| | ០៧ | សម្ភារ ឧបករណ៍ការិយាល័យ | | | | | | | | | |
| | | | ០១ | សម្ភារ ឧបករណ៍ការិយាល័យ | | | | | | | |
| | | | | | ០១ | ម៉ាស៊ីនកាត់ក្រដាស | 21082 | ថ្លៃដើម | ៣ លានរៀល | ៥-១០ | វិលស់ថេរ |
| | | | | | ០២ | ម៉ាស៊ីនថតចំលងឯកសារ | 21082 | ថ្លៃដើម | ៣ លានរៀល | ៣-១០ | វិលស់ថេរ |
| | | | | | ០៣ | ម៉ាស៊ីនស្កេនឯកសារ | 21082 | ថ្លៃដើម | ៣ លានរៀល | ៣-១០ | វិលស់ថេរ |
| | | | | | ០៤ | ម៉ាស៊ីនរាប់លុយ | 21082 | ថ្លៃដើម | ៣ លានរៀល | ៥-១០ | វិលស់ថេរ |
| | | | | | ០៥ | ម៉ាស៊ីនត្រជាក់ | 21082 | ថ្លៃដើម | ៣ លានរៀល | ២-១០ | វិលស់ថេរ |
| | | | | | ០៦ | ម៉ាស៊ីនកំដៅ | 21082 | ថ្លៃដើម | ៣ លានរៀល | ២-១០ | វិលស់ថេរ |
| | | | | | ០៧ | ផ្សេងៗ | 21082 | ថ្លៃដើម | ៣ លានរៀល | ៥-១០ | វិលស់ថេរ |
| | ០៨ | សម្ភារ ព័ត៌មានវិទ្យា និងទូរគមនាគមន៍ | | | | | | | | | |
| | | | | ០១ | សម្ភារ ព័ត៌មានវិទ្យា និងទូរគមនាគមន៍ | | | | | | |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ០១ | កុំព្យូទ័រ | 21083 | ថ្ងៃដើម | ៤ លានរៀល | ៣-១០ | រំលស់ថេរ |
| | | | | | ០២ | បណ្ដាញប្រព័ន្ធកុំព្យូទ័រ | 21083 | ថ្ងៃដើម | ៤ លានរៀល | ៣-១០ | រំលស់ថេរ |
| | | | | | ០៣ | ម៉ាស៊ីនមេ | 21083 | ថ្ងៃដើម | ៤ លានរៀល | ៣-១០ | រំលស់ថេរ |
| | | | | | ០៤ | ឧបករណ៍ចាក់បញ្ចាំង | 21083 | ថ្ងៃដើម | ៤ លានរៀល | ៣-១០ | រំលស់ថេរ |
| | | | | | ០៥ | ម៉ាស៊ីនបោះពុម្ពឯកសារ | 21083 | ថ្ងៃដើម | ៤ លានរៀល | ៣-១០ | រំលស់ថេរ |
| | | | | | ០៦ | អាគុយផ្គត់ផ្គង់ភ្លើង | 21083 | ថ្ងៃដើម | ៤ លានរៀល | ២-១០ | រំលស់ថេរ |
| | | | | | ០៧ | ផ្សេងៗ | 21083 | ថ្ងៃដើម | ៤ លានរៀល | ៣-១០ | រំលស់ថេរ |
| | ០៩ | គ្រឿងសង្ហារឹម និងបរិក្ខារបំពាក់ | | | | | | | | | |
| | | | ០១ | គ្រឿងសង្ហារឹម | | | | | | | |
| | | | | | ០១ | ទូ | 21084 | ថ្ងៃដើម | ៣ លានរៀល | ២-១០ | រំលស់ថេរ |
| | | | | | ០២ | តុ | 21084 | ថ្ងៃដើម | ៣ លានរៀល | ២-១០ | រំលស់ថេរ |
| | | | | | ០៣ | កៅអី | 21084 | ថ្ងៃដើម | ៣ លានរៀល | ២-១០ | រំលស់ថេរ |
| | | | | | ០៤ | សាឡុង | 21084 | ថ្ងៃដើម | ៣ លានរៀល | ២-១០ | រំលស់ថេរ |
| | | | | | ០៥ | គ្រែ | 21084 | ថ្ងៃដើម | ៣ លានរៀល | ២-១០ | រំលស់ថេរ |
| | | | | | ០៦ | ទូដែក | 21084 | ថ្ងៃដើម | ៣ លានរៀល | ២-១០ | រំលស់ថេរ |
| | | | | | ០៧ | ទ្វារសុវត្ថិភាព | 21084 | ថ្ងៃដើម | ៣ លានរៀល | ២-១០ | រំលស់ថេរ |
| | | | | | ០៨ | សម្ភារខណ្ឌចែកការិយាល័យ | 21084 | ថ្ងៃដើម | ៣ លានរៀល | ២-១០ | រំលស់ថេរ |
| | | | | | ០៩ | ផ្សេងៗ | 21084 | ថ្ងៃដើម | ៣ លានរៀល | ២-១០ | រំលស់ថេរ |
| | | | ០២ | បរិក្ខារបំពាក់ | | | | | | | |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ០១ | ទូរទស្សន៍ | 21084 | ថ្លៃដើម | ៣ លានរៀល | ២-១០ | រំលស់ថេរ |
| | | | | | ០២ | ទូទឹកកក ម៉ាស៊ីនចម្រោះទឹក | 21084 | ថ្លៃដើម | ៣ លានរៀល | ២-១០ | រំលស់ថេរ |
| | | | | | ០៣ | ម៉ូនីទ័រ | 21084 | ថ្លៃដើម | ៣ លានរៀល | ២-១០ | រំលស់ថេរ |
| | | | | | ០៤ | បរិក្ខារតាំងលម្អ | 21084 | ថ្លៃដើម | ៣ លានរៀល | ២-១០ | រំលស់ថេរ |
| | | | | | ០៥ | ផ្សេងៗ | 21084 | ថ្លៃដើម | ៣ លានរៀល | ២-១០ | រំលស់ថេរ |
| | ១០ | ស្នាដៃសិល្បៈនិងការប្រមូល ( សន្សំ) និងទ្រព្យសម្បត្តិបេតិកភណ្ឌ | | | | | | | | | |
| | | | ០១ | ស្នាដៃសិល្បៈ និងការប្រមូល( សន្សំ) | | | | | | | |
| | | | | | ០១ | គំនូរ ចម្លាក់ និងការងារសិល្បៈផ្សេងៗ | 21061 | ថ្លៃដើម | ១០ លានរៀល | មិនអនុវត្ត | មិនអនុវត្ត |
| | | | | | ០២ | រូបបដិមាករ ឬរូបសំណាក | 21061 | ថ្លៃដើម | ១០ លានរៀល | មិនអនុវត្ត | មិនអនុវត្ត |
| | | | | | ០៣ | ផ្សេងៗ | 21061 | ថ្លៃដើម | ១០ លានរៀល | មិនអនុវត្ត | មិនអនុវត្ត |
| | | | ០២ | ទ្រព្យសម្បត្តិបេតិកភណ្ឌ | | | | | | | |
| | | | | | ០១ | វិមាន ប្រាសាទ | 21061 | ថ្លៃដើម | ១០ លានរៀល | មិនអនុវត្ត | មិនអនុវត្ត |
| | | | | | ០២ | វត្តអារាម ព្រះវិហារ | 21061 | ថ្លៃដើម | ១០ លានរៀល | មិនអនុវត្ត | មិនអនុវត្ត |
| | | | | | ០៣ | សំណង់ប្រវត្តិសាស្ត្រ | 21061 | ថ្លៃដើម | ១០ លានរៀល | មិនអនុវត្ត | មិនអនុវត្ត |
| | | | | | ០៤ | បណ្ណាល័យ | 21061 | ថ្លៃដើម | ១០ លានរៀល | មិនអនុវត្ត | មិនអនុវត្ត |
| | | | | | ០៥ | ផ្សេងៗ | 21061 | ថ្លៃដើម | ១០ លានរៀល | មិនអនុវត្ត | មិនអនុវត្ត |
| | ១១ | គ្រឿងចក្រ និងឧបករណ៍ | | | | | | | | | |
| | | | ០១ | គ្រឿងចក្រ និងឧបករណ៍ | | | | | | | |
| | | | | | ០១ | គ្រឿងចក្រជីក កាយ កិនដី | 21088 | ថ្លៃដើម | ២០ លានរៀល | ៥-១០ | រំលស់ថេរ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ០២ | គ្រឿងចក្ររុញ ឈូស ឆាយដី | 21088 | ថ្លៃដើម | ១០ លានរៀល | ៥-១០ | វិលស់ថេរ |
| | | | | | ០៣ | យានយន្តឯកទេស | 21088 | ថ្លៃដើម | ១០ លានរៀល | ៥-១០ | វិលស់ថេរ |
| | | | | | ០៤ | ម៉ាស៊ីនស្ទូច លើក ស្តេន | 21088 | ថ្លៃដើម | ១០ លានរៀល | ៥-១០ | វិលស់ថេរ |
| | | | | | ០៥ | គ្រឿងយន្តកសិកម្ម | 21088 | ថ្លៃដើម | ១០ លានរៀល | ៥-១០ | វិលស់ថេរ |
| | | | | | ០៦ | គ្រឿងចក្របច្ចេកទេស | 21088 | ថ្លៃដើម | ១០ លានរៀល | ៥-១០ | វិលស់ថេរ |
| | | | | | ០៧ | ម៉ាស៊ីនបោះពុម្ពខ្នាតធំ | 21088 | ថ្លៃដើម | ១០ លានរៀល | ៥-១០ | វិលស់ថេរ |
| | | | | | ០៨ | ម៉ាស៊ីនភ្លើង | 21088 | ថ្លៃដើម | ១០ លានរៀល | ៥-១០ | វិលស់ថេរ |
| | | | | | ០៩ | ជណ្តើរយន្ត | 21088 | ថ្លៃដើម | ១០ លានរៀល | ៥-១០ | វិលស់ថេរ |
| | | | | | ១០ | ឧបករណ៍ពិសោធន៍ | 21088 | ថ្លៃដើម | ១០ លានរៀល | ៣-១០ | វិលស់ថេរ |
| | | | | | ១១ | ឧបករណ៍ និងបរិក្ខារវេជ្ជសាស្ត្រ | 21088 | ថ្លៃដើម | ១០ លានរៀល | ៣-១០ | វិលស់ថេរ |
| | | | | | ១២ | ម៉ាស៊ីនថតរូប | 21088 | ថ្លៃដើម | ៣ លានរៀល | ៣-១០ | វិលស់ថេរ |
| | | | | | ១៣ | ម៉ាស៊ីនសម្រាប់ដំណើរការកែច្នៃ | 21088 | ថ្លៃដើម | ១០ លានរៀល | ៣-១០ | វិលស់ថេរ |
| | | | | | ១៤ | ផ្សេងៗ | 21088 | ថ្លៃដើម | ៣ លានរៀល | ៣-១០ | វិលស់ថេរ |
| | ១២ | សព្វាវុធយោធា | | | | | | | | | |
| | | | ០១ | សព្វាវុធយោធា | | | | | | | |
| | | | | | ០១ | អាវុធ | 21088 | ថ្លៃដើម | ១០ លានរៀល | មិនអនុវត្ត | មិនអនុវត្ត |
| | | | | | ០២ | កប៉ាល់ចម្បាំង | 21088 | ថ្លៃដើម | ១០ លានរៀល | មិនអនុវត្ត | មិនអនុវត្ត |
| | | | | | ០៣ | រថក្រោះ រថពាសដែក | 21088 | ថ្លៃដើម | ១០ លានរៀល | មិនអនុវត្ត | មិនអនុវត្ត |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ០៤ | ផ្សេងៗ | 21088 | ថ្ងៃដើម | ១០ លានរៀល | មិនអនុវត្ត | មិនអនុវត្ត |
| | ១៣ | ទ្រព្យសកម្មរូបីផ្សេងៗ | | | | | | | | | |
| | | | ០១ | ទ្រព្យសកម្មរូបីផ្សេងៗ | | | | | | | |
| | | | | | ០១ | ទ្រព្យសកម្មរូបីផ្សេងៗ | 21088 | ថ្ងៃដើម | ៣ លានរៀល | ២-១០ | រំលស់ថេរ |

## ឧបសម្ព័ន្ធ ២÷ គំរូបញ្ជីទ្រព្យសកម្មរយៈពេលវែង

| ល.រ | ទ្រព្យសកម្មរយៈពេលវែង | បរិមាណ | លេខនាកូដសម្គាល់ | លេខអត្តសញ្ញាណ | ស្លាកចំន | ទីតាំង | ថ្ងៃចុះក្នុងបញ្ជី | ថ្ងៃចាប់ផ្តើមដាក់ឱ្យប្រើប្រាស់ ឬដំណើរការ | មាតិកាគណនី | ថ្លៃដើម | បន្ថែម | លក់ឬលុបចេញ | អាយុកាលប្រើប្រាស់ | រំលស់សម្រាប់ការិយបរិច្ឆេទរាយការណ៍ | រំលស់ចុះបង្គរ | តម្លៃយោងគណនេយ្យ | ប្រភពថវិកា | ចំណាត់ថ្នាក់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | | | | | | |
| ១ | | | | | | | | | | | | | | | | | | |
| ២ | | | | | | | | | | | | | | | | | | |
| ៣ | | | | | | | | | | | | | | | | | | |
| ៤ | | | | | | | | | | | | | | | | | | |
| ៥ | | | | | | | | | | | | | | | | | | |
| ៦ | | | | | | | | | | | | | | | | | | |
| xx | | | | | | | | | | | | | | | | | | |
| | | | | | | | | សរុប | | | | | | | | | | |

ឧបសម្ព័ន្ធ ៣÷គំរូរបាយការណ៍ចំណាយរំលស់ទ្រព្យសកម្មរយៈពេលវែង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ឈ្មោះ រដ្ឋបាល/ គ្រឹះស្ថាន និងនិមិត្តសញ្ញា

(បើមាន)

ថ្ងៃ ខែ ឆ្នាំ ព.ស

រាជធានី/ខេត្ត ថ្ងៃទី ខែ ឆ្នាំ________

## របាយការណ៍ចំណាយរំលស់ទ្រព្យសកម្មរយៈពេលវែង

- ឈ្មោះ និងអាសយដ្ឋាននៃអង្គភាពគ្រប់គ្រងៈ
- ឈ្មោះ និងអាសយដ្ឋាននៃរដ្ឋបាល/ គ្រឹះស្ថាន
- លេខកូដស្ថាប័នសាធារណៈ÷ រដ្ឋបាល/ គ្រឹះស្ថានៈ
- ស្នើរតនាគារកណ្តាល/រាជធានីខេត្ត កត់ត្រារំលស់ប្តូកបន្តក្នុងជំពូក គណនី ដូចខាងក្រោមៈ

| ល.រ | បរិយាយ | ជំពូក | គណនី | អនុគណនី | រូបិយបណ្ណ | ទឹកប្រាក់រំលស់ប្តូកបន្ត | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១ | រំលស់ប្តូកបន្ត គណនី សម្ភារ ឧបករណ៍ដឹកជញ្ជូន | ២៨ | ២៨០៨ | ២៨០៨១ | រៀល | xxx | |
| ២ | រំលស់ប្តូកបន្ត គណនី............ | | | | | xxx | |
| ៣ | | | | | | | |
| xxx | | | | | | | |
| រំលស់ប្តូកបន្តទ្រព្យសកម្មរយៈពេលវែងសម្រាប់ការិយបរិច្ឆេទរាយការណ៍ (សរុបរួម) | | | | | | xxxx | |

សរុបជាអក្សរចំណាយរំលស់សម្រាប់ការិយបរិច្ឆេទរាយការណ៍÷ (________________________________) រៀល

**បានឃើញនិងឯកភាព** **អ្នកពិនិត្យ** **អ្នករៀបចំ**

ឯកសារភ្ជាប់ (១) បញ្ជីទ្រព្យសកម្មរយៈពេលវែងសម្រាប់ការិយបរិច្ឆេទរាយការណ៍

ឧបសម្ព័ន្ធ ៤÷គំរូសលាកបត្របង់ចំណូលថវិកា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

{Logo}

**{ឈ្មោះស្ថាប័នសាធារណៈ}**

**{ឈ្មោះ អង្គភាព}**

លេខ..................................

ថ្ងៃ.................. ខែ....... ឆ្នាំ........ ស័ក ព.ស. ..........

ធ្វើនៅ......... ថ្ងៃទី ................ ខែ......... ឆ្នាំ ........

## សលាកបត្របង់ចំណូលថវិកា

- ឈ្មោះនិងអាសយដ្ឋាននៃអង្គភាពបង់ប្រាក់ចូលថវិកា÷................................
- ឈ្មោះនិងអាសយដ្ឋាននៃអង្គភាពជាម្ចាស់គ្រប់គ្រង÷.................................
- ឈ្មោះនិងលេខគម្រោង.........................................................................
- ឈ្មោះនិងលេខហិរញ្ញប្បទានឥតសំណង.......................................................

| | |
|---|---|
| លេខសម្គាល់ | ÷{លេខកូដក្រសួង ឬអង្គភាព} |
| លេខកូដសម្គាល់ទ្រព្យ÷......................... | |
| ឥណពន្ធ | ÷៤៧០៥......................... |
| ឥណទាន | ÷៧៥............................ |

| អនុគណនី | អត្ថន័យខ្ទង់ចំណូល | ចំនួនទឹកប្រាក់ | | | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ដុល្លារអាមេរិកទៅជារៀល | ជារៀល | សរុបទឹកប្រាក់ជារៀល |
| | | | | | |
| | | | | | |
| | សរុបរួម | | | | |

ចំនួនទឹកប្រាក់សរសេរជាអក្សរ÷...........................................................................................................

**ប្រធានស្ថាប័នសាធារណៈ:** អ្នកពិនិត្យ មន្ត្រីអនុវត្តគម្រោង

ឧបសម្ព័ន្ធ ៥÷គំរូសលាកបត្រទទួលស្គាល់ចំណាយថវិកា

**ព្រះរាជាណាចក្រកម្ពុជា**

{Logo} **ជាតិ សាសនា ព្រះមហាក្សត្រ**

**{ឈ្មោះស្ថាប័នសាធារណៈ}**

**{ឈ្មោះ អង្គភាព}**

ថ្ងៃ.................... ខែ........ ឆ្នាំ......... ស័ក ព.ស. ..........

លេខ....................................

ធ្វើនៅ.......... ថ្ងៃទី ................. ខែ.......... ឆ្នាំ ........

**សលាកបត្រទទួលស្គាល់ចំណាយថវិកា**

លេខសម្គាល់ ÷{លេខកូដក្រសួង ឬអង្គភាព}

លេខកូដសម្គាល់ទ្រព្យ÷.........................

ឥណពន្ធ ÷២១.........................

ឥណទាន ÷៤៧០៥.............................

- ឈ្មោះនិងអាសយដ្ឋាននៃអង្គភាព÷...................................................................

- ឈ្មោះនិងលេខគម្រោង...................................................................................

- ឈ្មោះនិងលេខហិរញ្ញប្បទានឥតសំណង.........................................................

| អនុគណនី | អត្ថន័យខ្ទង់ចំណាយ | ចំនួនទឹកប្រាក់ | | | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ដុល្លារអាមេរិកទៅជារៀល | ជារៀល | សរុបទឹកប្រាក់ជារៀល |
| | | | | | |
| | | | | | |
| | សរុបរួម | | | | |

ចំនួនទឹកប្រាក់សរសេរជាអក្សរ÷...................................................................................................................

**ប្រធានស្ថាប័នសាធារណៈ** អ្នកពិនិត្យ មន្ត្រីអនុវត្តគម្រោង